# សម្រែកព្រៃឈើ

## ទស្សនៈពុទ្ធសាសនាស្តីពីបរិស្ថាន

អត្ថបទសិក្សាសំរាប់សហគមន៍វត្ត



ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស ២៥៤៣

www.elibraryofcambodia.org

www.elibraryofcambodia.org

# សំរែកព្រៃឈើ

## ទស្សនៈព្រះពុទ្ធសាសនាស្តីពីបរិស្ថាន

អត្ថបទសិក្សាសំរាប់សហគមន៍វត្ត

បោះពុម្ពលើកទី ១

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
រួមសហការជាមួយក្រុមការងារអង្គការក្រៅរដ្ឋាភិបាល
គម្រោងការអប់រំបរិស្ថានសំរាប់ព្រះសង្ឃខ្មែរ

គ.ស. ១៩៩៩

ថ្ងៃសុក្រ ៣ កើត ខែអស្សុជ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨
(២៦-០៩-២០១៤) ចម្លងបាន! ភិក្ខុ វិសាខបញ្ញោ ឈាង សុវណ្ណ
គង់នៅវត្ត សំពៅមាស រាជធានីភ្នំពេញ ។

www.elibraryofcambodia.org

www.elibraryofcambodia.org

# សេចក្ដីថ្លែងអំណរគុណ

សៀវភៅដែលព្រះតេជព្រះគុណ-លោកអ្នកកំពុងកាន់អាននេះ បានប្រសូតចេញជារូបរាងឡើង តាមគោលគំនិតនៃការបោះពុម្ពផ្សាយសៀវភៅដើមឈ្មោះ " **សំរែកព្រៃឈើ** " (A Cry From The Forest) ដែលជាឯកសារអប់រំ រំលេចដោយរូបភាព ចងក្រងដោយ *គម្រោងទស្សនៈព្រះពុទ្ធសាសនា ចំពោះធម្មជាតិ* (Buddhist Perception of Nature Project) របស់អ្នកប្រាជ្ញថៃ និងទីបេ នៅពាក់កណ្ដាលទសវត្សឆ្នាំ ១៩៨០ ដោយមានការឧបត្ថម្ភគាំទ្រពី *មូលនិធិការពារសត្វព្រៃថៃ* (Wildlife Fund Thailand) ។ ជាអ្នកប្រាជ្ញស្រាវជ្រាវ និងជាអ្នកនិពន្ធមួយរូប លោកបណ្ឌិត **ឆាត់ស៊ូម៉ាន កាប៊ីលស៊ីង** (Dr.Chatsumarn Kabilsingh) ប្រចាំការនៅសកលវិទ្យាល័យ **ធម្មសាស្ត្រ** ប្រទេសថៃ បានជំរុញទឹកចិត្តឱ្យមានការបង្កើតសៀវភៅនេះ ជាភាសាខ្មែរឡើង ។ ដូចគ្នានឹងសៀវភៅដើមដែរ ឯកសារនេះ បានរៀបចំតាក់តែងឡើង ក្នុងគោលបំណងលើកយកបញ្ហាបរិស្ថាន ដែលលេចធ្លោជាងគេមកបង្ហាញ តាមរយៈការបង្រៀនគោលការណ៍សីលធម៌ព្រះពុទ្ធសាសនា នៅក្នុងប្រទេសមួយ ដែលមានប្រជាពលរដ្ឋ ៩០ ភាគរយ ជាអ្នកកាន់ព្រះពុទ្ធសាសនា ។

មូលនិធិជាដំបូងគេសំរាប់រៀបចំបង្កើតសៀវភៅនេះ បានផ្ដល់ឱ្យរួមគ្នាដោយ *កម្មវិធីគ្រប់គ្រងបរិស្ថានកម្ពុជា* (Cambodia Environmental Management Program/CEMP) របស់ *ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍអន្តរជាតិ* (USAID) ហើយនិង *កម្មវិធីជំនួយបច្ចេកទេសបរិស្ថាន " អ៊ីតាប់ "* (Environmental Technical Advisory Programme/ETAP) នៃកម្មវិធីអភិវឌ្ឍសហប្រជាជាតិ (United Nations Development Programme/UNDP) ។ គម្រោងអ៊ីតាប់ (ETAP) បានបន្តជួយឧបត្ថម្ភដល់ការងារនេះ ចាប់តាំងពីខែ កក្កដា ១៩៩៧ កន្លងមក ដោយបានផ្ដល់ការគាំទ្រ និងជំនួនបច្ចេកទេសពីលោក **ភីធ័រ ចនស្តុន** (Peter Johnston) និងលោក **ឆិន ពន្លក** ជាប្រធានគំរោង ព្រមទាំងពីបណ្ឌិត **ភីធ័រ យ៉ាឡាយផាប់** (Dr. Peter Gyallay-Pap) ដែលជាទីប្រឹក្សាផ្នែកអប់រំបរិស្ថានផងដែរ ។ ព្រះភិក្ខុ **យស ហ៊ុត ខេមចារោ** នៃសមាគមធម្មទូត វត្តលង្កា រាជធានីភ្នំពេញ និងព្រះភិក្ខុ **ហៀម គឹមតេង** ប្រធានអង្គការសន្តិសេនា វត្តព្រៃធ្លាក់ ខេត្តស្វាយរៀង បានផ្ដល់ឱវាទឈានមុខ ក្នុងឋានៈព្រះអង្គទាំង ២ ជាអ្នកផ្ដល់យោបល់សំខាន់ឱ្យដល់គម្រោងការមួយនេះ ។



www.elibraryofcambodia.org

លោក **មេខ គីម ទរីន់** និងលោក **ស៊ុ រតន្យា** ជាអ្នកធ្វើការស្រាវជ្រាវដំបូង សំរាប់រឿងព្រេងពុទ្ធសាសនារបស់ខ្មែរ និងការបង្រៀននេះ ។ លោក **យឹម ឌុក** ជាអ្នកបកប្រែឯកសារអង់គ្លេស មកជាភាសាខ្មែរ ដោយមានការផ្ទៀងផ្ទាត់ និងកែសំរួលជាថ្មីដោយលោក **អ៊ុខ ម៉ុនធឿន** ។ កញ្ញា **រូត បូតុមលី** (Ruth Bottomley) ជាអ្នកព្រាង និងចងក្រងឯកសារដើមជាភាសាអង់គ្លេស ហើយលោក **ខម សត្យា** ជាវិចិត្រករ ។ ព្រះភិក្ខុបណ្ឌិត **អូម៉ាល់ប៊េ សោភិត ថេរោ** (Ven. Dr. Omalbe Sobhita Thero) និមន្តមកពីប្រទេសស្រីលង្កា ដែលបំរើការងារជាអ្នកស្មគ្រចិត្តនៃអង្គការសហប្រជាជាតិ ក្នុងឋានៈជាទីប្រឹក្សាផ្នែកអប់រំបរិស្ថាននៃអង្គការអ៊ីតាប់ បានផ្ទៀងផ្ទាត់ និងកែសំរួលឯកសារ ជាភាសាអង់គ្លេសនេះឡើងវិញ ។ មានស្ថាប័នជាច្រើននៅភ្នំពេញ បានផ្តល់ឯកសារសំខាន់ៗ នៅក្នុងអំឡុងពេលនៃការស្រាវជ្រាវ ក្នុងនោះរួមមាន **បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ** ជាដើម ។ បញ្ជីឯកសារពិគ្រោះសំរាប់ការចងក្រងសៀវភៅនេះ មាននៅផ្នែកខាងចុងបង្អស់នៃសៀវភៅ ។ នៅទីបញ្ចប់ សូមថ្លែងអំណរគុណជាថ្មីម្តងទៀតចំពោះព្រះភិក្ខុ **តឿង គីមតេខ** ជាប្រធានអង្គការសន្តិសេនា វត្តព្រៃឆ្លាក់ ខេត្តស្វាយរៀង និងជាប្រធានប្រតិបត្តិនៃក្រុមអង្គការគម្រោងការអប់រំបរិស្ថានសំរាប់ព្រះសង្ឃខ្មែរ ហើយនិងឯកឧត្តម **ឈន អឿម** បច្ចុប្បន្នជារដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ព្រមទាំងសិក្ខាកាមជាព្រះសង្ឃ និងគ្រហស្ថទាំងអស់ ដែលបាននិមន្ត និងចូលរួមក្នុង *សិក្ខាសាលាជាតិស្តីពីការបណ្តុះបណ្តាលគ្រូឧទ្ទេសបរិស្ថានជាព្រះសង្ឃ* ដែលបានប្រព្រឹត្តទៅពីថ្ងៃទី ២៩ មិថុនា ដល់ ៥ កក្កដា ១៩៩៨ នៅវត្តសំរោងអណ្តែត រាជធានីភ្នំពេញ ហើយបានជួយផ្តល់ជាយោបល់ និងសំណូមពរកែលំអអត្ថបទទាំងនេះ ឱ្យទៅជាឯកសារព្រាងមួយមានភាពសុក្រិតឡើងថែមទៀត ទាក់ទងទៅនឹងបរិបទព្រះពុទ្ធសាសនា ដើម្បីជាប្រយោជន៍ដល់ការលើកស្ទួយគុណធម៌បរិស្ថាននៅទូទាំងព្រះរាជាណាចក្រកម្ពុជាយើងនេះ តាមរយៈវត្តអារាម ព្រះសង្ឃ ដូនជី តាជី និងសហគមន៍មូលដ្ឋាន ។

**បរិស្ថានជាជីវិតរបស់អ្នក**



www.elibraryofcambodia.org

# បញ្ជីមាតិកា

**ចំណងជើង** **ទំព័រ**


សេចក្តីថ្លែងអំណរគុណ ........ i

បញ្ជីមាតិកា........ iii

អារម្ភកថា ........ 1

១. សេចក្តីផ្តើម ........ 1

២ ព្រះពុទ្ធសាសនា និងបរិស្ថាន........ 3

៣. រឿងព្រេងពុទ្ធនិយម និងទំនាក់ទំនងទៅនឹងបរិស្ថាន........ 4

៤. តួនាទីរបស់ព្រះសង្ឃនៅក្នុងការអប់រំបរិស្ថាន........ 5

៥. របៀបប្រើសៀវភៅនេះ........ 6

**ជំពូកទី ១ : ការអប់រំបរិស្ថាន** ........ 9

- មេរៀន ១ ក. ឈូក និងការអប់រំបរិស្ថាន ........ 11
- មេរៀន ១ ខ. គតិបណ្ឌិតបរិស្ថាន ........ 15
- មេរៀន ១ គ. សត្វទទា ស្វា និងដំរី ........ 19
- *សកម្មភាព : ការស្វែងយល់អំពីបរិស្ថាននៅក្នុងមូលដ្ឋាន* ........ 23

**ជំពូកទី ២ : បរិស្ថានល្អជាមាគ៌ាជីវិតនៃពុទ្ធសាសនិកជន** ........ 25

- មេរៀន ២ ក. ព្រះធម៌ និងបរិស្ថាន ........ 27
- មេរៀន ២ ខ. ធម្មយាត្រា ........ 31
- មេរៀន ២ គ. ការអភិវឌ្ឍសហគមន៍តាមរយៈវត្តអារាម ........ 35
- មេរៀន ២ ឃ. វត្តអារាម ........ 39
- មេរៀន ២ ង. ការវិវត្តនៃរដូវកាល និងមាគ៌ាព្រះពុទ្ធសាសនា ........ 43




www.elibraryofcambodia.org

- មេរៀន ២ ច.  ការយល់ដឹងបរិស្ថានតាមរយៈភាសាបាលី ........................................47
- មេរៀន ២ ឆ.  និមិត្តរូបនៃផ្កាឈូក ........................................................ 51
- មេរៀន ២ ជ.  ការបំបួសដើមឈើ ........................................................ 55
- *សកម្មភាព :   បរិស្ថានល្អ ជាមាតាជីវិតរបស់ពុទ្ធសាសនិកជន* ...................................59

**ជំពូកទី ៣ : ការបង្កើតនិរន្តរភាពបរិស្ថាន** ..........................................................63
- មេរៀន ៣ ក.  បរិស្ថានសមស្របល្អ ..........................................................65
- មេរៀន ៣ ខ. អាកជីវិតរបស់ព្រះពុទ្ធ ..........................................................69
- មេរៀន ៣ គ. ទឹកជាប្រភពនៃជីវិត ..........................................................73
- មេរៀន ៣ ឃ. ជំនឿ និងទម្លាប់នៅតាមមូលដ្ឋាន ............................................77
- មេរៀន ៣ ង. សត្វសេក និងដើមជ្រៃ ..........................................................81
- មេរៀន ៣ ច. ការធ្វើបុណ្យកុសលតាមរយៈអំណោយសួនឧទ្យាន ...............................85
- *សកម្មភាព :   ការបង្កើតឱ្យមានបរិស្ថានសមស្របល្អ* ...........................................89

**ជំពូកទី ៤ : ការរក្សាការពារធនធានធម្មជាតិ** ..........................................................91
- មេរៀន ៤ ក.  ការប្រើប្រាស់ធនធានធម្មជាតិ..........................................................93
- មេរៀន ៤ ខ.  វត្តប្រតិបត្តិ ៤ យ៉ាង .......................................................... 97
- មេរៀន ៤ គ.  អ្នកជំនួញ និងដើមពោធិ..........................................................101
- មេរៀន ៤ ឃ.  ការប្រើប្រាស់ដ៏ត្រឹមត្រូវនៃផលព្រឹក្ស ...........................................105
- មេរៀន ៤ ង.  តម្លៃនៃផលព្រឹក្ស..........................................................109
- *សកម្មភាព :   ការប្រើប្រាស់ធនធានធម្មជាតិ*..........................................................113

**ជំពូកទី ៥ : តម្លៃនៃព្រៃឈើ** ..........................................................115
- មេរៀន ៥ ក.  តម្លៃនៃព្រៃឈើ..........................................................117
- មេរៀន ៥ ខ.  ដើមឈើសំខាន់ៗក្នុងអាកជីវិតរបស់ព្រះពុទ្ធ ......................................121



www.elibraryofcambodia.org

- មេរៀន ៥ គ. ដើមពោធិព្រឹក្ស ......................................... 125
- មេរៀន ៥ ឃ. ព្រៃឈើសហគមន៍នៅប្រទេសកម្ពុជា ......................................... 129
- មេរៀន ៥ ង. ព្រះភិក្ខុ និងរុក្ខទេវី ......................................... 133
- *សកម្មភាព : តម្លៃនៃព្រៃឈើ* ......................................... 137

**ជំពូកទី ៦ : ការស្វែងយល់តម្លៃសត្វព្រៃ** ......................................... 139
- មេរៀន ៦ ក. សត្វព្រៃ និងព្រៃព្រឹក្សា ......................................... 141
- មេរៀន ៦ ខ. ករុណាធម៌របស់ព្រះពុទ្ធចំពោះសត្វ ......................................... 145
- មេរៀន ៦ គ. ដីក្នុងព្រះពុទ្ធសាសនា ......................................... 149
- មេរៀន ៦ ឃ. ព្រានប្រមាញ់ និងសត្វដីរ ......................................... 153
- មេរៀន ៦ ង. រឿងសុវណ្ណសាម ......................................... 157
- មេរៀន ៦ ច. បុរសបរិភោគស៊ុតសត្វ ......................................... 161
- មេរៀន ៦ ឆ. នាគ ......................................... 165
- *សកម្មភាព : ការល្បែងយល់តម្លៃសត្វព្រៃ* ......................................... 169

**ជំពូកទី ៧ : ការចៀសវាងការបំពុល និងសំណល់** ......................................... 171
- មេរៀន ៧ ក. ការបំពុលប្រភពទឹក ......................................... 173
- មេរៀន ៧ ខ. ការថែរក្សាបរិស្ថានឱ្យបានស្អាតជានិច្ច ......................................... 177
- មេរៀន ៧ គ. សារសំខាន់នៃអនាម័យ ......................................... 181
- មេរៀន ៧ ឃ. ការបំពុលដោយសូរសំឡេង ......................................... 185
- មេរៀន ៧ ង. កំណែច្នៃជាថ្មីឡើងវិញ ......................................... 189
- *សកម្មភាព : យើងចៀសវាងការបំពុលបរិស្ថាន* ......................................... 193

**ឯកសារពិគ្រោះ** ......................................... 195

**ការអប់រំបរិស្ថាន ជាភារកិច្ចរបស់យើងទាំងអស់គ្នា**

www.elibraryofcambodia.org

www.elibraryofcambodia.org

# អារម្ភកថា

## ១. សេចក្តីផ្តើម

ក្នុងរយៈពេលជាច្រើនទសវត្សកន្លងមក គោលបំណងនៃការអភិវឌ្ឍនៅអាស៊ីអាគ្នេយ៍ បានផ្តោតការយកចិត្តទុកដាក់ជាសំខាន់ ទៅលើការលូតលាស់ផ្នែកសេដ្ឋកិច្ច ដោយបានធ្វើការពិចារណាបន្តិចបន្តួច ឬគ្មានទាល់តែសោះ ចំពោះរាល់ទិដ្ឋភាពនៃការអភិវឌ្ឍសង្គម វប្បធម៌ និងបរិស្ថាន ដើម្បីបង្កើនគុណភាពនៃជីវិត ។ ការធ្វើអាជីវកម្មហួសហេតុ ជាពិសេសលើធនធានធម្មជាតិ[១] ដើម្បីកេងយកចំណេញផ្នែកសេដ្ឋកិច្ចឯកជនឱ្យបានក្នុងរយៈពេលមួយដ៏ខ្លី កំពុងតែធ្វើឱ្យបរិស្ថានជួបប្រទះនឹងភាពរេចរឹលបន្តិចម្តងៗ យ៉ាងឆាប់រហ័ស ការបាត់បង់ការគោរពចំពោះតម្លៃប្រពៃណី និងការមានអារម្មណ៍ឃ្លាតឆ្ងាយពីគ្រួសារ សហគមន៍ វប្បធម៌ និងទឹកដី ។ ព្រះពុទ្ធសាសនា ដែលជាប្រព័ន្ធមួយនៃជំនឿ និងមាគ៌ាជីវិត តែងតែជួយលើកតម្កើងតម្លៃរបស់សហគមន៍ និងវប្បធម៌ តាំងពីបុរាណកាលមក ហើយនិងធ្វើឱ្យមានអត្តសញ្ញាណកម្ម ជាមួយនឹងពិភពធម្មជាតិដែលនៅជុំវិញ ។ នាបុរាណកាល ព្រះពុទ្ធសាសនាបានចូលរួមចំណែកនូវអ្វីដែលយើងហៅថា ដំណើរការអភិវឌ្ឍ ដោយពឹងផ្អែកលើសហគមន៍ ដែលបានឆ្លើយតបលើសលប់ទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងធ្វើឱ្យខូចខាតដ៏តិចតួចដល់បរិស្ថាន ជាជាងការអភិវឌ្ឍតាមបែបសម័យទំនើបលោកខាងលិច ។ គោលការណ៍របស់ព្រះពុទ្ធសាសនា បានផ្តល់នូវដំណោះស្រាយប្រកបដោយសក្តានុពលភាព សំរាប់ដោះស្រាយបញ្ហានានា ដែលកប់នៅក្នុងទិដ្ឋភាពនៃការបំផ្លិចបំផ្លាញបរិស្ថាន មានរាប់តាំងពីការលោភលន់ ដែលធ្វើឱ្យមនុស្សចេញទៅកាប់ឈើទាំងស្របច្បាប់ ទាំងមិនស្របច្បាប់ ដើម្បីកេងយកចំណេញផ្នែកសេដ្ឋកិច្ច ឬមួយក៏ភាពក្រីក្រ និងភាពត្រូវតែលៃងរវល់គិត ដែលបង្ខំឱ្យអ្នកភូមិប្រើប្រាស់ធនធានធម្មជាតិមិនបានត្រឹមត្រូវ ។

នៅប្រទេសដទៃទៀតក្នុងតំបន់អាស៊ីអាគ្នេយ៍ ព្រះពុទ្ធសាសនាបានបង្ហាញឱ្យឃើញថា សាសនានេះអាចមានឥទ្ធិពល និងគុណប្រយោជន៍ដោយផ្ទាល់ ក្នុងការលើកទឹកចិត្តឱ្យមានការសង្គ្រោះសត្វព្រៃគ្រប់ប្រភេទ និងតំបន់ព្រៃឈើនានា រួមទាំងការធ្វើឱ្យបរិស្ថានកាន់តែស្អាត និងល្អប្រសើរឡើងថែមទៀត ។ ជាផ្នែកមួយនៃរបៀបរបបរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ ដែលកាន់ខ្ជាប់ទៅដោយសីលធម៌ និងវប្បធម៌ល្អ ពោលគឺ

---

[១] *ធនធានធម្មជាតិ ៖ អ្វីៗដែលកើតមានឡើងដោយលក្ខណៈធម្មជាតិ មានតម្លៃសំរាប់ជីវិតមនុស្ស ជាឧទាហរណ៍ ទឹក ដើមឈើ ដី និងរុក្ខជាតិដទៃទៀត ។*



www.elibraryofcambodia.org

ប្រហែល ៩០ ភាគរយ ជាពុទ្ធសាសនិកជននោះ ព្រះពុទ្ធសាសនាអាចប្រើជាប្រព័ន្ធឃោសនាដ៏សំខាន់ និងសមស្របមួយ សំរាប់បង្រៀន និងរៀនសូត្រអំពីគោលគំនិតសំខាន់ៗនៃបរិស្ថាន ដើម្បីធ្វើឱ្យប្រជាពលរដ្ឋ និងសហគមន៍នានា អាចមានលទ្ធភាពកាន់តែប្រសើរឡើងថែមទៀត ក្នុងការយកចិត្តទុកដាក់ថែទាំបរិស្ថាន ។ ជាប្រពៃណីដ៏យូរលង់ណាស់មកហើយ វត្តអារាម[២] បានក្លាយជានិមិត្តរូបដ៏សំខាន់មួយរបស់សហគមន៍ជនបទកម្ពុជា រហូតមកទល់សព្វថ្ងៃនេះ ។ ហេតុនេះហើយ វត្តអារាមបានត្រូវគេចាត់ទុកជាមជ្ឈមណ្ឌលមួយសមស្រប និងមានប្រសិទ្ធភាពខ្ពស់ ក្នុងការរៀបចំកម្មវិធីអប់រំ និងការយល់ដឹងអំពីបរិស្ថានដល់សហគមន៍មូលដ្ឋាន ។ ព្រះពុទ្ធសាសនាអាចជួយប្រជាពលរដ្ឋកម្ពុជា ឱ្យធ្វើដំណើរតាមគន្លងទិសដៅមួយនៃការអភិវឌ្ឍដែលធានាបាននូវនិរន្តរភាព[៣] និងអនាគតល្អមួយ ដែលប្រជាពលរដ្ឋអាចរស់នៅ ដោយចុះសំរុងជាមួយនឹងធម្មជាតិ វប្បធម៌ និងខ្លួនរបស់គេផ្ទាល់ ។ ម្យ៉ាងទៀត ទស្សនៈរបស់ព្រះពុទ្ធសាសនាស្តីពីវិបត្តិបរិស្ថាន ក៏អាចលើកទឹកចិត្តដល់ការអភិវឌ្ឍទស្សនៈអភិសមាចារ[៤] ឬក្រមសីលធម៌ ទាំងក្នុងពុទ្ធចក្រ ទាំងក្នុងអាណាចក្រ នៅក្នុងប្រទេសកម្ពុជាបានទៀតផង ។

សៀវភៅនេះ ត្រូវបានបង្កើតឡើង ជាផ្នែកមួយនៃកម្មវិធីអប់រំបរិស្ថានក្រៅប្រព័ន្ធ សំរាប់ព្រះសង្ឃ និងដូនជីកម្ពុជា ហើយដែលកម្មវិធីនេះ ត្រូវបានផ្តួចផ្តើមជាគំនិត និងសម្របសម្រួល ដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយក្រុមនៅប្រទេសកម្ពុជា ។ គោលដៅនៃកម្មវិធីនេះ គឺធ្វើឡើងតាមរយៈព្រះសង្ឃ តាមរយៈការបណ្តុះបណ្តាលព្រះសង្ឃ ឱ្យក្លាយទៅជាគ្រូឧទ្ទេស បន្តដល់គ្រប់ស្រទាប់ប្រជាពលរដ្ឋនៅជនបទ និងដឹកនាំប្រជាពលរដ្ឋទាំងនោះឱ្យយល់ តាមការបង្រៀន ឬទេសនា ដោយផ្តល់ចំណេះដឹងអំពីធម្មជាតិ ដើម្បីរួមគ្នាជួយថែរក្សា និងធ្វើឱ្យបរិស្ថាននៅកម្ពុជាមានលក្ខណៈល្អប្រសើរឡើង ។ ដោយមានការឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការយូអិនឌីភី-អ៊ីតាប់ (UNDP/ETAP) និងយូណេស្កូ (UNESCO) ផងនោះ ក្រុមអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក (NGOs) មួយ ត្រូវបានបង្កើតឡើង ដើម្បីបណ្តុះបណ្តាល និងធ្វើការផ្ទាល់ជាមួយនឹងក្រុមព្រះសង្ឃបង្គោលតាមវត្តនានា នៅក្នុងប្រទេសកម្ពុជា ឱ្យក្លាយទៅជាគ្រូឧទ្ទេសបន្តដល់ព្រះសង្ឃទាំងឡាយ គង់នៅតាមវត្តខេត្ត-ក្រុង នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ វត្ថុបំណងនេះ គឺ

---

[២] *វត្ត : ទីអារាម ។*

[៣] *និរន្តរភាព : ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការនាពេលបច្ចុប្បន្ន ដោយមិនធ្វើឱ្យចុះខ្សោយសមត្ថភាពនៃមនុស្សជំនាន់ក្រោយ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការផ្ទាល់របស់គេ នាពេលអនាគត ។*

[៤] *អភិសមាចារ : ប្រព័ន្ធនៃគោលការណ៍សីលធម៌ ។*



www.elibraryofcambodia.org

ដើម្បីឱ្យវត្តទាំងឡាយនៅប្រទេសកម្ពុជា មានគំនិតផ្ដើមរៀបចំការរៀនសូត្រអំពីបរិស្ថាន និងដឹកនាំអនុវត្តសកម្មភាពជាក់ស្ដែង នៅក្នុងសហគមន៍របស់ពួកគេតែម្ដង ។

## ២. *ព្រះពុទ្ធសាសនា និង បរិស្ថាន*

*អេកូឡូស៊ី* [៥] សំដៅទៅលើការសិក្សាពីទំនាក់ទំនងទៅវិញទៅមកនៃរុក្ខជាតិ និងសត្វគ្រប់ប្រភេទរវាងគ្នានិងគ្នា (រួមទាំងមនុស្សផង) ហើយនិងរវាងមជ្ឈដ្ឋានជុំវិញរបស់វាផង ។ ការសិក្សាអំពីអេកូឡូស៊ីបង្ហាញឱ្យឃើញថា អ្វីៗទាំងអស់នៅក្នុងបរិដ្ឋានមានលក្ខណៈទាក់ទង និងពឹងផ្អែកគ្នាទៅវិញទៅមក ។ មានការទទួលស្គាល់ជាទូទៅថា ការបំផ្លិចបំផ្លាញព្រៃឈើនៅកម្ពុជាអាចធ្វើឱ្យទឹកភ្លៀងធ្លាក់មិនទៀងទាត់ ដែលជះឥទ្ធិពលមិនល្អដល់ផលិតកម្មកសិកម្ម ដោយសារតែមានគ្រោះរាំងស្ងួត និងទឹកជំនន់ជាច្រើនលើកច្រើនសា ។

ព្រះពុទ្ធសាសនាបានប្រកាន់យកនូវសច្ចធម៌មួយមានឈ្មោះថា "*ការចាប់កំណើតមិនអាស្រ័យលើខ្លួនឯង*" ឬជាភាសាបាលីថា "**បដិច្ចសមុប្បាទ**" (ក្នុងធម៌ព្រះពុទ្ធសាសនាគេស្គាល់ថាជា ច្បាប់លក្ខខណ្ឌ) ដែលតាមច្បាប់នោះ គេយល់ថា រាល់ភាវៈទាំងអស់នៅក្នុងចក្រវាលនេះ មានទំនាក់ទំនង និងអាស្រ័យនឹងគ្នាទៅវិញទៅមក ។ មានន័យថា គ្មានអ្វីអាចរស់រាន មានជីវិតដោយខ្លួនឯងបានឡើយ ប៉ុន្តែវាត្រូវតែមានទំនាក់ទំនងទៅនឹងវត្ថុដទៃទៀត នៅលើផែនដី និងនៅក្នុងចក្រវាលនេះ ។ បរិស្ថានមានន័យថា "*មជ្ឈដ្ឋានជុំវិញខ្លួន*" ហើយបើនិយាយឱ្យងាយយល់ គឺមានន័យថា ខ្លួនយើងគ្រប់រូប ដែលជាសរពាង្គកាយមនុស្ស រួមជាមួយពិភពមនុស្ស ពិភពធម្មជាតិ និងពិភពវប្បធម៌ ដែលនៅជុំវិញយើង ។ គោលការណ៍ **បដិច្ចសមុប្បាទ** សង្កត់ធ្ងន់លើសេចក្ដីត្រូវការសំរាប់ការរស់នៅរួមគ្នា រវាងភាគចំណែកទាំងអស់របស់បរិស្ថាន ទោះមានជីវិតក្ដី និងគ្មានជីវិតក្ដី ហើយលើកទឹកចិត្តដល់ការគោរព និងការយោគយល់គ្នា រវាងមនុស្សជាតិគ្រប់រូប និងភាវៈមានជីវិតទាំងអស់ ដែលរស់រាននៅលើពិភពលោកយើងតែមួយ ។ មនុស្សជាតិមិនត្រូវមើលឃើញខ្លួនឯងថាជាភាវៈ ដែលស្ថិតរស់នៅដាច់តែឯងពីបរិស្ថាននោះទេ មនុស្សគឺជាផ្នែកមួយនៃបរិស្ថានដែរ ។ ប្រសិនបើបរិស្ថានត្រូវទទួលរងការបំផ្លិចបំផ្លាញ មនុស្សជាតិក៏មិនអាចរស់នៅបានឡើយ ហើយបើមនុស្សធ្វើទុក្ខទោស ឬរំលោភទៅលើធម្មជាតិ ឬវប្បធម៌របស់អ្នកណាមួយ មានន័យថា មនុស្សក៏ធ្វើទុក្ខដល់ខ្លួនឯងដែរ ។ ប៉ុន្តែ

---

[៥] *អេកូឡូស៊ី "ecology" : មកពីពាក្យក្រិច "oikos" មានន័យថា ផ្ទះ ឬ ជម្រក ។ ខ្លះនិយមហៅថា "បរិស្ថានវិទ្យា" ដែលមានន័យថា ជាវិទ្យាសាស្ត្រ ដែលសិក្សាពីទំនាក់ទំនងរវាងភាវៈរស់ និងបរិស្ថានដែលវារស់នៅ ។*



www.elibraryofcambodia.org

បើមនុស្សចេះគោរព និងប្រព្រឹត្តទៅលើបរិស្ថានដោយចិត្តធម៌មេត្តាករុណា និងមានការគិតគូរពិចារណា នោះសុខុមាលភាពរបស់មនុស្សជាតិ ក៏ត្រូវបានធានាដែរ ។ ដូចដែលអ្នកដឹកនាំព្រះពុទ្ធសាសនានៅកម្ពុជាមួយព្រះអង្គ គឺសម្តេចព្រះមហាឃោសានន្ទ ព្រះអង្គមានពុទ្ធដីកាថា :

*"មនុស្ស និងព្រៃឈើមានទំនាក់ទំនងគ្នា ។*
*ប្រសិនបើយើងថែរក្សាខ្លួនយើង*
*យើងក៏នឹងត្រូវថែរក្សាព្រៃឈើដែរ*
*ហើយព្រៃឈើនឹងថែរក្សាផលយើងវិញ"[៦] ។*

## ៣. រឿងព្រេងពុទ្ធនិយម និង ទំនាក់ទំនងទៅនឹងបរិស្ថាន

តាំងពីបុរាណកាលមកម្ល៉េះ អ្នកធ្វើអត្ថាធិប្បាយផ្នែកព្រះពុទ្ធសាសនា បានប្រើរឿងព្រេង សំរាប់ជាវិធីសាស្ត្របកស្រាយ និងពន្យល់អំពីការប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ គម្ពីរធម្មបទ ដែលជាគាថាភាសាបាលីមានពុទ្ធភាសិតចំនួន ៤២៣ សរសេរជាពាក្យកាព្យ គឺជាឧទាហរណ៍មួយនៃប្រជុំរឿងព្រេងនិទាន និងរឿងប្រជាប្រិយជាច្រើន ដែលបានលើកបង្ហាញអំពីអត្ថន័យនៃពាក្យ និងវត្ថុឃ្លាដ៏ពិសេសណាមួយ ។

នៅពេលដែលយើងមើលអត្ថបទព្រះពុទ្ធសាសនាបែបបុរាណទាំងនេះ ដំបូងយើងឃើញថា វាហាក់ដូចជាមាននិយាយយោងដោយផ្ទាល់តែបន្តិចបន្តួចប៉ុណ្ណោះ ទៅលើអ្វីដែលឥឡូវនេះគេហៅថា គំនិតស្តីពីបរិស្ថាន ឬអេកូឡូស៊ី និងបញ្ហារបស់វា ។ នេះក៏ព្រោះតែកាលនោះ ពិភពលោកដែលព្រះពុទ្ធគង់នៅ និងបង្រៀន គឺជាពិភពមួយដែលមានភាពចុះសំរុងគ្នា រវាងផ្នែកទាំងអស់នៃបរិស្ថាន ។ មែនទែនទៅ ការអប់រំបរិស្ថានមិនចាំបាច់ត្រូវធ្វើឡើយនៅពេលនោះ ។ ប៉ុន្តែ ការពិពណ៌នាជាច្រើន ដែលមាននៅក្នុងរឿងព្រេងពុទ្ធនិយម ក្រើនរំលឹកយើង ឱ្យយល់ដឹងពីធម្មជាតិដែលធ្លាប់មានកាលពីដើម និងបង្ហាញថា តើឥឡូវយើងបាត់បង់វាអស់ប៉ុណ្ណាហើយ ។ រឿងព្រេងទាំងនេះ តែងតែលើកតំណាលអំពីវាសនដ្ឋានក្នុងព្រៃ និងការធ្វើសមាធិ នៅក្នុងមជ្ឈដ្ឋានធម្មជាតិដែលនៅជុំវិញ ។ ទំនាក់ទំនងដ៏រឹងមាំដែលមនុស្សធ្លាប់ផ្សារភ្ជាប់ជាមួយនឹងធម្មជាតិ មានបង្ហាញស្រាប់នៅក្នុងរឿងនិទានស្តីពីជីវិតរបស់ព្រះពុទ្ធ ដែលហេតុការណ៍សំខាន់ទាំងនោះ ច្រើនកើតមានឡើងនៅទីជនបទ ហើយផ្សារភ្ជាប់ជាមួយនឹងដើមឈើជានិច្ច ។

---

[៦] *ដកស្រង់ពីសិក្ខាសាលាស្តីពីព្រះពុទ្ធសាសនា និងការការពារបរិស្ថាន ដែលប្រារព្ធធ្វើឡើងនៅខេត្តស្វាយរៀង ពីថ្ងៃទី ២០ ដល់ ទី ២៣ កុម្ភៈ ១៩៩៥ ។*



www.elibraryofcambodia.org

ម្យ៉ាងទៀត រឿងព្រេងពុទ្ធនិយមតែងតែបង្កប់នូវនិមិត្តរូបនិយម[៧] យ៉ាងច្រើន ដែលទាក់ទងមួយផ្នែកទៅនឹងប្រភេទរុក្ខជាតិ និងសត្វជាច្រើន ។ ពុទ្ធឱវាទជាច្រើនបានប្រើប្រាស់ឧទាហរណ៍ និងការប្រៀបធៀបពីធម្មជាតិ ដើម្បីបង្ហាញឱ្យឃើញអំពីសីលធម៌ដ៏សំខាន់ៗ សំរាប់អប់រំផ្លូវចិត្ត ។ សត្វតែងតែបានលើកបង្ហាញជាមួយនឹងក្តីអាណិតអាសូរ និងយល់គ្នាជាខ្លាំង ។ មានសត្វខ្លះ ដូចជាដំរី សេះ និងទាតជាដើម នៅក្នុងរឿងទេវកថា ត្រូវបានប្រើជាឧទាហរណ៍ ដើម្បីលើកបង្ហាញនូវគុណសម្បត្តិយ៉ាងវិសេស ។ រឿងនិទានទាំងនេះ សំរាប់បង្រៀនមនុស្សឱ្យយល់អំពីសារសំខាន់នៃគុណធម៌ដ៏ខ្ពស់ ដែលមនុស្សខ្លួនឯងជូនកាលបានបង្ហាញឱ្យឃើញថាអន់ជាងសត្វទៅទៀត ។ គោលដៅ គឺត្រូវបង្រៀនមេរៀនសីលធម៌តាមរយៈ រូបាធិដ្ឋាន[៨] និងដើម្បីបង្ហាញទីតាំងសត្វ ដែលតែងតែនៅជាប់ជាមួយមនុស្ស នៅក្នុងទស្សនៈព្រះពុទ្ធសាសនា ស្តីពីពិភពលោក ។

ដោយពឹងផ្អែកទៅលើមូលដ្ឋានគ្រឹះខាងលើ សៀវភៅនេះ បានដកស្រង់រឿងនិទានជាច្រើនតាមបែបពុទ្ធនិយម និងរឿងប្រជាប្រិយខ្លះៗ ដើម្បីបង្ហាញឱ្យឃើញពីអភិសមាចារ ឬក្រមសីលធម៌បរិស្ថាន ។ ថ្វីបើក្រមសីលធម៌បរិស្ថាននេះ មិនមែនជាគោលបំណងនៃរឿងនិទានទាំងនេះពីដើមទីមកក្តី ក៏វាបានគូសបញ្ជាក់ នូវក្រមច្បាប់សីលធម៌ សំរាប់កែតម្រង់អាកប្បកិរិយាឱ្យបានត្រឹមត្រូវ ដែលសព្វថ្ងៃនេះត្រូវបានគេបកស្រាយថា ជាមាគ៌ាជីវិត ដែលអាចផ្តល់គុណប្រយោជន៍ឱ្យដល់បរិស្ថាន ។ រឿងនិទានមានបំណងឱ្យមានការពិភាក្សាអំពីបរិស្ថាន ជាពិសេសអំពីបញ្ហាបរិស្ថាន ដែលមានឥទ្ធិពលដល់សហគមន៍មូលដ្ឋានរបស់យើង ហើយវាក៏បង្ហាញឱ្យឃើញនូវគោលគំនិតដែលថា សហគមន៍ព្រះពុទ្ធសាសនាអាចដើរតួយ៉ាងសកម្ម ក្នុងការលើកកំពស់ការយល់ដឹងបរិស្ថាន ដែលជាមធ្យោបាយមួយឆ្ពោះទៅរកបរិស្ថានមានសោភណភាព និងសុខភាព សំរាប់យើងរស់នៅ ។

## ៤. តួនាទីរបស់ព្រះសង្ឃនៅក្នុងការអប់រំបរិស្ថាន

ការអភិរក្ស និងការពារបរិស្ថាន គឺមិនគ្រាន់តែជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលតែឯងប៉ុណ្ណោះទេ ថែមទាំងប្រជាពលរដ្ឋរស់នៅ ធ្វើការងារតាមសហគមន៍ជនបទ និងទីក្រុងនានា ក៏ត្រូវចូលរួមថែរក្សាការពារផងដែរ ។ ព្រះសង្ឃខ្មែរស្ថិតនៅក្នុងឋានៈមួយ ដែលអាចមានលទ្ធភាពផ្សព្វផ្សាយចំណេះដឹងអំពីបរិស្ថាន

---

[៧] *និមិត្តរូបនិយម : ការប្រើប្រាស់រូបភាព ដើម្បីតំណាងឱ្យអ្វីមួយផ្សេងទៀត ។*

[៨] *រូបាធិដ្ឋាន : កន្លែងដែលតួ ឬព្រឹត្តិការណ៍នៅក្នុងរឿងនិទាន ឬភាពយន្តត្រូវបានគេប្រើប្រាស់ ដើម្បីតំណាងឱ្យគុណសីលធម៌ ។*



www.elibraryofcambodia.org

នៅក្នុងសហគមន៍វត្ត ។ ព្រះសង្ឃ និងដូនជី អាចជួយប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ឱ្យមានការលើកស្ទួយការយល់ដឹងពីបរិស្ថាន ឥរិយាបថ និងអំពើនានា ដែលពាក់ពន្ធ័នឹងបរិស្ថាន នៅក្នុងសហគមន៍របស់ព្រះអង្គផ្ទាល់ ។ ដោយផ្អែកលើគោលការណ៍ខ្លួនជួយខ្លួនឯង និងស្វ័យទុកវិត្ត បញ្ហានានា ដែលមានចោទឡើងក្នុងមូលដ្ឋាន អាចនឹងដោះស្រាយបាន ដោយប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន ហើយវត្តក្នុងមូលដ្ឋានអាចជួយដូចដែលធ្លាប់ធ្វើតាំងពីបុរាណកាលមក ដោយការផ្តល់ការណែនាំ ដំបូន្មាន និងការលើកទឹកចិត្ត ។

ការទាក់ទិនរបស់ពុទ្ធសាសនិកជននៅក្នុងសង្គមបែបនេះ គេឱ្យឈ្មោះថា *"ព្រះពុទ្ធសាសនាចូលរួម នៅក្នុងសង្គម"* ។ ការពាក់ពន្ធ័នេះទាមទារនូវសុក្រឹតភាពនៃគតិបណ្ឌិតរបស់ពុទ្ធសាសនា និងមេត្តាធម៌ ដែលមានជាប្រពៃណី សំរាប់យកទៅប្រើនៅក្នុងការងារក្នុងសង្គម និងការអនុវត្តជាក់ស្តែង ។ តួនាទីរបស់វត្តនៅក្នុងការជំរុញគំនិតផ្តួចផ្តើម សំរាប់បំរើសេចក្តីត្រូវការចេះតែធំឡើងរបស់សហគមន៍បែបនេះ បានទទួលប្រជាប្រិយភាពកាន់តែច្រើនឡើងៗ នៅតំបន់អាស៊ីអាគ្នេយ៍ នៅក្នុងរយៈពេលថ្មីៗកន្លងមកនេះ ។ នៅកម្ពុជា សកម្មភាពបែបនេះរបស់វត្ត ឈរនៅលើមូលដ្ឋាននៃតួនាទីដើមរបស់វត្តអារាម ដែលជាមជ្ឈមណ្ឌលបំរើឱ្យការអប់រំ និងការងារសង្គមមួយដ៏សំខាន់ សំរាប់សហគមន៍មូលដ្ឋាន ។

ក្នុងនាមជាអ្នកដឹកនាំដែលគេគោរព និងមានតួនាទីជាគំរូនៅក្នុងសង្គម ព្រះសង្ឃអាចមានតួនាទីយ៉ាងសំខាន់មួយ ក្នុងការថែរក្សាបរិស្ថាននៅមូលដ្ឋានរបស់ខ្លួន ។ ជាញឹកញាប់ ព្រះសង្ឃ និងដូនជី ដែលរស់នៅតាមស្រុកជនបទ តែងតែមានទស្សនៈអំពីជីវិតដូចគ្នា ជាមួយនឹងអ្នកភូមិដែលរស់នៅជាមួយដែរ ។ ព្រះអង្គអាចមានឥទ្ធិពលលើជីវភាពរស់នៅរបស់សហគមន៍ តាមរយៈការធ្វើជាគំរូនាំមុខគេ និងជួយបង្កើនការយល់ដឹងអំពីឥទ្ធិពលរបស់មនុស្សជាតិ ដែលអាចមានទៅលើធម្មជាតិ និងសង្គម ហើយនឹងបង្ហាញឱ្យឃើញនូវការទទួលខុសត្រូវរបស់គេចំពោះកិច្ចការពារធម្មជាតិ និងការប្រើប្រាស់ធនធានទាំងនោះដោយប្រុងប្រយ័ត្ន ។

## ៥. *របៀបប្រើសៀវភៅនេះ*

អត្ថបទសិក្សាសំរាប់សហគមន៍នេះ ត្រូវបានរៀបចំឡើង ដើម្បីប្រើជាឧបករណ៍អប់រំក្រៅប្រព័ន្ធមួយ សំរាប់គ្រូឧទ្ទេសប្រើប្រាស់ ក្នុងការបង្រៀនព្រះសង្ឃ និងដូនជី នៅក្នុងសហគមន៍វត្ត ដែលធ្វើការជាមួយប្រជាពលរដ្ឋ តាមមូលដ្ឋានចំណុះជើងវត្ត ។ អត្ថបទទាំងនេះ ក៏អាចប្រើក្នុងសហគមន៍ដទៃទៀតបានដែរ ទៅតាមលទ្ធភាព តាមការសម្របសម្រួលរបស់អង្គការមិនមែនរដ្ឋាភិបាល សំរាប់ការងារអភិវឌ្ឍន៍សហគមន៍ ។ គោលដៅនៃអត្ថបទទាំងនេះ គឺដើម្បីបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋ ឱ្យកាន់តែល្អប្រសើរឡើង : ក) ទាក់ទងទៅនឹងគោលគំនិត ឬបញ្ញត្តិបរិស្ថាន តាមរយៈទស្សនៈរបស់ព្រះពុទ្ធសាសនា ខ) អំពីក៏រិត និង



www.elibraryofcambodia.org

មូលហេតុនៃការបំផ្លិចបំផ្លាញបរិស្ថាននៅកម្ពុជា និងទិកន្លែងដទៃទៀត ហើយនិង គ) ជាមធ្យោបាយផ្តល់ជាគំនិត សំរាប់ការអនុវត្តជាក់ស្តែង ទៅតាមគន្លងគោលការណ៍ព្រះពុទ្ធសាសនា និងវិធីដោះស្រាយបញ្ហាបរិស្ថាននៅក្នុងសហគមន៍មូលដ្ឋាន ។

សៀវភៅនេះចែកចេញជាប្រាំពីរជំពូក ដូចមានខាងក្រោម :

*១. ការអប់រំបរិស្ថាន*

*២. បរិស្ថានល្អ ជាមាតាំ ជីវិតនៃពុទ្ធសាសនិកជន*

*៣. ការបង្កើតនិរន្តរភាពបរិស្ថាន*

*៤. ការរក្សាការពារធនធានធម្មជាតិ*

*៥. តម្លៃនៃព្រៃឈើ*

*៦. ការស្វែងយល់តម្លៃសត្វព្រៃ*

*៧. ការចៀសវាងការបំពុល និងសំណល់ ។*

ជំពូកនីមួយៗ សុទ្ធតែមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក ។ មតិយោបល់ជាច្រើន ដែលបានពិភាក្សាក្នុងជំពូកណាមួយ អាចយកទៅអនុវត្តបាន ចំពោះបញ្ហាដែលមានលើកឡើង នៅក្នុងជំពូកដទៃទៀតក្នុងសៀវភៅនេះ ។ រឿងនិទាន និងបញ្ហាបរិស្ថាននានា ដែលមានពាក់ព័ន្ធលើកយកមកបង្ហាញនៅក្នុងសៀវភៅនេះ គឺមានបំណងដើម្បីជំរុញការពិភាក្សា និងការយល់ដឹងនៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ហើយសង្ឃឹមថា វានឹងជួយរកដំណោះស្រាយបញ្ហាបរិស្ថានទាំងនោះ ។

សៀវភៅនេះ បានចងក្រងឡើង ដើម្បីលើកតម្កើងការយល់ដឹងបរិស្ថាន និងដើម្បីផ្តល់នូវមូលដ្ឋានគ្រឹះសំខាន់ៗ ដែលអាចឱ្យគេបង្កើនចំណេះដឹងបរិស្ថាន និងធ្វើសកម្មភាពការពារបរិស្ថាន ។ ភាគច្រើននៃចំណេះដឹងបរិស្ថាន គឺមានរួចជាស្រេចទៅហើយ នៅក្នុងគតិបណ្ឌិត ដែលមានបង្កប់ជាយូរលង់មកហើយ នៅក្នុងសហគមន៍របស់យើង ។ សង្ឃឹមថា ឯកសារសិក្សានេះ នឹងជួយបង្ហាញឱ្យយើងគិតឃើញពីគតិបណ្ឌិតជាប្រពៃណីទាំងអស់នោះ ហើយនិងធ្វើឱ្យយើងប្រកាន់ខ្ជាប់នូវឥរិយាបថល្អប្រសើរថែមទៀត ចំពោះបរិស្ថាន និងការអភិរក្សបរិស្ថានជាក់ជាមិនខានឡើយ ។ ជាក្តីសង្ឃឹមផងដែរថា ឯកសារនេះ នឹងជួយបង្កើន និងពង្រីកជំនាញ ឬការប៉ិនប្រសប់ ក្នុងការកំណត់ការអង្កេត ស្រាវជ្រាវ និងការដោះស្រាយបញ្ហាបរិស្ថាន ដែលមានចោទឡើងនៅក្នុងសហគមន៍មូលដ្ឋាន ។ ក្នុងលក្ខណៈជាឯកសារសិក្សាសំរាប់សហគមន៍ ជាការពិតណាស់ការទទួលបានជោគជ័យ ឬបរាជ័យនៃការប្រើប្រាស់សៀវភៅនេះ វាអាស្រ័យទៅលើការចូលរួមយ៉ាងសកម្មរបស់សមាជិកសហគមន៍គ្រប់ឋានៈទាំងអស់ ។ មហាជនទាំងអស់នៅក្នុងសហគមន៍ ត្រូវការធ្វើការរួមគ្នា



www.elibraryofcambodia.org

ដើម្បីឱ្យយល់ច្បាស់លាស់ និងដោះស្រាយបញ្ហាបរិស្ថាន ដែលចោទឡើងចំពោះមុខ សំដៅលើកកំពស់គុណភាពនៃជីវិតរបស់យើង ឱ្យកាន់តែល្អប្រសើរថែមទៀត ។

ខាងក្រោមនេះ ជាចំណុចសំខាន់ៗមួយចំនួន សំរាប់ជាមគ្គុទេសក៏ដល់គ្រូឧទ្ទេស នៅតាមមូលដ្ឋាន ដែលប្រើប្រាស់អត្ថបទសិក្សាទាំងនេះ ក្នុងឋានៈជាអ្នកសំរបសំរួលក្រុមសិក្សា :

១ - ជំពូកនីមួយៗ មានចំរុះដោយអត្ថបទមេរៀនខ្លីៗជាច្រើន ដែលអាចយកមកអាន ឬកាន់តែល្អជាងនេះ គឺលើកយកមកនិទានឡើងវិញដោយខ្លួនឯងផ្ទាល់ ឬមួយក៏ទេសនាឱ្យស្តាប់ដល់មហាជន ដែលមកកាន់ទីវត្តអារាម ដើម្បីសិក្សាវិជ្ជាព្រះពុទ្ធសាសនា និងបរិស្ថាន បានស្តាប់និងត្រង់ត្រាប់តាម ។ នៅចុងបញ្ចប់នៃអត្ថបទមេរៀននីមួយៗ សុទ្ធតែមានសំរាំងលំហាត់ ឬសំណួរជាច្រើនទៀត សំរាប់ធ្វើការពិភាក្សាតាមក្រុមតូចៗ ។

២ - សៀវភៅនេះ មានបញ្ចូលរូបភាពជាច្រើន ដែលត្រូវលាតបង្ហាញជូនអ្នកសិក្សា នៅទន្ទឹមពេលកំពុងអាន ឬនិទាន និងពិភាក្សារឿង ។ ឧបករណ៍សោតទស្សន៍ ក៏អាចផ្តល់ប្រយោជន៍ច្រើន ក្នុងការទាក់ទាញអារម្មណ៍របស់អ្នកសិក្សា និងជួយជំរុញពួកគេឱ្យមានភាពក្លៀវក្លា ក្នុងការពិភាក្សាតាមក្រុម ទៅតាមបទពិសោធន៍ដែលពួកគេមានស្រាប់ ឬធ្លាប់ជួបប្រទះ។

៣ - នៅចុងជំពូកនិមួយៗ សុទ្ធតែមានអមដោយលំហាត់សកម្មភាពអនុវត្តជានិច្ច ក្នុងគោលបំណងដើម្បីពង្រឹងចំណេះដឹង ដែលបានសិក្សារួចមកហើយ និងដើម្បីជំរុញឱ្យមានការលើកទឹកចិត្តអ្នកសិក្សាឱ្យចេះរករឿងរ៉ាវ ឬបញ្ហានានាទាក់ទងនឹងបរិស្ថាន នៅពេលក្រោយៗមកទៀត ។ លំហាត់អស់ទាំងនេះបានសំរាំងនិងសំរបទៅតាមទំហំរបស់ក្រុម វ័យ និងសមត្ថភាពសិក្សា ។ គ្រូឧទ្ទេសព្រះសង្ឃ និងដូនជីប្រចាំក្រុមសហគមន៍ ឬសិស្សសាលា ក៏អាចប្រើប្រាស់លំហាត់បែបនេះបានដូចគ្នា ។

៤- ឧទាហរណ៍ជាច្រើន ទាក់ទងនឹងគម្រោងការងារបរិស្ថាន ដែលបានបង្កើតឡើងដោយសហគមន៍ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា និងថៃ ក៏មានលើកបង្ហាញជូនស្រាប់ នៅក្នុងសៀវភៅនេះដែរ រួមទាំងសំណូមពរផ្សេងៗ សំរាប់ដំណើរការការងារបរិស្ថាន នាពេលអនាគត ដោយផ្តើមចេញពីទស្សនៈនៃព្រះពុទ្ធសាសនានេះ ។

៥- បញ្ជីឯកសារពិគ្រោះ មាននៅខាងចុងសៀវភៅនេះ សំរាប់លើកទឹកចិត្តក្នុងការស្រាវជ្រាវជាបន្តៗទៀត ទៅតាមប្រធានបទ ដែលបានលើកឡើងនៅក្នុងឯកសារសិក្សានេះ ។

**បំផ្លាញបរិស្ថាន មានន័យថា បំផ្លាញជីវិតខ្លួនឯង**



www.elibraryofcambodia.org

# ជំពូកទី ១

# ការអប់រំបរិស្ថាន

មេរៀន ១ក : អ្នក និង ការអប់រំបរិស្ថាន

មេរៀន ១ខ : គតិបណ្ឌិតបរិស្ថាន

មេរៀន ១គ : សត្វចតា ស្វា និង ជីរ

*សកម្មភាព : ការស្វែងយល់បរិស្ថាននៅក្នុងមូលដ្ឋាន*

www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន ១ ក**

# ឈូក និង ការអប់រំបរិស្ថាន

នៅពេលដែលព្រះពុទ្ធជាអម្ចាស់បានត្រាស់ដឹង មានព្រហ្មមួយអង្គព្រះនាម **សហម្បតិ** បានអារាធនានិមន្តព្រះអង្គ សំដែងធម្មទេសនាប្រោសសត្វលោក ។ គ្រានោះ ព្រះពុទ្ធអង្គមិនទាន់ទទួលការនិមន្តភ្លាមទេ ដោយសារព្រះអង្គមានព្រះតំរិះថា : ពពួកសត្វជាបុថុជ្ជនក្រាស់ដោយកាម ពុំអាចយល់បាននូវព្រះសទ្ធម្ម ។ ក្រោយមកព្រះអង្គទ្រង់ព្រះតំរិះថា : គង់មានសត្វលោកខ្លះអាចយល់បាននូវព្រះសទ្ធម្មមិនខានឡើយ ។

ព្រះអង្គទ្រង់ប្រៀបធៀបសត្វលោក ទៅនឹងឈូកក្នុងជលដ្ឋាន ដែលមានចែកចេញជា ៣ ប្រភេទ គឺ ផ្កាឈូកនៅក្នុងទឹកមួយ ផ្កាឈូកនៅស្មើទឹកមួយ ផ្កាឈូកដុះផុតទឹករង់ចាំព្រះអាទិត្យមួយ ។ គឺដូចសត្វ ៣ ប្រភេទ :

*១ - សត្វលោកខ្លះ ក្រាស់ដោយធូលី ពោលគឺមានកាមតណ្ហាក្រាស់*

*២ - សត្វលោកខ្លះ ស្តើងដោយធូលី ពោលគឺមានកាមតណ្ហាស្តើង*

*៣ - សត្វលោកខ្លះ មានបញ្ញាខ្ពស់ ពោលគឺមាននិស្ស័យដែលព្រះអង្គអាចប្រោសបាន ។*

ដូច្នេះ *ធម៌របស់ព្រះអង្គ* នេះនឹងបានជាគុណប្រយោជន៍ដល់មនុស្សលោក ទោះតិចក្តី ច្រើនក្តី ទៅតាមកំរិតសមត្ថភាពនៃការយល់ដឹងរបស់ខ្លួន ។ ឈូកដែលដុះចេញផុតពីទឹក ប្រៀបទៅនឹងអ្នកដែលមានឧបនិស្ស័យខ្ពស់ អាចយល់បានយ៉ាងឆាប់រហ័ស ។ ឯឈូកដែលដុះចេញមកត្រឹមផ្ទៃទឹក ហើយដែលនឹងចេញជាផ្កានៅថ្ងៃបន្ទាប់នោះ គឺប្រៀបបានទៅនឹងសត្វលោក ដែលបានស្តាប់ ហើយកំពុងចាប់ផ្តើមយល់ជ្រួតជ្រាបជាបណ្តើរៗ លើកលែងតែមនុស្សមិនមាននិស្ស័យនឹងរៀនសូត្រ និងមិនស្តាប់ពាក្យទូន្មាន ។ សត្វលោកប្រភេទនោះ ប្រដូចបានទៅនឹងឈូកដែលដុះនៅក្រោមទឹក ដែលអាចនឹងត្រូវក្លាយជាចំណីរបស់ត្រី និងពពួកសត្វអណ្តើក ។

ប្រសិនបើយើងពិចារណាទៅលើការអប់រំបរិស្ថានតាមរបៀបនេះ យើងអាចយល់បានថា វាមានសារសំខាន់ណាស់ ក្នុងការអប់រំមនុស្សឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន ។ តាមរយៈនៃការអប់រំនេះ យើងអាចជួយឱ្យគេធ្វើការផ្លាស់ប្តូរឥរិយាបថ និងមាគ៌ាជីវិតរបស់គេបាន ។ ការលើកឡើងនូវបញ្ហានានានៃបរិស្ថាន ដែលមានចោទឡើង ជួនកាលមានជួបនឹងឧបសគ្គផងដែរ ជាពិសេស នៅពេលណាដែលយើងមានលទ្ធភាពតែបន្តិចបន្តួច ក្នុងការទប់ស្កាត់ការបំផ្លិចបំផ្លាញបរិស្ថាន ដែលបង្កឡើងដោយរាជ្ញាធរ ឬក្រុមហ៊ុន



www.elibraryofcambodia.org

បរទេសនោះ ។ ទោះជាយ៉ាងណាក៏ដោយ មនុស្សដែលប្រកបដោយគតិបណ្ឌិត មុខតែនឹងស្លាប់ ហើយនឹងយល់ពីបញ្ហានេះជាមិនខាន ។ បើកាលណាមានមនុស្សចេះដឹងកាន់តែច្រើន យើងក៏មានឱកាសកាន់តែច្រើន ក្នុងការការពារ និងទប់ស្កាត់ការបំផ្លិចបំផ្លាញបរិស្ថាននាពេលអនាគតដែរ ។

## សំណួរពិភាក្សា

*១. បើតាមយោបល់ព្រះតេជព្រះគុណ-លោកអ្នក នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក តើអ្នកណា ដែលអ្នកគិតថា អាចងាយជ្រួតជ្រាប ចាប់យកការអប់រំបរិស្ថាន ? ហើយតើមានក្រុមមនុស្សណាខ្លះ ដែលអ្នកគិតថាមានលក្ខណៈសម្បត្តិល្អបំផុត ក្នុងការទទួលយកការអប់រំបរិស្ថាននេះបាន ?*

*២. តើអ្នកគិតថា មានហេតុផលអ្វីខ្លះដែលធ្វើឱ្យមនុស្សស្ម័គ្រចិត្តរៀន ? ហើយមានហេតុផលអ្វីខ្លះ ដែលធ្វើឱ្យមនុស្សមិនចង់រៀន ?*

*៣. ជានិមិត្តរូបនៃភាពបរិសុទ្ធ តើផ្លាលោកអាចជំរុញឱ្យមានការសិក្សាបរិស្ថានបានយ៉ាងដូចម្ដេច ? ឧទាហរណ៍ ភាពបរិសុទ្ធនៃគំនិត (ភាពបរិសុទ្ធខាងក្នុង) នឹកនាំឱ្យដល់ដំណើរការសិក្សា សំរាប់ភាពបរិសុទ្ធនៃបរិស្ថាន (ភាពបរិសុទ្ធខាងក្រៅ) ។*



www.elibraryofcambodia.org

១ក. ឈូក និងការអប់រំបរិស្ថាន



www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន ១ ខ**

# គតិបណ្ឌិតបរិស្ថាន

**សុត្តនិបាត** គឺជាឯកសារដើមមួយរបស់ព្រះពុទ្ធសាសនា ដែលនិយាយអំពីតម្លៃនៃការស្គាល់ធម្មជាតិ ។ ព្រះពុទ្ធទ្រង់មានពុទ្ធដីកាយ៉ាងដូច្នេះថា :

*" អ្នកស្គាល់តិណជាតិ វល្លិជាតិ រុក្ខជាតិ រួចហើយអ្នកស្គាល់សត្វល្អិតគ្រប់ប្រភេទ ដូចជា ដង្កូវ ពពួកសត្វមមាច ស្រមោចជាដើម ..... ។ អ្នកក៏ស្គាល់ពពួកសត្វចតុបាទទាំងធំទាំងតូច និងអបាទកសត្វមាន ពស់ ត្រី ដែលហែលហែលសប្បាយនៅក្នុងទឹក សត្វបក្សាបក្សីដែលមានស្លាប ហើយអាចហោះហើរនៅលើអាកាសបាន..... ។ អ្នកអាចដឹងលក្ខណៈសំគាល់របស់ពូជសត្វគ្រប់ប្រភេទ ហើយពូជរបស់វាមានលក្ខណៈផ្សេងៗគ្នាទៀតផង "* ។

គោលដៅចំបងនៃការអប់រំបរិស្ថាន គឺដើម្បីឱ្យប្រជាពលរដ្ឋយល់ និងឱ្យតម្លៃចំពោះមជ្ឈដ្ឋានជុំវិញខ្លួនដែលពួកគេរស់នៅ ព្រមទាំងបញ្ហាបរិស្ថាននានា ដែលមានចោទឡើងទៀតផង ។ កង្វះខាតនៃការយល់ដឹងអំពីបរិស្ថាន គឺជាកត្តាចំបងមួយ ដែលរួមចំណែកបង្កឱ្យមានការបំពុល និងការបំផ្លិចបំផ្លាញបរិស្ថាន ។ ដរាបណាប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្រើន អំពីហេតុផលនៃការធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ដរាបនោះ គេនឹងមានទឹកចិត្ត និងការប្ដេជ្ញាចិត្តខ្ពស់ ដើម្បីឆ្លើយតបទៅតាមដំណោះស្រាយបញ្ហាមួយ ដែលមានលក្ខណៈជាវិជ្ជមាន ។ តាមការយល់ដឹងអំពីដំណើររបស់ធម្មជាតិមានដូចជា របបទឹកភ្លៀង ប្រភេទដី និងផលប្រយោជន៍នៃរុក្ខជាតិ និងដើមឈើនោះ កសិករអាចទទួលផលមកវិញបានកាន់តែល្អប្រសើរពីសកម្មភាព ឬរបរកសិកម្មរបស់ខ្លួន ។

តាមធម្មតា យើងអាចរៀនសូត្របានយ៉ាងច្រើនពីសហគមន៍ទាំងឡាយណា ដែលនៅតែបន្តការរស់នៅ ដោយមានការរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយនឹងបរិស្ថានរបស់គេ ។ ប្រជាពលរដ្ឋរស់នៅតាមសហគមន៍ជនបទនៃប្រទេសកម្ពុជា បានទទួលចំណេះដឹងជាបន្តបន្ទាប់យ៉ាងច្រើន អំពីបរិស្ថាននៅក្នុងមូលដ្ឋានផ្ទាល់របស់ពួកគេ ដើម្បីអាចឱ្យពួកគេរស់រានមានជីវិត និងរស់នៅប្រកបដោយភាពសុខដុមរមនាជាមួយនឹងបរិស្ថានធម្មជាតិ និងវប្បធម៌ ។ ចំណេះដឹងរបស់ពួកគេរួមមានការដឹងថា ទីកន្លែងណាដែលមានធនធានពេលណាទើបគេអាចប្រមូលធនធានទាំងនោះបាន ហើយនិងក្នុងកម្រិត ឬទំហំប៉ុណ្ណា ដែលគេអាចយកធនធាន



www.elibraryofcambodia.org

និមួយៗមកប្រើប្រាស់បាន ។ ម្យ៉ាងទៀត ពួកគេក៏អាចស្គាល់បានទៀតថា រុក្ខជាតិ ឬឈើប្រភេទណាខ្លះដែលអាចយកមកធ្វើជាអាហារ ហើយប្រភេទមួយណាអាចយកមកធ្វើជាឱសថ ឬក៏ប្រើប្រាស់ក្នុងផ្នែកសិប្បកម្មបានជាដើម ។ ចំណេះដឹងបរិស្ថានទាំងនេះ គឺទទួលបានពីការដកពិសោធ និងការសង្កេតពិនិត្យពិច័យ អស់ជាច្រើនជំនាន់មកហើយ ។ ចំណេះដឹងវៀនសូត្រដោយផ្ទាល់ នៅក្នុងមូលដ្ឋានទាំងនេះហើយដែលបានបង្កើតបានជាគតិបណ្ឌិតបរិស្ថាននោះ ។ ជាការសំខាន់ គឺការស្វះស្វែងរកគតិបណ្ឌិតនេះឯង ដែលជាវិធី ឬជាមធ្យោបាយមួយនៃការដោះស្រាយសង្កាធ ដែលសង្កត់ទម្ងន់មកលើបរិស្ថាន បង្កឡើងដោយសារការអភិវឌ្ឍតាមបែបសម័យទំនើបនោះ ។

## សំណួរពិភាក្សា

*១. តើអ្វីខ្លះ ដែលព្រះតេជព្រះគុណ-លោកអ្នក គិតថាជាលក្ខណៈចម្បងនៃបរិស្ថាន ក្នុងមូលដ្ឋានជុំវិញខ្លួនព្រះអង្គ ? មានរុក្ខជាតិដើមឈើ និងសត្វចំនួនប៉ុន្មាន ? ហើយតើព្រះតេជព្រះគុណ-លោកអ្នកអាចស្គាល់ នឹងប្រាប់ឈ្មោះរុក្ខជាតិដើមឈើ និងសត្វទាំងនោះបានទេ ?*

*២. ចូរពិគ្រោះជាមួយចាស់ទុំ នៅក្នុងសហគមន៍របស់ព្រះតេជគុណ-លោកអ្នក ដែលគាត់អាចស្គាល់បន្លែរុក្ខជាតិ និងសត្វ ដែលព្រះតេជគុណ-លោកអ្នក មិនស្គាល់ ។*

*៣. ចូរពិភាក្សារកវិធីនានា ដែលសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នកអាចជួយសិស្សសាលា ឱ្យបានយល់ជ្រៅពីបរិស្ថាន នៅជុំវិញខ្លួនរបស់ពួកគេ ។*



www.elibraryofcambodia.org



១២. គតិបណ្ឌិតបរិស្ថាន

www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន ១ គ**

# សត្វទទា ស្វា និង ដំរី

កាលដើមឡើយ មានជ្រៃមួយដើមធំ ដុះនៅទីជំរាលនៃភ្នំហេមពាន្ត ។ នៅក្បែរដើមជ្រៃនោះ មានសត្វបីដែលជាមិត្តសំឡាញ់នឹងគ្នាគឺ សត្វទទា ស្វា និងដំរី បានស្នាក់អាស្រ័យ និងរស់នៅរួមជាមួយគ្នា ។ ពួកគេរស់នៅដោយប្រកាន់ខ្ជាប់ភាពគួរសមរវាងគ្នា ស្លូតបូត និងគោរពគ្នាជានិច្ច ។ នាថ្ងៃមួយ ពួកគេបានសំរេចចិត្តសួរគ្នាថា : មានអ្នកណាមួយ ដែលមានវ័យចំណាស់ជាងគេ នៅក្នុងចំណោមពួកយើងទាំងអស់គ្នានេះ ។ ដំរីនៅចាំបាន និងដំណាលថា : កាលពីយើងនៅក្មេង កំពស់ខ្ពស់បំផុតនៃគ្រួយជ្រៃនេះ គឺត្រឹមពោះរបស់ខ្ញុំប៉ុណ្ណោះ ។ ឯស្វាវិញនៅចាំបានថា : កាលពីខ្ញុំនៅតូច ខ្ញុំធ្លាប់បានអង្គុយស៊ីគ្រួយជ្រៃ ដែលនៅទីខ្ពស់បំផុតនេះ ដោយមិនចាំបាច់ហើបខ្លួនពីដីឡើយ ។ ចំណែកឯទទាវិញនៅចាំបានថា : មានថ្ងៃមួយ ខ្ញុំបានពាំផ្លែជ្រៃពីដើមជ្រៃធំមួយ ដុះនៅកន្លែងផ្សេងយកមកស៊ី ហើយបានបន្ទោបង់ចោលនៅទីវាលនេះ ហើយពេលក្រោយមក វាក៏ដុះបានជាដើមជ្រៃនេះ និងលូតលាស់ធំរហូតមកដល់សព្វថ្ងៃ ។ ដូច្នេះទទា គឺជាសត្វដែលមានវ័យចំណាស់ជាងគេ ហើយបន្ទាប់ពីនោះមក ស្វា និងដំរី ក៏មានការគោរព និងផ្តល់កិត្តិយស ព្រមទាំងស្តាប់បង្គាប់ពាក្យដំបូន្មាន ប្រៀនប្រដៅរបស់សត្វទទាជារៀងរហូតមក ។ តាមដំបូន្មានរបស់សត្វទទា ពួកគេទាំង ៣ រូបបានប្រកាន់ខ្ជាប់នូវសីលប្រាំ ហើយរស់នៅជាមួយគ្នា ដោយការគួរសម និងការគោរពគ្នាទៅវិញទៅមកជានិច្ច ។ លុះសត្វទាំង ៣ នេះ លាចាកលោកនេះទៅ ពួកគេក៏បានចាប់កំណើតជាថ្មី នៅឯឋានសួគ៌ទាំងអស់គ្នាហោង ( **គម្ពីរតិត្តិរជាតក** ) ។

រឿងនេះ ព្រះពុទ្ធជាអម្ចាស់ ទ្រង់បាននិទានលើកជាឧទាហរណ៍ សំរាប់ប្រៀនប្រដៅដល់ភិក្ខុសង្ឃសាវ័កទាំងឡាយ ដែលគង់នៅក្នុងទីអាវាសសហគមន៍ ឱ្យមានការគោរព ចំពោះភិក្ខុចាស់វស្សាជាង ដែលប្រកបដោយសីលធម៌ ចរិយាធម៌ និងសមភាព ។ រឿងនេះ ក៏ជាគតិមួយ សំរាប់រំលឹកដាស់តឿន ឱ្យដឹងថាការរស់នៅក្នុងសហគមន៍ តែងមានបទពិសោធន៍ ឬមេរៀនផ្សេងៗគ្នា ពីជំនាន់មួយទៅជំនាន់មួយ ក្នុងការទាក់ទងជាមួយសហគមន៍នោះ ។ ដូច្នេះ សមាជិកទាំងអស់ក្នុងសហគមន៍ អាចរួមចំណែកផ្តល់វិភាគទានជាចំណេះដឹងរបស់ខ្លួន ដើម្បីបានជាប្រភពធនធានមួយ សំរាប់ផ្តល់ផលប្រយោជន៍ ចំពោះសហគមន៍ទាំងមូល ។ ជាឧទាហរណ៍ នៅក្នុងសហគមន៍មួយ អ្នកដែលមានវ័យចំណាស់ជាងគេ តែងមានចំណេះដឹងច្រើនអំពីបរិស្ថាន និងមរតកវប្បធម៌នៅក្នុងមូលដ្ឋានរបស់ខ្លួន ដែលចាត់ជាទ្រព្យសម្បត្តិដ៏សំខាន់បំផុតមួយ មិន



www.elibraryofcambodia.org

អាចកាត់ថ្លៃបាន ។ ចំណេះដឹងបែបនេះ គេអាចផ្ទេរទៅឱ្យក្មេងជំនាន់ក្រោយៗ ដែលរស់នៅក្នុងសហគមន៍ជាមួយគ្នា ។ ពួកគេទាំងនេះ អាចរួមចំណែកក្នុងការគ្រប់គ្រងធនធានធម្មជាតិរបស់សហគមន៍នោះ ប្រកបដោយគតិបណ្ឌិត ព្រមទាំងអាចពង្រឹងប្រព័ន្ធវារិ និងអត្ថន័យរបស់មូលដ្ឋាននោះបានទៀតផង ។

## សំណួរពិភាក្សា

*១. តើមានអ្នកណាខ្លះជាសមាជិក ដែលមានវ័យចំណាស់ នៅក្នុងសហគមន៍ របស់ព្រះតេជព្រះគុណ-លោកអ្នក ? តើមានអ្នកណាខ្លះជាសមាជិក ដែលមានវ័យក្មេង នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ? តើព្រះតេជព្រះគុណ-លោកអ្នកយល់ថា ចំណេះដឹង និងបទពិសោធន៍របស់ពួកគេទាំងពីរវ័យ អំពីបរិស្ថានក្នុងមូលដ្ឋាន មានលក្ខណៈខុសគ្នាយ៉ាងណា ?*

*២. តើពួកចាស់ៗកំពុងផ្ទេរចំណេះដឹងជាប្រពៃណីមក ទៅឱ្យក្មេងៗជំនាន់ក្រោយបានប៉ុន្មាន ?*

*៣. តើវត្តអាចបំពេញជាអ្នកផ្សព្វផ្សាយចំណេះដឹង និងគតិបណ្ឌិតក្នុងមូលដ្ឋានបានយ៉ាងដូចម្តេច ?*



www.elibraryofcambodia.org



១៩. សត្វទទា ស្វា និងដំរី

www.elibraryofcambodia.org

www.elibraryofcambodia.org

# សកម្មភាព

## ការស្វែងយល់អំពីបរិស្ថាននៅក្នុងមូលដ្ឋាន

១. **វត្ថុបំណង** : ដើម្បីអង្កេតស្រាវជ្រាវ និងធ្វើឱ្យក្រុមអ្នកសិក្សាបានស្គាល់ និងយល់ដឹងអំពីបរិស្ថានក្នុងមូលដ្ឋានរបស់អ្នកផ្ទាល់ និងដើម្បីកំណត់រកមនុស្ស ដែលស្គាល់ធនធានមាននៅក្នុងសហគមន៍ច្បាស់ ។

២. **សកម្មភាព** :

❶ បែងចែកអ្នកសិក្សាជាក្រុមតូចៗ ។

❷ ក្រុមនីមួយៗត្រូវប្រមូល ឬរកឱ្យបានផលិតផលធម្មជាតិចំនួន ៦ មុខ ដែលគេអាចរកបាននៅក្នុងបរិស្ថានក្នុងមូលដ្ឋាន ជាឧទាហរណ៍មានដូចជា ស្លឹកឈើជ្រុះ គ្រាប់ពូជ ផ្លែឈើ មែកឈើតូចៗ និងលាមកសត្វជាដើម ។

❸ ឱ្យក្រុមនីមួយៗធ្វើការពិភាក្សាលើវត្ថុទាំង ៦ មុខ ដែលរកបានហើយនោះ ដោយត្រូវកំណត់ពេលវេលាជាក់លាក់ ដើម្បីពិភាក្សាផង ។

❹ ចូរធ្វើការសង្កេតពិនិត្យឱ្យឃើញថា ពួកគេស្គាល់របស់ទាំងនោះដល់កំរិតណា ដូចជាថា ដើមឈើអ្វី ? រុក្ខជាតិអ្វី ? សត្វអ្វី ? បានមកពីណា ? ជាដើម ហើយថាតើរបស់ទាំងនោះមានជាទូទៅហើយងាយរកបានក្នុងតំបន់នោះឬទេ ? តើគេប្រើរបស់នោះសំរាប់ធ្វើអ្វីខ្លះ ? (ជាឧទាហរណ៍សំរាប់បរិភោគ ធ្វើថ្នាំសង្កូវជាដើម) ។

❺ បើមានពេល ចូរឱ្យក្រុមនិមួយៗធ្វើការផ្លាស់ប្តូរទីតាំងពីកន្លែងមួយទៅកាន់ទីកន្លែងមួយទៀត រហូតដល់ក្រុមនីមួយៗ បានពិភាក្សាអំពីរបស់ទាំងអស់ ដែលក្រុមដទៃរកបាន ។

❻ ចូរពិភាក្សាពីលទ្ធផលរបស់ក្រុមនីមួយៗ នៅក្នុងក្រុមធំ ។

❼ តើមាននរណាដឹងច្រើនជាងគេ ?



www.elibraryofcambodia.org

❽ ចូរពិភាក្សាថា តើអ្នកបានដឹងពត៌មានអំពីផលិតផលធម្មជាតិទាំងនោះ ពីណាមក ដូចជាពី :

- ➢ ការសង្កេតពិនិត្យ
- ➢ ឪពុកម្តាយ
- ➢ ទូរទស្សន៍ វិទ្យុ កាសែត
- ➢ មិត្តភក្តិ
- ➢ ព្រះសង្ឃ/ដូនជី
- ➢ គ្រូបង្រៀន
- ➢ សៀវភៅ
- ➢ ផ្សេងៗ ។

### ៣. សកម្មភាពអនុវត្តបន្ត :

❶ *បិទភ្ជាប់ផលិតផលធម្មជាតិ ដែលរកបាននៅលើក្រដាសធំមួយសន្លឹក ឬបិទលើជញ្ជាំងស្អាត ។*

❷ *បិទពត៌មានដែលអ្នកបានប្រមូល សំរាប់វត្ថុនីមួយៗ ។*

❸ *បន្ថែមពត៌មានផ្សេងៗទៀតនៅពេលដែលអ្នករកឃើញ និងបន្ថែមរបស់ថ្មីៗ ដែលគួរចាប់អារម្មណ៍ ។*

❹ *សាកសួរសមាជិកដទៃទៀតក្នុងសហគមន៍ ដើម្បីសុំពត៌មានអំពីអ្វីដែលអ្នកបានរកឃើញ ។*

## គុណភាពបរិស្ថាន គឺជាតម្រូវការនៃ

## មនុស្ស សត្វ និង រុក្ខជាតិ



www.elibraryofcambodia.org

# ជំពូកទី ២

# បរិស្ថានល្អ ជា
# មាគ៌ាជីវិតនៃពុទ្ធសាសនិកជន


មេរៀន ២ក : ព្រះធម៌ និង បរិស្ថាន

មេរៀន ២ខ : ធម្មយាត្រា

មេរៀន ២គ : ការអភិវឌ្ឍសហគមន៍តាមរយៈវត្តអារាម

មេរៀន ២ឃ : វត្តអារាម

មេរៀន ២ង : ការវិវត្តនៃបុរេកាល និងមាគ៌ាព្រះពុទ្ធសាសនា

មេរៀន ២ច : ការយល់ដឹងបរិស្ថានតាមរយៈភាសាបាលី

មេរៀន ២ឆ : និមិត្តរូបនៃផ្កាឈូក

មេរៀន ២ជ : ការបំបួសដើមឈើ

*សកម្មភាព : បរិស្ថានល្អ ជាមាគ៌ាជីវិតរបស់ពុទ្ធសាសនិកជន*


www.elibraryofcambodia.org

www.elibraryofcambodia.org

មេរៀន ២ ក

# ព្រះធម៌ និង បរិស្ថាន

**ព្រះធម៌** ដ៏ចំបងដែលព្រះពុទ្ធជាម្ចាស់ ទ្រង់លើកយកមកប្រៀនប្រដៅ ដល់ពុទ្ធសាសនិកជនអំពីច្បាប់សីលធម៌នៃធម្មជាតិនោះ មានមូលដ្ឋានលើ **អរិយសច្ចៈ** ទាំង ៤ គឺ :

១. **ទុក្ខសច្ចៈ** គឺការឈឺចាប់ ឬទុក្ខ ដែលជាហេតុការណ៍ដ៏សំខាន់បំផុតនៃជីវិត

២. **សមុទយសច្ចៈ** គឺការយល់មូលហេតុពិតនៃសេចក្តីទុក្ខ

៣. **និរោធសច្ចៈ** គឺការយល់ដឹងអំពីការរំលត់ទុក្ខ

៤. **មគ្គសច្ចៈ** គឺស្គាល់វិធីកំណត់ទុក្ខ ដោយការប្រតិបត្តិតាមផ្លូវ **មជ្ឈិមបដិបទា** ឬផ្លូវកណ្តាលនៃធម្មចរិយា (*ការរក្សាសីល*) ការតាំងជាសមាធិ និងការប្រកាន់ខ្ជាប់នូវបញ្ញា (*បញ្ញា*) ។

ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ទ្រង់ប្រៀនប្រដៅថា លោភៈ ទោសៈ និង មោហៈ ជាមូលដ្ឋាននៃសេចក្តីទុក្ខ និងបញ្ហាទាំងអស់របស់យើង ។ ការយល់ដឹងនេះ ធ្វើឱ្យមានឡើងនូវការយល់ថា មនុស្សទាំងឡាយត្រូវតែមានការទទួលខុសត្រូវដោយខ្លួនឯង ពុំមែនមានត្រឹមតែពីប្រទេសមួយទៅប្រទេសមួយ និងពីមនុស្សម្នាក់ទៅម្នាក់ទៀតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពីមនុស្ស រហូតដល់រាល់ភាវៈមានជីវិតដទៃទៀតផងដែរ ។ ព្រះធម៌បានអះអាងថា ពុំមានភាវៈអ្វីមួយអាចមានអត្ថិភាព ឬរស់នៅដោយឯកឯងបានឡើយ ហើយថា រាល់ភាវៈមានជីវិតទាំងអស់ ត្រូវទាក់ទងគ្នា និងពឹងផ្អែកគ្នាទៅវិញទៅមក ដើម្បីរស់រានមានជីវិត និងសេចក្តីចំរុងចំរើន ។ មនុស្សជាតិត្រូវតែយល់ថា ជាផ្នែកមួយនៃបរិស្ថានដែរ ។ ព្រោះថា កាលណាបរិស្ថានទទួលរងគ្រោះថ្នាក់តាមវិធីណាមួយក៏ដោយ មនុស្សក៏ត្រូវទទួលគ្រោះថ្នាក់ ឬរងទុក្ខទោសដែរ ។

សិក្ខាបទទាំងប្រាំរបស់ព្រះពុទ្ធសាសនា ឬ **បញ្ចសីល** ជាសេចក្តីត្រូវការចាំបាច់អប្បបរមា សំរាប់ឱ្យមានជីវិតមារយាទល្អជាប្រចាំ ព្រោះសិក្ខាបទទាំងនេះទូន្មានមនុស្សមិនឱ្យសំលាប់សត្វ មិនឱ្យលួចទ្រព្យគេ ការវៀរចាកកាមរាគ ឬមិនរំលោភប្រពន្ធកូនគេ ការមិនកុហកគេ និងការមិនសេពគ្រឿងស្រវឹង ។ ម្យ៉ាងទៀត គេក៏បានបកស្រាយបញ្ចសីលនេះ ជាន័យវិជ្ជមានបានដែរថា *មេត្តា ករុណា សប្បុរសធម៌ និងសេចក្តីទៀងត្រង់ កម្លាំងពលំនិងភាពទទួលខុសត្រូវ សច្ចធម៌និងការប្រាស្រ័យទាក់ទងគ្នា សុខភាពនិងការយកចិត្តទុកដាក់ស្តាប់បង្គាប់* ។



www.elibraryofcambodia.org

តាមរយៈការប្រតិបត្តិតាមព្រះធម៌ជាទូទៅ និងតាមបញ្ចសីលជាពិសេសនោះ ពុទ្ធសាសនិកជនអាចចូលរួមវិភាគទាន ក្នុងការបង្កើតឥរិយាបថទទួលខុសត្រូវ និងការយកចិត្តទុកដាក់ស្តាប់ នៅពេលណាដែលមនុស្សយល់បានថា ការលួចប្លន់បរិស្ថាន ជាពិសេសធនធានធម្មជាតិ ដើម្បីផលប្រយោជន៍ប្រើប្រាស់តែខ្លួនឯង (*មហិច្ឆតា*) គឺធ្វើឱ្យអ្នកដទៃ និងប្រទេសជាតិទាំងមូល ទទួលរងនូវហាយនភាព ឬការបំផ្លិចបំផ្លាញទៅវិញទេ ។ ថែរក្សាធម្មជាតិ មានន័យថា ជាការថែរក្សាអ្វីៗទាំងអស់ ដែលមាននៅក្នុងលោកយើងនេះ ហើយក៏ពុំមែនដោយសារតែវាមានប្រយោជន៍ ឬក៏ព្រោះតែយើងស្រឡាញ់ចូលចិត្តវាអញ្ចឹង តែម្យ៉ាងនោះទេ ។

## សំណួរពិភាក្សា

*១. ចូរពិភាក្សាអំពីសិក្ខាបទនីមួយៗ ក្នុងចំណោមសិក្ខាបទទាំង ៥ និងវិធីដែលគេអាចបកស្រាយបានជាជំហានវិជ្ជមាន ឆ្ពោះទៅការថែរក្សានិង ការពារបរិស្ថាន ។*

*២. ចូរជ្រើសរើសយកបញ្ហាបរិស្ថានណាមួយ ដែលកំពុងមានចោទឡើងនៅប្រទេសកម្ពុជា ឬក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក - ចូរពិភាក្សាបញ្ហាដែលជ្រើសរើសនោះទៅតាមគន្លងផ្លូវព្រះធម៌ :*

*① តើមានទុក្ខអ្វីខ្លះ កើតឡើងពីបញ្ហានោះ ?*

*② តើអ្វីខ្លះ ជាហេតុនៃបញ្ហា និងទុក្ខដែលកើតមានឡើង ?*

*③ តើគេអាចដោះស្រាយបានបញ្ហាតាមរបៀបយ៉ាងដូចម្តេច ?*

*④ តើមានជំហានអនុវត្តជាក់ស្តែងអ្វីខ្លះ ដែលគេអាចប្រកាន់យក ដើម្បីពុះពារជំនះលើបញ្ហា និងទុក្ខទាំងនោះបាន ?*



www.elibraryofcambodia.org

២ក. ព្រះធម៌ និងបរិស្ថាន









www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន ២១**

# ធម្មយាត្រា

ធម្មយាត្រា ដែលមានន័យថា "*ការត្រាច់ចរដើម្បីស្វែងរកសច្ចភាព*" ជាដំណើរដោយថ្មើរជើងមួយ ដែលមានប្រពៃណីដ៏មានចំណាស់មកហើយ របស់ពុទ្ធសាសនិកជននៅក្នុងប្រទេសកម្ពុជា ។ ផ្ដើមគំនិតឡើងដោយមជ្ឈមណ្ឌលធម្មយាត្រានោះ ដំណើររបស់ពុទ្ធសាសនិកជនទាំងនេះ ធ្វើឡើងដើម្បីស្វែងរកសន្តិភាព និងការបង្រួបបង្រួមជាតិ ដែលសបញ្ជាក់ឱ្យឃើញថា ព្រះពុទ្ធសាសនា មានតួនាទីយ៉ាងសំខាន់ នៅក្នុងដំណើរការអភិវឌ្ឍនៅប្រទេសកម្ពុជា ។ សកម្មភាពទាំងឡាយរបស់ភិក្ខុសង្ឃ និងដូនជី ដែលចូលរួមនៅក្នុងក្បួនធម្មយាត្រា បានផ្ដល់តួនាទីជាវិជ្ជមានធ្វើជាគំរូគេ ឱ្យដល់សហគមន៍ទាំងឡាយ នៅទូទាំងប្រទេស ។ ក្បួនធម្មយាត្រា បានបង្ហាញឱ្យឃើញ ពីវិធីដែលព្រះភិក្ខុសង្ឃ និងដូនជី អាចធ្វើការតាមផ្លូវអហិង្សា ដើម្បីជួយដល់ប្រជាពលរដ្ឋទាំងឡាយ ដែលរងទុក្ខវេទនា ។

នៅក្នុងក្បួនដំណើរធម្មយាត្រា ដែលធ្វើពីខេត្តសៀមរាបឆ្ពោះទៅកាន់ទីក្រុងភ្នំពេញ មុនពេលបោះឆ្នោតជាតិ កាលពីខែ ឧសភា ឆ្នាំ ១៩៩៣ កន្លងមក សមាជិកចូលរួមក្នុងដំណើរធម្មយាត្រា បានភ្ញាក់ស្មារតី និងយល់ដឹងយ៉ាងច្បាស់លាស់អំពីការបំផ្លិចបំផ្លាញបរិស្ថាន ដែលបណ្ដាលឡើងដោយការកាប់ឈើដ៏ច្រើនហួសហេតុពេក ។ ជាការឆ្លើយតប ពួកគេបានដាំដើមឈើឡើងវិញ នៅក្នុងវត្តអារាមតាមបណ្ដោយផ្លូវជាតិ ។ មានក្បួនធម្មយាត្រាប្រចាំឆ្នាំជាច្រើនលើក បានធ្វើឡើងចាប់ពីឆ្នាំ ១៩៩២ មក ហើយការដាំដើមឈើបានក្លាយទៅជាលក្ខណៈសំគាល់ទូទៅមួយ នៃការធ្វើធម្មយាត្រានិមួយៗនេះ ។ កូនពោធិព្រឹក្សជាច្រើន ដែលជាអំណោយពីប្រទេសស្រីលង្កា ត្រូវបានគេយកមកដាំ នៅក្នុងរយៈពេលនៃការធ្វើធម្មយាត្រានាឆ្នាំ ១៩៩២ ។ ក្បួនធម្មយាត្រា ដែលគ្រាន់តែជាសកម្មភាពដ៏សាមញ្ញមួយនៃការដើរ ការស្ដាប់ ការប្រោះព្រំទឹក និងការបញ្ជូនសារ ឬសញ្ញាស្ដីពីសន្តិភាព និងការបង្រួបបង្រួមជាតិនោះ បាននាំនាំមកនូវសេចក្ដីសង្ឃឹម និងការជំរុញទឹកចិត្តឱ្យដល់សហគមន៍ទាំងឡាយ ដែលក្បួនបានឆ្លងកាត់ ។ ការជំរុញទឹកចិត្ត និងការដឹកនាំក្បួនធម្មយាត្រានេះ បានកើតចេញមកពីសម្ដេច **ព្រះមហាឃោសានន្ទ** ដែលបានទូន្មានប្រៀនប្រដៅយ៉ាងដូច្នេះថា :

"*កាលណាយើងស្រឡាញ់ការពារបរិស្ថាន កាលនោះធម្មជាតិមុខតែ ល្អចំពោះយើងហើយ ។ ដើមឈើទាំងឡាយ ប្រៀបនឹងមាដូចជា*



www.elibraryofcambodia.org

មាតាបិតារបស់យើងដូច្នេះដែរ ។ ដើមឈើ ចិញ្ចឹមបីបាច់ថែរក្សា យើងឱ្យធំធាត់ ផ្គត់ផ្គង់ដល់យើងនូវវត្ថុគ្រប់បែបយ៉ាង មានដូចជា ផ្លែ ស្លឹក មែក ដើម ជាដើម ។ ឈើទាំងនោះផ្តល់ដល់យើងនូវម្ហូប អាហារ និងបំពេញបំណងប្រាថ្នារបស់យើងជាច្រើនទៀត ។ ប៉ុន្តែបើ យើងកាប់រំលំដើមឈើចោល វានឹងមិនមានភ្លៀងតទៅទៀតទេ ។ ដើមឈើ ធ្វើឱ្យមានភ្លៀងធ្លាក់ ។ អាស្រ័យហេតុនេះហើយ នៅ ក្នុងការធ្វើធម្មយាត្រានេះ យើងនឹងផ្សព្វផ្សាយព្រះធម៌អំពីការថែ រក្សាការពារខ្លួនយើង និងការថែរក្សា ការពារបរិស្ថានរបស់យើង ដែលនេះជាព្រះធម៌ របស់ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ នៃយើងទាំង អស់គ្នា "[៤] ។

## សំណួរពិភាក្សា

១. ក្រៅពីការដាំដើមឈើ តើព្រះតេជព្រះគុណ-លោកអ្នកគិតថា មានសកម្មភាពអ្វីខ្លះ ដើម្បីថែរក្សា ការពារ និងកែលំអបរិស្ថាន អាចត្រូវគេផ្តួចផ្តើមគំនិតឱ្យមាន នៅក្នុងការធ្វើធម្មយាត្រាម្តងៗ ?

២. តើព្រះភិក្ខុសង្ឃ ដូនជី និងអាចារ្យ អាចមានតួនាទីអ្វីខ្លះ នៅក្នុងវត្តអារាម ដើម្បីផ្សព្វផ្សាយពាក្យ ប្រៀនប្រដៅអំពីបរិស្ថាន ចំពោះអ្នកមកស្តាប់ដ៏ច្រើនកកកុញ នៅតាមផ្លូវធ្វើធម្មយាត្រានោះ ?

៣. តើការពិសោធន៍នៃធម្មយាត្រាម្តងៗ អាចផ្តល់គំនិតដល់មូលដ្ឋានរបស់ព្រះតេជព្រះគុណ-លោកអ្នក ដូចម្តេចខ្លះ ?

---

[៤] គ្រាប់ពូជសន្តិភាព ភាគ ១០ លេខ ៣ ។



www.elibraryofcambodia.org



២១. ធម្មយាត្រា

www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន**
**២ គ**

## ការអភិវឌ្ឍសហគមន៍តាមរយៈវត្តអារាម

ជាទូទៅ វត្តអារាមព្រះពុទ្ធសាសនា តែងតែតាំងទីស្ថិតនៅក្នុង ឬក្បែរភូមិ ហើយមានតួនាទីមិនគ្រាន់តែសំរាប់ប្រារព្ធធ្វើពិធីបុណ្យផ្នែកសាសនាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសំរាប់បំរើឱ្យជីវភាពផ្នែកសង្គម និងវប្បធម៌របស់ស្រុកភូមិថែមទៀតផង ។ ជាប្រពៃណីដ៏យូរលង់មកហើយ វត្តអារាមជាមជ្ឈមណ្ឌលសិក្សារបស់សហគមន៍មួយយ៉ាងសំខាន់ ទោះបីជាប្រពៃណីនេះ ត្រូវបានអាក់ខានអស់រយៈពេលប៉ុន្មានទសវត្សថ្មីៗនេះ ដោយសារការរំជើបរំជួលផ្នែកសង្គម និងនយោបាយ ព្រមទាំងការហូរចូលនូវវប្បធម៌របស់បស្ចិមប្រទេសយ៉ាងណាក៏ដោយ ។ ប៉ុន្តែសព្វថ្ងៃនេះ វត្តអារាមកំពុងចាប់ផ្តើមមុខមាត់ជាថ្មីម្តងទៀត ក្នុងការដើរតួនាទីជាមជ្ឈមណ្ឌលរបស់សហគមន៍ ហើយវត្តអារាមទាំងនេះ បាននិងកំពុងចាប់ផ្តើមដើរតួនាទីធ្វើជាគំរូ និងអប់រំគេក្នុងការជំរុញសកម្មភាពខ្លួនជួយខ្លួនឯង ដើម្បីកែលំអគុណភាពនៃជីវភាពរបស់សហគមន៍ ។ ផ្លូវថ្នល់ សាលារៀនថ្នាក់មត្តេយ្យ ក្រុមធនាគារ និងឥណទានជនបទ ធនាគារស្រូវ និងក្រុមល្ខោនសិល្បៈរបស់សហគមន៍ទាំងអស់ សុទ្ធតែបានបង្កើតឡើង ដោយអ្នកស្រុកមូលដ្ឋាន តាមរយៈសកម្មភាពអភិវឌ្ឍន៍សហគមន៍ ដឹកនាំដោយព្រះសង្ឃ ។ ការកែលំអគុណភាពនៃជីវិតនេះ មានរួមបញ្ចូលទាំងការថែរក្សាបរិស្ថានផងដែរ ។ សកម្មភាពអស់នេះ មានរាប់បញ្ចូលទាំងការអប់រំ យល់ដឹងអំពីបរិស្ថាន និងសកម្មភាពនានា ដើម្បីកែលំអបរិស្ថានក្នុង និងក្រៅវត្តទៀតផង ។

នៅបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ វត្តអារាមជាច្រើនរបស់ខ្មែរ កាន់តែក្លាយទៅជាមជ្ឈមណ្ឌលដ៏សកម្មក្នុងការបណ្តុះបណ្តាល និងធ្វើសិក្ខាសាលាគ្រប់រូបភាព ដែលមានទាក់ទិននៅក្នុងសហគមន៍មូលដ្ឋាន ។ ជាឧទាហរណ៍ ដូចជា *គំរោងជំនួយផ្នែកអប់រំរបស់ព្រះពុទ្ធសាសនាខ្មែរ* ហៅកាត់ជាភាសាអង់គ្លេសថា *ឃីព* (KEAP) ជាដើម ជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ នៅខេត្តបាត់ដំបង បានអនុវត្តកម្មវិធីបណ្តុះបណ្តាលព្រះពុទ្ធសាសនា និងការយល់ដឹងបរិស្ថាន នៅរវាងខែ មេសា និង កញ្ញា ឆ្នាំ ១៩៩៤ កន្លងមក[១០] ។ មានក្រុមការងារមួយ ដែលមានសមាជិកជាង ២០ រូប ជាព្រះភិក្ខុសង្ឃ អាចារ្យវត្ត គ្រូបង្រៀន និងមេដឹកនាំសហគមន៍ជាគ្រហស្ថ មកពីវត្តនានានៅក្នុងស្រុកទាំងបួននៃខេត្តបាត់ដំបង បានចូលរួម និងទទួលការបណ្តុះ

---

[១០] *ក្រសួងបរិស្ថាន : ស្ថានភាពបរិស្ថាននៅប្រទេសកម្ពុជា ១៩៩៤ ។ ភ្នំពេញ យូអិនឌីភី ១៩៩៥ ។*



www.elibraryofcambodia.org

បណ្តាលពិកម្មវិធីនេះ ។ គោលបំណងនៃគំរោងការនេះ គឺដើម្បីលើកតម្កើងសកម្មភាពនៃការសិក្សាតាមវត្តអារាម និងការអនុវត្តជាក់ស្តែង ស្តីពីការយល់ដឹងបរិស្ថាន ដែលជាមធ្យោបាយមួយសំរាប់ទាក់ទាញ និងប្រមូលផ្តុំប្រជាពលរដ្ឋនៅជុំវិញវត្តអារាម ឱ្យចូលរួមក្នុងសកម្មភាពការពារបរិស្ថានទាំងឡាយ ។ វង់ភ្លេងរបស់សហគមន៍នៅវត្តមួយ បានទទួលការបណ្តុះបណ្តាល និងដើរសំដែង នៅតាមវត្តអារាមដទៃទៀតជាច្រើន ដើម្បីអប់រំដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន អំពីភាពចាំបាច់នៃការការពារព្រៃឈើ និងថែរក្សាការពារបរិស្ថានឱ្យមានសុខភាពល្អ ។ ការដាំដើមឈើដ៏ទូលំទូលាយមួយបានប្រារព្ធធ្វើឡើងដោយសិក្ខាកាម និងប្រជាពលរដ្ឋ ក្នុងសហគមន៍វត្តនៅក្នុង និងក្រៅវត្តទាំង ៤ ស្រុក ដែលបានចូលរួមក្នុងសិក្ខាសាលានេះ ។

## សំណួរពិភាក្សា

*១. ចូរចាត់ឱ្យចាស់ព្រឹទ្ធាចារ្យណាម្នាក់ ក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ឱ្យពន្យល់អំពីសកម្មភាពអប់រំ ដែលវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក បានដឹកនាំធ្វើនៅក្នុងអតីតកាល ។ តើវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នកមានតួនាទីអ្វីខ្លះ នៅក្នុងការរៀបចំបង្កើតវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាសហគមន៍អំពីបញ្ហានៃការអភិវឌ្ឍ បញ្ហាវប្បធម៌ បញ្ហាបរិស្ថាន នៅក្នុងមូលដ្ឋានផ្ទាល់ ?*

*២. ចូរពិភាក្សារកគំនិតសំខាន់ៗ សំរាប់សកម្មភាពអប់រំបរិស្ថាន ដែលអាចបង្កើតឡើងនៅក្នុងវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក ។ ( ព្រះតេជព្រះគុណ-លោកអ្នកក៏អាចបន្ថែមគំនិតខ្លះៗទៀតក៏បាន កាលណាព្រះតេជព្រះគុណ-លោកអ្នក បានទទួលសៀវភៅនេះហើយ) ។*

## ខាងក្រោមនេះជាសំណួចខ្លះៗ ដើម្បីជាគំនិតសំរាប់ពិភាក្សា :

❶ ចូរធ្វើការជាមួយសិស្ស ឬសមណសិស្ស ដើម្បីរៀបចំកម្មវិធីដាំ និងថែទាំកូនឈើនៅក្នុងវត្ត ឬនៅក្នុងសាលា ។

❷ ចូរប្រារព្ធធ្វើវគ្គបណ្តុះបណ្តាល សម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន ស្តីអំពីបញ្ហាបរិស្ថានដែលកើតមាននៅក្នុងមូលដ្ឋាន ។

❸ ចូរធ្វើការសំដែងធម៌ទេសនាស្តីពីការរក្សាការពារ និងកែលំអបរិស្ថាននៅក្នុងមូលដ្ឋាន ។

❹ ចូរធ្វើការកោះប្រជុំក្រុមសិក្សាបរិស្ថាន សម្រាប់សហគមន៍នៅតាមមូលដ្ឋាន ។



www.elibraryofcambodia.org

២៥. ការកើតឡើងសហគមន៍តាមរយៈវត្តអារាម



www.elibraryofcambodia.org

www.elibraryofcambodia.org

មេរៀន
២ ឃ

# វត្តអារាម

ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ទ្រង់ប្រកាន់ថា ធម្មជាតិមានគុណភាពខាងសោភណភាព និងភាពស្ងប់ស្ងៀមបរិសុទ្ធ ដែលអាចបណ្តុះចិត្តគំនិត និងដឹកនាំទៅដល់ការធ្វើសមាធិភាវនាបាន ។ ព្រះបរមគ្រូជាអម្ចាស់ទ្រង់បានលើកទឹកចិត្ត ដល់អ្នកមានសទ្ធាជ្រះថ្លារបស់ព្រះអង្គ ឱ្យចេះសាងសង់វត្តអារាម នៅត្រង់ទីតាំងណាដែលប្រកបដោយទេសភាពធម្មជាតិ ។ មានវត្តមួយ នៅក្នុងចំណោមវត្តអារាមនានា នៅសម័យពុទ្ធកាលដែលត្រូវបានគេសាងថ្វាយ ចំពោះព្រះពុទ្ធគឺ **វត្តវេឡុវនារាម** ស្ថិតក្នុងក្រុង **រាជគ្រឹះ** រាជធានីនៃព្រះរាជាណាចក្រ **មគធរដ្ឋ** ក្នុងប្រទេសឥណ្ឌា ។ ឈ្មោះនៃវត្តនេះមានន័យថា "**វិហារព្រៃឫស្សី**" ដែលបានតាំងនៅក្នុងព្រៃឫស្សីមួយ ។ ពាក្យបាលីថា "**វិហារ**" សំដៅព្រះវិហារព្រះពុទ្ធសាសនា ដែលមានន័យថា "*កន្លែងល្ហល្ហេវ ឬកណ្តាលវាលតាំងនៅក្នុងព្រៃ*" ។

វត្តអារាមនៅប្រទេសកម្ពុជា ច្រើនតែសាងសង់ឡើង នៅតាមបណ្តោយមាត់ទន្លេ ឬស្ទឹង មានហ៊ុំព័ទ្ធទៅដោយព្រៃព្រឹក្សាលតាវល្លិ ឬក៏តាំងនៅលើកំពូលភ្នំ ដែលជាទីកន្លែងមានខ្យល់អាកាស ដី និងទឹក ដែលធ្វើឱ្យប្រសើរឡើង ដល់ការរស់នៅខាងផ្លូវចិត្ត ។ ជាទូទៅ គេបានជឿជាក់ ហើយបានប្រតិបត្តិមកហើយថា ដី ឬមាត់ច្រាំងទន្លេ ដែលជាកម្មសិទ្ធិរបស់វត្ត គឺជារបស់ **អភយទាន** ឬជាតំបន់ហាមឃាត់ ដែលនឹងក្លាយទៅជាបដិសរណដ្ឋានមួយ សំរាប់សត្វបក្សាបក្សីម្រឹគីម្រឹគាទាំងឡាយ ដែលរស់នៅទីនោះ។ អគារព្រះវិហារនិមួយៗ ជាធម្មតា មានហ៊ុំព័ទ្ធដោយរុក្ខជាតិ បុប្ផា ស្រះទឹក ព្រមទាំងដើមឈើ ដើម្បីបង្កើតឱ្យទៅជាឧទ្យានសន្តិភាព សម្រាប់ការធ្វើសមាធិ និងការសប្បាយរីករាយ ។ វត្តដូចដែលបានពោលមកខាងលើនេះ ឱ្យឈ្មោះថា **វត្តអារាម** ។

ប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ព្រះសង្ឃជាច្រើនអង្គ ក្នុងវត្តអារាមនៃប្រទេសកម្ពុជា បានដឹកនាំសកម្មភាពបណ្តុះ និងដាំដើមឈើ ក្នុងគោលបំណងបង្កើត ឬកែលំអវត្តអារាមឡើងវិញ ។ ប្រពៃណីខ្មែរខាងព្រះពុទ្ធសាសនា ចាប់តាំងពីរាជ្យព្រះករុណា **ព្រះបាទស៊ីសុវត្ថិ** (ឆ្នាំ ១៩០៤-១៩២៧) មកម្ល៉េះ គឺមានទម្លាប់បណ្តុះ ដាំដើមគគីរនៅក្នុងបរិវេណវត្ត ។ នៅប្រទេសថៃ ជាទូទៅវត្តទាំងឡាយនៅក្នុងព្រៃ មានតួនាទីសំខាន់ ក្នុងការថែរក្សាការពារតំបន់ធំៗ ដែលមានព្រៃនៅជុំវិញ ឬនៅក្បែរវត្ត ។ គេអាចធ្វើបានដូចគ្នាដែរ ចំពោះវត្តទាំងឡាយនៅប្រទេសកម្ពុជា ។ ដូចគ្នានេះដែរ ទីផ្សំបានជួយរក្សាបរិស្ថាន ទុកដូចជាការគោរព



www.elibraryofcambodia.org

ចំពោះបុព្វការីជននោះ បានលើកទឹកចិត្តដល់មនុស្សទាំងពួង មិនឱ្យបំផ្លិចបំផ្លាញសួន ឬព្រៃដែលនៅជុំវិញ ឡើយ ។

## សំណួរពិភាក្សា

១. ចូរពិភាក្សាអំពីបរិស្ថានមូលដ្ឋាន នៅខាងក្នុង ឬនៅជុំវិញវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក ដូចមានតទៅ:

① តើគេអាចកែលំអបរិស្ថានតាមរបៀបបែបណា ?

② តើមានសត្វបក្សាបក្សី ឬម្រឹគម្រឹគាអាស្រ័យនៅក្នុងវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នកដែរឬទេ ? បើមាន តើជាសត្វពួកណាខ្លះ ? សត្វទាំងនោះជាសត្វអាស្រ័យនៅជាអចិន្ត្រៃយ៍ ឬគ្រាន់តែមកស្នាក់នៅជាបណ្តោះអាសន្នប៉ុណ្ណោះ ? ប្រសិនបើមិនមានទេ តើយើងអាចធ្វើដូចម្តេចខ្លះ ដើម្បីទាក់ទាញសត្វទាំងនោះ ឱ្យមករស់នៅឡើងវិញ ?

២. តើមានសំណូមពរអ្វីខ្លះ ចំពោះព្រះគ្រូចៅអធិការវត្ត និងគណៈកម្មការវត្ត ដើម្បីធ្វើឱ្យវត្តព្រះតេជព្រះគុណ-លោកអ្នក មានបរិស្ថានរឹតតែសមរម្យល្អ សំរាប់មនុស្ស និងសត្វព្រៃទាំងឡាយ ឱ្យដូចន័យពិតជាវត្តអារាមនោះ ?



www.elibraryofcambodia.org



២៥. ចម្ការ

www.elibraryofcambodia.org

**មេរៀន ២១**

# ការវិវត្តនៃរដូវកាល និង មាគ៌ាព្រះពុទ្ធសាសនា

នៅក្នុងព្រះ **វិន័យបិដក** ភាគទី ១ ចែងថា ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ទ្រង់បានដាក់បញ្ញត្តិមិនឱ្យបព្វជិតធ្វើដំណើរក្នុងរដូវវស្សាឡើយ ម្យ៉ាងព្រោះថា នាំឱ្យមានរបួស ឬគ្រោះថ្នាក់ដល់សត្វល្អិត និងដង្កូវ ឬជន្លេន ដែលចេញមករកស៊ីនៅរដូវភ្លៀងនេះ ។ វិន័យបញ្ញត្តិនេះ បានដាស់តឿនក្រើនរំលឹកដល់ភិក្ខុសង្ឃឱ្យមានមេត្តា ករុណាធម៌ ចំពោះសត្វមានជីវិតទាំងអស់ ។ ព្រះសង្ឃបានប្រព្រឹត្តតាមវិន័យបញ្ញត្តិនេះ ជារៀងរហូតមកដល់សព្វថ្ងៃ ហើយនៅក្នុងរយៈពេលនៃរដូវភ្លៀងនេះ ភិក្ខុសង្ឃទាំងឡាយ តែងតែចូលកាន់ **ព្រះវស្សា** ដែលជាធម្មតាមានរយៈពេលបីខែ ជាទូទៅនៅរវាងខែកក្កដា ដល់ខែតុលា ដែលព្រះភិក្ខុសង្ឃចាំបាច់ត្រូវតែគង់នៅ ចាំព្រះវស្សាក្នុងទីវត្តអារាមប៉ុណ្ណោះ ។ នៅប្រទេសកម្ពុជា ប្រពៃណីនេះក៏បានធានាផងដែរថា សន្ទូងមិនត្រូវបានគេជាន់ឈ្លីឡើយ ។ នៅរវាងខាងចុងនៃការចូលវស្សា នឹងមានពិធីបុណ្យភ្ជុំបិណ្ឌ ដែលគេបានប្រារព្ធធ្វើឡើង អស់រយៈពេល ១៥ ថ្ងៃ ដើម្បីឧទ្ទិសមគ្គផលជូនដល់បុព្វការីជន ដែលបានចាកឋានលោកនេះទៅ ព្រមទាំងធ្វើ និងប្រគេនចង្ហាន់ភេសជ្ជៈដល់ព្រះសង្ឃក្នុងពេលនោះដែរ ។ នៅពេលចេញ **ព្រះវស្សា** ព្រះភិក្ខុសង្ឃមានឱកាសជាថ្មីម្តងទៀត ដើម្បីនិមន្តត្រាច់ចរបិណ្ឌបាតចង្ហាន់ នៅទីឆ្ងាយៗ និងធ្វើដំណើរទៅស្រុកកំណើតរបស់ខ្លួនបាន ដើម្បីសាកសួរសុខទុក្ខក្រុមគ្រួសារ ។

ការគោរពប្រតិបត្តិនៃជីវភាពជាបព្វជិតនេះ តែងតែឆ្លុះបញ្ចាំងឱ្យឃើញពីការវិវត្តនៃរដូវកាលរបស់ធម្មជាតិ និងកសិកម្ម ។ ពិធីបុណ្យព្រះពុទ្ធសាសនា ដូចជា **ថ្ងៃសីល** និងការធ្វើឧបោសថរបស់ព្រះសង្ឃក្នុងពេល ១៥ ថ្ងៃម្តង នៅក្នុងវត្តជាដើម គឺមានកើតឡើងទៅតាមប្រតិទិនចន្ទគតិ ។ ការគោរពប្រតិបត្តិទាំងនេះ និងមាគ៌ាជីវិតរបស់បព្វជិត តែងក្រើនរំលឹកដល់ពុទ្ធសាសនិកជនទាំងឡាយ ឱ្យយល់ច្បាស់អំពីទំនាក់ទំនងដ៏ជិតស្និទ្ធ រវាងព្រះពុទ្ធសាសនា ធម្មជាតិ និងបរិស្ថានទាំងមូល ។



www.elibraryofcambodia.org

## សំណួរពិភាក្សា

១. តើមានប្រពៃណី និងពិធីបុណ្យព្រះពុទ្ធសាសនាដទៃទៀតអ្វីខ្លះ ដែលបានឆ្លុះបញ្ចាំង ឱ្យឃើញពីការវិវត្តនៃរដូវកាលនៃធម្មជាតិ និងកសិកម្ម ?

២. ជារឿយៗ អត្ថន័យដើមរបស់ប្រពៃណី និងពិធីបុណ្យសាសនាទាំងឡាយ តែងត្រូវគេបំភ្លេចចោលគ្រប់ពេល ។ ចូរពិភាក្សាថា ធ្វើយ៉ាងណាឱ្យសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក បានយល់ដឹងឱ្យកាន់តែច្រើន អំពីពិធីបុណ្យទាំងឡាយ ដែលសហគមន៍នោះបានគោរពប្រតិបត្តិ ។ ចូរពិភាក្សាអំពីមាគ៌ាឬវិធី ដែលវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក អាចជួយឱ្យយល់ និងជំរុញឱ្យមានពិធីបុណ្យព្រះពុទ្ធសាសនា និងប្រពៃណីវប្បធម៌ដទៃផ្សេងទៀត ។



www.elibraryofcambodia.org

២១. ការវិវត្តនៃរដូវកាល និងអាគារព្រះពុទ្ធសាសនា



www.elibraryofcambodia.org

www.elibraryofcambodia.org

មេរៀន
២ ៥

# ការយល់ដឹងបរិស្ថានតាមរយៈភាសាបាលី

ភាសាបាលី ជាភាសាដ៏ចំណាស់ និងពិសិដ្ឋមួយរបស់ពុទ្ធសាសនាថេរវាទ អាចទៅជាឧបករណ៍ដ៏មានសារប្រយោជន៍មួយ ដើម្បីលើកឡើងពីស្មារតីយល់ដឹងខាងបរិស្ថាន ។ ពាក្យខ្មែរថា "**បរិស្ថាន** ឬ **បរិដ្ឋាន**" មានកំណើតមកពីពាក្យបាលី "**បរិត្ថះ**" មានន័យថា "*ការការពារ ការតាំការ*" ។ តំបន់ដែលយើងកំពុងរស់នៅ គឺអាស៊ីអាគ្នេយ៍ដីគោក រួមមានប្រទេស ភូមា ថៃ កម្ពុជា លាវ និងវៀតណាមនោះ មានឈ្មោះម្យ៉ាងទៀតថា **សុវណ្ណភូមិ** ឬ "*ទឹកដីមាស*" ក្នុងភាសាបាលី ។ ដើមឈើដែលមានវ័យចំណាស់ និងធ្វើសក្ការៈពីសំណាក់ពុទ្ធសាសនិកជន មានឈ្មោះថា "**វនប្បតិ**" ជាភាសាបាលីប្រែមកថា "*ឈើជាម្ចាស់នៃព្រៃ*" ។

ដូចគ្នានេះដែរ ឈ្មោះជាភាសាបាលីរបស់ខេត្ត និងស្រុកជាច្រើននៅប្រទេសកម្ពុជា បានធ្វើឱ្យយើងនឹកឃើញដល់លក្ខណៈពិសេសរបស់ធម្មជាតិ ឬវប្បធម៌នៃតំបន់ពិសេសៗទាំងនោះ ។ ទាំងអស់នេះអាចប្រើបានជាទីស្ថានអនុស្សាវរីយ៍ដ៏សមរម្យ សម្រាប់សារសំខាន់ខាងបរិស្ថាននៃកន្លែងទាំងនោះ ។ **រតនគិរី** មានន័យថា "*ពេជ្រ*" ឬ "*ភ្នំត្បូង*" ដែលរៀបរាប់អធិប្បាយយ៉ាងសមទំនង អំពីទេសភាពធម្មជាតិរបស់ខេត្តនេះ មានដូចជា ភាពសម្បូណ៌ស្រទាប់ព្រៃ ឬភ្នំធម្មជាតិដ៏ក្រាស់ បឹងកើតពីមាត់ភ្នំភ្លើង ត្បូងថ្ម និងរ៉ែ និងដីសម្បូណ៌ជីជាតិ ។ **មណ្ឌលគិរី** ជាពាក្យបាលី មានន័យថា "*ហ៊ុំព័ទ្ធដោយថ្ម ឬភ្នំ*" ។ ស្រុក **សម្បូណ៌** មកពីពាក្យបាលីថា **សម្ពុរះ** មានន័យថា "*ពេញប្រៀប ពោរពេញ*" ឬ "*ក្រាស់ក្រែលច្រើន*" ដែលមានទំនាក់ទំនងជាក់ស្តែងទៅនឹងធនធានធម្មជាតិ ដែលមានច្រើនក្រៃលែងនៅតំបន់នេះ មានដូចជា ព្រៃលិចទឹក បរិវេណសម្រាប់ត្រីពង បក្សាបក្សី ហើយនឹងត្រីផ្សោតទន្លេមេគង្គជាដើម ។ ឧទាហរណ៍មួយទៀតគឺខេត្ត **ពោធិ៍សាត់** ដែលជាខេត្តមួយ ស្ថិតនៅក្នុងប្រទេសកម្ពុជាភាគពាយព្យ ។ តាមការអះអាងជាច្រើន ពាក្យ **ពោធិ៍សាត់** នេះ ក្លាយមកពីពាក្យ "*ពោធិសត្ថ:*" ។ ប៉ុន្តែ "*ពោធិសាត់*" មានជាប់ទាក់ទងនឹងរឿងតំណាលមួយថា : មានដើមពោធិមួយដើម បានអណ្តែតបញ្ច្រាសទឹក ហើយមកទើរនៅលើទីមួយ រួចបានត្រូវគេស្រង់យកទៅដាំ ។ ទីដែលគេដាំដើមពោធិនោះឱ្យឈ្មោះថា "*ពោធិសាត់*" ហើយក្រោយៗមកទៀតគេនិយាយខ្លីថា "*ពោធិ៍សាត់*" ជាប់រហូតមកដល់សព្វថ្ងៃ ។



www.elibraryofcambodia.org

## សំណួរពិភាក្សា

១. សូមពិចារណារកឈ្មោះ ទីកន្លែងទាំងឡាយ ដែលមានទំនាក់ទំនងចំពោះបរិស្ថាននៅក្នុងមូលដ្ឋានរបស់ព្រះតេជព្រះគុណ-លោកអ្នក ស្នាក់អាស្រ័យនៅ ។

២. តើធនធានធម្មជាតិ សត្វព្រៃ ឬសម្បត្តិវប្បធម៌ (ដូចជាវិមាន ប្រាសាទជាដើម) ដែលបានឱ្យឈ្មោះដល់កន្លែងនោះ នៅតែមានជាក់ស្តែងនៅឡើយមែនឬទេ ?

៣. តើមានដើមឈើណាខ្លះ នៅក្នុងតំបន់ព្រះតេជព្រះគុណ-លោកអ្នក ដែលមានឈ្មោះជាឈើវនប្បតិ ដែរឬទេ ? បើគ្មានទេ តើសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក អាចរកឃើញ ហើយប្រាប់ឈ្មោះដើមឈើ ដែលឋិតរស់នៅបានយូរ អាចទៅជាវនប្បតិបានដែរឬទេ ?



www.elibraryofcambodia.org




២៧. ការយល់ដឹងបរិស្ថានតាមរយៈភាសាញាណ

www.elibraryofcambodia.org

| | |
|---|---|
| មេរៀន ២៩ | និមិត្តរូបនៃផ្កាឈូក |

ជានិច្ចកាល ដើមឈូក ឬបទុមជាតិ ជារុក្ខជាតិម៉្យាង បានក្លាយទៅជានិមិត្តរូប ដ៏ជាទីរាប់អានមួយនៃភាពបរិសុទ្ធ នៅក្នុងលទ្ធិព្រះពុទ្ធសាសនា ។ ផ្កាឈូក ដែលលូតដុះចេញផុតពីទឹកល្អក់ ឬភក់ ត្រូវបានចាត់ទុកជានិមិត្តរូបនៃសត្វលោក ដែលបានរួចផុតពី លោភៈ ទោសៈ និងមោហៈ ។ ផ្កាឈូក នៅតែជាដង្វាយសម្រាប់ពុទ្ធបូជា ដ៏មានប្រជាប្រិយ នៅក្នុងពិធីបុណ្យព្រះពុទ្ធសាសនា ជាពិសេស នៅក្នុងពិធីបុណ្យ **វិសាខបូជា** ដែលរំឭកដល់ការប្រសូត ការចូលព្រះបរិនិព្វាន និងការត្រាស់ដឹង របស់ព្រះបរមគ្រូជាអម្ចាស់នៃយើងរាល់គ្នា ។ ជារឿយៗ ផ្កាឈូកតែងតែត្រូវគេលើកយកមកពណ៌នា នៅក្នុងសិល្បៈតាមបែបពុទ្ធនិយម ហើយស្រះឈូកក៏គេតែងប្រទះឃើញជានិច្ចនៅតាមទីវត្តអារាម ។ មានរឿងមួយបានតំណាលថា : នៅពេលដែលព្រះអង្គទ្រង់ប្រសូតភ្លាមនោះ ព្រះសម្មាសម្ពុទ្ធទ្រង់បានឈានទៅមុខចំនួនប្រាំពីរជំហាន ទៅទិសខាងជើង ដោយយាងលើផ្កាឈូក ដែលផុសរីកឡើង ទ្រព្រះបាទារបស់ព្រះអង្គ ។ តម្លៃជានិមិត្តរូបដែលជាប់ទាក់ទងទៅនឹងផ្កាឈូកនេះ បានជួយរក្សាការពារពូជផ្សេងៗនៃផ្កាឈូក នៅក្នុងបណ្ដាប្រទេសដែលកាន់លទ្ធិព្រះពុទ្ធសាសនា ។

ពិធិ **បុណ្យផ្កា** ធ្វើឱ្យមានការជាប់ទាក់ទងទៅនឹងពុទ្ធបរិស័ទជាគ្រហស្ថ ដែលមានសទ្ធាជ្រះថ្លា ចូលជាបច្ច័យ ជួយវត្តអារាមនៅតាមមូលដ្ឋាន ដើម្បីជាប្រយោជន៍សំរាប់ជួសជុល សាងសង់ ឬក៏ផ្ដល់មូលនិធិចំពោះគំរោងទាំងឡាយរបស់សហគមន៍ ។ តាមប្រពៃណី បច្ច័យត្រូវគេដោតចងភ្ជាប់ទៅនឹងដើមឈើ ដើម្បីឱ្យដូចផ្ការីកមែនទែន ។ បុណ្យផ្កានេះ ដែលត្រូវគេប្រារព្ធធ្វើឡើងពេញមួយឆ្នាំនោះ ប្រហែលជាមានប្រភពដើមមកពីរឿងរ៉ាវរបស់ព្រះរាជានៃប្រទេសស្រីលង្កា ដែលទ្រង់បានបញ្ជូនចីវរ តុបតែងលំអដោយប្រាក់ៗកាក់ចំនួនបីរយ ហើយយកទៅប្រគេនព្រះភិក្ខុ **មហាបទុមត្ថេរ** ក្នុងការទទួលដឹងពួទូវការដែលភិក្ខុសង្ឃបានប្រើប្រាស់ផ្កា ដើម្បីគោរពបូជាចំពោះព្រះពុទ្ធបដិមា ។ នៅប្រទេសថៃ ពិធិបុណ្យ "*ផាប៉ា*" គឺជាពិធីបុណ្យមួយដែលមានលក្ខណៈស្រដៀងគ្នានឹងបុណ្យផ្ការបស់ខ្មែរដែរ ។ ពិធីបុណ្យនេះ បានត្រូវគេកែសម្រួលដោយល្អប្រពៃ ដើម្បីយកប្រាក់នេះសម្រាប់ដាំកូនឈើ និងសម្រាប់គំរោងការថែរក្សាបរិស្ថានដទៃទៀតរបស់សហគមន៍ ។ ពិធីបុណ្យផ្កានៅប្រទេសកម្ពុជា ក៏អាចយកមកកែច្នៃ ដើម្បីយកបច្ច័យ ផ្ដល់សម្រាប់គំរោងកែលំអបរិស្ថាននានា ពោលគឺសម្រាប់កែលំអគុណភាពនៃជីវិតរបស់សហគមន៍ទាំងឡាយ នៅក្នុងមូលដ្ឋាន ។



www.elibraryofcambodia.org

## សំណួរពិភាក្សា

១. នៅក្នុងរយៈពេលពីរបីឆ្នាំកន្លងទៅនេះ វត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក បានឧបត្ថម្ភគាំទ្រអ្វីខ្លះ ជាមួយនឹងបច្ច័យ ដែលបានរៃអង្គាសពីបុណ្យផ្កាកន្លងមក ?

២. តើព្រះតេជព្រះគុណ-លោកអ្នក អាចជួយជំរុញផ្តើមគំនិត បង្កើតសកម្មភាព និងគំរោងការបរិស្ថានអ្វីខ្លះ ក្នុងសហគមន៍ព្រះតេជព្រះគុណ-លោកអ្នក ដោយប្រើប្រាស់បច្ច័យ ដែលបានមកពីបុណ្យផ្កានោះ ?



www.elibraryofcambodia.org

## ២៨. និមិត្តរូបនៃផ្កាឈូក



www.elibraryofcambodia.org

www.elibraryofcambodia.org

មេរៀន
២ ៩

# ការបំបួសដើមឈើ

តាមធម្មតា ពិធីបុណ្យបំបួស ត្រូវគេចាត់ចែងឡើងសម្រាប់តែកុលបុត្រ ទុកជាទំនៀមទម្លាប់មួយ ដែលជាសញ្ញាបង្ហាញប្រាប់ ពីការចូលទៅក្នុងភេទជាបព្វជិត របស់កុលបុត្រទាំងនោះ ។ នៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះ ពិធីបុណ្យបំបួស បានត្រូវគេសម្របសម្រួល សម្រាប់បំបួសដើមឈើដែរ ។ នៅឆ្នាំ ១៩៩៨ ព្រះសង្ឃដែលបានធ្វើធម្មយាត្រានៅខេត្តរតនគិរី ក៏បានបំបួសដើមឈើ ទុកជានិមិត្តរូបផងដែរ ។ ព្រះសង្ឃពុទ្ធសាសនាបាន "បំបួស" ឈើ ដោយចងរុំព័ទ្ធជុំវិញដើមឈើនោះ ជាមួយនឹងស្បង់ចីពរ ឬសំពត់ជ្រលក់ពណ៌រមៀត ដើម្បីជាសញ្ញាប្រាប់នូវភាពពិសិដ្ឋរបស់ដើមឈើនោះ ។ ព្រះគ្រូចៅអធិការវត្ត **ពោធារាម** នៅប្រទេសថៃភាគខាងជើង ត្រូវបានគេប្រគេនកិត្តិយសជាភិក្ខុសង្ឃទី ១ ហើយ ដែលបានយល់ស្របតាមប្រពៃណីបំបួសកុលបុត្រ ឱ្យទៅជាពិធីបំបួសឈើនេះ ។ ព្រះតេជព្រះគុណអង្គនោះ បានពង្រីកទំនៀមទម្លាប់នេះ ឱ្យទៅជាឧបករណ៍ សម្រាប់អប់រំមនុស្សទាំងឡាយ អំពីសារប្រយោជន៍នៃបរិស្ថានព្រៃឈើ ហើយនិងគ្រោះថ្នាក់នៃការកាប់បំផ្លាញឈើ ។ ព្រះតេជព្រះគុណចៅអធិការអង្គនោះ បានពន្យល់យ៉ាងដូច្នេះថា :

*"ប្រសិនបើ ដើមឈើត្រូវគេរុំខ្ចប់ដោយស្បង់ ឬសំពត់សាដកទៅហើយ គ្មានបុគ្គលណាម្នាក់អាចហ៊ានកាត់ ឬកាប់ផ្ដួលរំលំឡើយ ។ ដូច្នេះ អាត្មាបានត្រិះរិះគិតថា ប្រហែលជាគំនិតនេះ អាចត្រូវគេប្រើប្រាស់ ដើម្បីបន្ថយបង្អាក់ការកាប់ឈើបាន ហើយអាត្មាភាពក៏បានចាប់ផ្ដើមរៀបចំ បង្កើតពិធីបុណ្យបំបួសដើមឈើនេះ នៅក្នុងព្រៃក្បែរវត្ត ។ អាត្មាភាពបានហៅទំនៀមទម្លាប់នេះថា ជាការបំបួស ដើម្បីឱ្យទម្ងន់ដល់ដើមឈើនោះ រឹតតែមានភាពពិសិដ្ឋឡើង ។ ពាក្យថា "ការបំបួសដើមឈើ" ពួទៅហាក់ដូចជាចម្លែកត្រចៀក ចំពោះប្រជាពលរដ្ឋថៃ ព្រោះថា ការបំបួសនេះ ធ្វើឡើងចំពោះតែបុរសភេទប៉ុណ្ណោះ ។ ការចម្លែកនេះ បានជួយផ្សព្វផ្សាយដំណឹងនេះ ឱ្យល្បីខ្ចរខ្ចាយពីមាត់មួយទៅមាត់មួយជាហូរហែរៀងទៅ "[១១]* ។

ព្រះគ្រូចៅអធិការអង្គនោះ បានទទួលជោគជ័យក្នុងការទាក់ទាញអារម្មណ៍ ចំពោះការបំផ្លិចបំផ្លាញបរិស្ថាន ដែលបណ្ដាលឡើងពីការកាប់រំលំព្រៃឈើ នៅក្នុងតំបន់របស់ព្រះអង្គ ហើយរាជរដ្ឋាភិបាលថៃ នៅ

---

[១១] *គ្រាប់ពូជសន្តិភាព ភាគ ១១ លេខ ១ ឆ្នាំ ១៩៩២ ។*



www.elibraryofcambodia.org

ក្នុងឆ្នាំបន្ទាប់ៗមក ក៏បានហាមប្រាមមិនឱ្យកាប់រំលំដើមឈើ ដើម្បីចូលរួមចំណែកចំពោះការខិតខំខ្នះខ្នែងរបស់ព្រះគ្រូចៅអធិការអង្គនោះ ។ ចាប់តាំងពីពេលនោះមក ភិក្ខុសង្ឃដទៃទៀត ក៏បានឯកភាពគ្នាយល់ព្រមថា ការបំបួសឈើនេះ វាជាមធ្យោបាយមួយនៃការថែរក្សាការពារព្រៃឈើ ។ ព្រះភិក្ខុសង្ឃទាំងនេះ ត្រូវគេប្រគេនងារៈជា "ព្រះសង្ឃអេកូឡូស៊ី" ឬ "ព្រះសង្ឃបរិស្ថាន" ដោយសារតែកិច្ចការបរិស្ថានរបស់ព្រះអង្គ ។ ពិធីបុណ្យសាសនា ដូចជាការបំបួសដើមឈើនេះជាដើម អាចធ្វើជាឧទាហរណ៍គន្លឹះមួយ ដើម្បីបញ្ជាក់ឱ្យឃើញពីភាពចាំបាច់ជាបន្ទាន់ នៃការថែរក្សាការពារធនធានធម្មជាតិ ព្រមទាំងទុកជាមាគ៌ាមួយនៃការប្រៀនប្រដៅ អំពីអន្តរសម្ពន្ធរវាងព្រះពុទ្ធសាសនា ធម្មជាតិ និងបរិស្ថានទាំងមូល ។

## សំណួរពិភាក្សា

*១. តើពិធីបំបួសដើមឈើ នឹងទៅជាពិធីបុណ្យដ៏សមស្របមួយ ដើម្បីរក្សាការពារឈើសំខាន់ៗ នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ដែរឬទេ ? ចូរពិភាក្សារកគុណសម្បត្តិ និងគុណវិបត្តិ ។*

*២. តើព្រះតេជព្រះគុណ-លោកអ្នក អាចនឹកឃើញពិធីបុណ្យពុទ្ធសាសនាដទៃទៀត ដែលជាពិធីបុណ្យដ៏សមរម្យ សម្រាប់ជួយជំរុញការថែរក្សាការពារព្រៃឈើ នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នកដែរឬទេ ?*



www.elibraryofcambodia.org

## ២៥. ការបំបួសដើមឈើ



www.elibraryofcambodia.org

www.elibraryofcambodia.org

# សកម្មភាព

## បរិស្ថានល្អជាមាគ៌ាជីវិតរបស់ពុទ្ធសាសនិកជន

១. វត្ថុបំណង : ដើម្បីគិតគូរពិចារណា ឬវិធីរកមធ្យោបាយទាំងឡាយ ដែលការប្រតិបត្តិប្រពៃណី ពិធីបុណ្យព្រះពុទ្ធសាសនា និងវត្ត អាចជួយថែរក្សាការពារបរិស្ថាន នៅក្នុងមូលដ្ឋាន បានដោយប្រសិទ្ធភាព ។

២. សកម្មភាព :

❶ ជាឯកជន ឬក៏ជាក្រុមតូចៗ ចូរជ្រើសរើសយកមេរៀនណាមួយ ដែលមាននៅក្នុងជំពូកទី ២ នេះ ។

❷ ចូរកត់ត្រាទុកនូវមូលហេតុ ដែលព្រះតេជព្រះគុណ-លោកអ្នក បានជ្រើសរើសយកមេរៀននោះ ហើយសូមព្រះតេជព្រះគុណ-លោកអ្នក ពិចារណាត្រិះរិះរកមធ្យោបាយ ឬវិធីទាំងឡាយ ដែលព្រះតេជព្រះគុណ-លោកអ្នក អាចធ្វើបាន តាមរយៈសកម្មភាពណាមួយ នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ។

*ខាងក្រោមនេះ ជាយោបល់ខ្លះៗ សម្រាប់ការធ្វើសកម្មភាពទាំងនេះ :*

- ❒ ចូរបង្កើតទីកន្លែងបណ្តុះកូនឈើ នៅក្នុងវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក ។
- ❒ ចូរសរសេរផ្លាក ហើយបិទភ្ជាប់នឹងដើមឈើសំខាន់ៗ នៅក្នុងវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក ឬនៅជិតព្រៃ ជាភាសាបាលី ដោយមានបកប្រែជាភាសាខ្មែរផង ។
- ❒ ចូររៀបចំបង្កើតជាសិក្ខាសាលាមួយស្តីអំពីបរិស្ថាន ដែលត្រូវប្រារព្ធធ្វើឡើងនៅក្នុងវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក ។



www.elibraryofcambodia.org

៣. ចំណាចអនុវត្ត :

❶ នៅក្នុងក្រុមតូចៗ ចូរធ្វើការពិភាក្សា និងកត់ត្រាជាបញ្ជីមាតិកា ឬវិធីអនុវត្តជាក់ស្តែង ដែលអាចជួយថែរក្សាការពារបរិស្ថានបាន តាមរយៈវត្តអារាម ដោយផ្តោតអារម្មណ៍លើការដឹកនាំការប្រតិបត្តិប្រពៃណី និងបុណ្យទាននានា របស់ព្រះពុទ្ធសាសនា ។

❷ ក្រោយពីធ្វើការពិភាក្សាក្នុងក្រុមតូចៗ រួចហើយ ចូរនាំគ្នាជួបប្រជុំជាក្រុមធំ ហើយចែករំលែកមតិយោបល់គ្នាទៅវិញទៅមក ។

❸ ចូរធ្វើការសម្រេចចិត្តយកសកម្មភាពទាំងឡាយណា ដែលក្រុមមានអារម្មណ៍ និងយល់ថា ជាសកម្មភាពសមរម្យជាងគេបំផុត សម្រាប់សហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ។ ចូរជ្រើសរើសយកសកម្មភាពតែពីរឬបីបានហើយ ដែលក្រុមយល់ថា ពួកគេអាចអនុវត្តបាន នៅក្នុងរយៈពេល ៦ ខែ ទៅមុខទៀតនេះ ។

❹ ពេលប្រជុំជាក្រុមធំ ចូរព្រាងគំរោងការងារប្រាំមួយខែនោះ នៅលើក្រដាសធំមួយសន្លឹក ឬលើក្ដារខៀនក៏បាន ។ ចូរធ្វើការកត់ចំណាំពីកាលបរិច្ឆេទសំខាន់ៗ នៃពិធីបុណ្យព្រះពុទ្ធសាសនាផង ។

❺ ចូរកត់ត្រាទុកជាទៀងទាត់ រៀងរាល់សប្តាហ៍ និងរៀងរាល់ខែ នូវសកម្មភាពបរិស្ថាន ដែលក្រុមនិមួយៗ នឹងត្រូវអនុវត្ត នៅក្នុងរយៈពេលប្រាំមួយខែនេះ ។

*ចូរចងចាំថា ពេលធ្វើការចាត់ប្រមាណនេះ យើងត្រូវគិតឱ្យបានដិតដល់ថា តើសកម្មភាពទាំងនេះ នឹងត្រូវចំណាយពេលប៉ុន្មាន ? តើនរណានឹងទទួលខុសត្រូវ ចំពោះសកម្មភាពទាំងនេះ ? តើនរណាខ្លះមកពីសហគមន៍ នឹងត្រូវចូលរួមនៅក្នុងសកម្មភាពទាំងនេះ ហើយតើក្រុមនិមួយៗ សង្ឃឹមរំពឹងទុកថា នឹងសម្រេចបានផលអ្វីខ្លះពីសកម្មភាព ដែលបានព្រោងទុកមកនេះ ?*



www.elibraryofcambodia.org

### ៤. សកម្មភាពអនុវត្តបន្ត :

① នៅរវាងដំណាច់ប្រាំមួយខែដំបូង ចូរធ្វើការប្រជុំជាក្រុមធំម្តងទៀត ដើម្បីពិភាក្សា និងវាយតម្លៃអំពីការរីកចំរើននៃសកម្មភាពទាំងនោះ ។ ពេលនោះ យើងសង្កេតឃើញថា សកម្មភាពខ្លះអាចត្រូវបំពេញបានចប់រួចរាល់ ឯសកម្មភាពខ្លះទៀត អាចនឹងធ្វើបន្ត រហូតទាល់ប្រាំមួយខែក្រោយមកទៀត ហើយមានសកម្មភាពខ្លះ ប្រហែលជាមិនបានសម្រេចលទ្ធផលទាល់តែសោះ ។

② ចូរនាំគ្នាពិភាក្សាអំពីហេតុផលនានា ដែលធ្វើឱ្យសកម្មភាពខ្លះ មិនបានទទួលលទ្ធផលជោគជ័យតាមការរំពឹងទុក ហើយចូរនាំគ្នាទឹករកដំណោះស្រាយ ឬវិធីផ្សេងទៀត ។

③ ចូរគូរវាសគំរោងការងារសម្រាប់រយៈពេលប្រាំមួយខែបន្ទាប់ ។ រួចហើយចូរបំពេញនូវសកម្មភាពដែលត្រូវធ្វើបន្ត និងសកម្មភាពថ្មីណាមួយក៏បាន ។

## បរិច្ឆេទចលនាទី៦ ពិចារណាធនធានរបស់អ្នក



www.elibraryofcambodia.org

www.elibraryofcambodia.org

# ជំពូកទី ៣

# ការបង្កើតនិរន្តរភាពបរិស្ថាន


មេរៀន ៣ក : បរិស្ថានសមស្របល្អ

មេរៀន ៣ខ : ឆាកជីវិតរបស់ព្រះពុទ្ធ

មេរៀន ៣គ : ទឹកជាប្រភពនៃជីវិត

មេរៀន ៣ឃ : ជំនឿ និង ទម្លាប់នៅតាមមូលដ្ឋាន

មេរៀន ៣ង : សត្វសេក និង ដើមជ្រៃ

មេរៀន ៣ច : ការធ្វើបុណ្យកុសលតាមរយៈអំណោយសួនឧទ្យាន

*សកម្មភាព : ការបង្កើតឱ្យមានបរិស្ថានសមស្របល្អ*


www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន ៣ ក**

# បរិស្ថានសមស្របល្អ

តាមទស្សនៈរបស់ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ស្ដីអំពីទំនាក់ទំនងរវាងមនុស្ស និងធម្មជាតិ បានបង្ហាញនៅក្នុងគោលការណ៍របស់ព្រះអង្គអំពី "*ការចិញ្ចឹមជីវិតតាមសម្មាអាជីវៈ*" ដែលជាមាគ៌ាមួយ នៅក្នុងចំណោមមាគ៌ាទាំងឡាយ ក្នុងលទ្ធិរបស់ព្រះសម្មាសម្ពុទ្ធ ស្ដីអំពី **អដ្ឋង្គិកមគ្គ** ឆ្ពោះទៅរកការត្រាស់ដឹង ។ នៅក្នុង **គម្ពីរមង្គលសូត្រ** ដែលនៅក្នុងនោះ ព្រះសម្មាសម្ពុទ្ធទ្រង់រៀបរាប់ ដោយបានលើកបង្ហាញ ពីកត្តាដ៏សក្ដិសមទាំងឡាយ ដែលនាំមកនូវសុខុមាលភាពរបស់បុគ្គលម្នាក់ៗ ព្រះអង្គទ្រង់សម្ដែងវែកញែកសេចក្ដីក្នុងវគ្គមួយថា "*ដើម្បីស្នាក់អាស្រ័យនៅក្នុងទីកន្លែងដ៏សមរម្យ ឬបរិស្ថានមួយ*" ។

មាគ៌ាជីវិតរបស់មនុស្សម្នាក់ៗ មានសណ្ឋានរូបរាងឡើងដោយសារបរិស្ថាន ដែលមនុស្សកំពុងរស់ ។ បរិស្ថានដែលមានរួមបញ្ចូលទាំងមនុស្ស សង្គម-វប្បធម៌ និងធម្មជាតិ មានសភាពខុសប្លែកគ្នា ពីប្រទេសមួយទៅប្រទេសមួយ និងពីតំបន់មួយទៅតំបន់មួយទៀត ។ អត្តសញ្ញាណវប្បធម៌របស់មនុស្សរីកលូតលាស់ និងដុះដាលឡើង ស្របទៅតាមបរិស្ថាននៅតាមមូលដ្ឋាន ដែលមានសភាពផ្សេងគ្នាដូច្នោះដែរ ។ នៅប្រទេសកម្ពុជា មានប្រជាពលរដ្ឋខ្មែរជាម្ចាស់ប្រទេសរស់នៅតាមទីជនបទ និងទីក្រុង ។ ក្រៅពីនេះ នៅមានជនជាតិចិន វៀតណាម ចាម[១២] និងជនជាអន្លោគ្រោម[១៣] ព្រមទាំងជនជាតិភាគតិចដទៃផ្សេងៗ រស់តាមតំបន់ព្រៃភ្នំទៀតផងដែរ ។ ក្រុមនីមួយៗ រីកចំរើន និងលូតលាស់ក្នុងបរិស្ថានពិសេសមួយ ដោយបន្ថែមនូវភាសាវប្បធម៌ដ៏ប្រពៃរបស់ខ្លួន ទៅលើបរិស្ថានធម្មជាតិដ៏ប្រណិតរបស់ប្រទេសកម្ពុជាទៀតផង ។

ការបំផ្លិចបំផ្លាញជំរក ឬលំនៅឋាន[១៤] ធម្មជាតិ ជាធម្មតាតែងនាំមកនូវការខូចរេចរឹលបរិស្ថានទាំងមូល ដែលជាហេតុធ្វើឱ្យបរិស្ថានពុំមានលក្ខណៈសមរម្យ សម្រាប់ការរស់នៅសោះឡើយ ។ មាគ៌ាជីវិត ភាសា ចំណេះដឹងខាងប្រពៃណី កេរដំណែលវប្បធម៌ ព្រមទាំងអត្តសញ្ញាណរបស់សហគមន៍ទាំងឡាយ ដែលរស់នៅក្នុងជំរក ឬលំនៅស្ថានទាំងនេះ ត្រូវទទួលរងគ្រោះថ្នាក់ ឬការបំផ្លិចបំផ្លាញដូចគ្នាដែរ ។ ដូចគ្នានេះដែរ

---

[១២] *ចាមជាជនជាតិអ៊ិស្លាមកម្ពុជា មានគំហេតុជមកពីអាណាចក្រចំប៉ាបុរាណ ឬមកពីប្រទេសម៉ាឡេស៊ី ។*

[១៣] *អន្លោគ្រោម : កម្មសិទ្ធិតាមធម្មជាតិ ។ ប្រជាជនអន្លោគ្រោមជាទូទៅត្រូវគេចាត់ទុកថាជាប្រជាជនដើមនៅលើទឹកដីណាមួយ អស់ជាច្រើនសតវត្សមកហើយ ។ ក្រុមអន្លោគ្រោមនៅក្នុងប្រទេសកម្ពុជារួមមាន : ទំពួន គ្រឹង ចារាយ ការ៉េត កាចុក ព្រៅ និងកួយ ។*

[១៤] *ជំរក ឬលំនៅឋាន : បរិស្ថានធម្មជាតិរបស់សត្វ រុក្ខជាតិ មនុស្សជាតិ ។ល។*



www.elibraryofcambodia.org

ឱនភាពនៃមាគ៌ាជីវិតមួយចំនួន ដូចជាសង្គមជនបទជាដើម តែងតែនាំមកនូវការបំផ្លិចបំផ្លាញជំរក ឬលំនៅឋាន ដែលបានទ្រទ្រង់ដល់ពួកគេ ។ ហេតុការណ៍នេះ បានផ្ដល់ផលឱ្យដល់ប្រជាពលរដ្ឋ ឱ្យក្លាយទៅជាអ្នកគ្មានទីដៅ និងវង្វេងស្មារតីក្នុងជីវភាពរស់នៅរបស់គេ ព្រមទាំងបាត់បង់នូវចំណេះដឹងអំពីជំរក ឬលំនៅឋានទាំងនេះផងដែរ ។ ការថែរក្សាការពារជំរក ឬលំនៅឋានធម្មជាតិ មានន័យថា ថែរក្សាការពារបរិស្ថាន ដែលក្នុងនោះរួមទាំងខ្លួនយើងផងដែរ ។

## សំណួរពិភាក្សា

*១. ចូរពិភាក្សាអំពីមាគ៌ា ឬវិធីទាំងឡាយ ដែលជីវិតរបស់ព្រះតេជព្រះគុណ-លោកអ្នកបានទទួលរងឥទ្ធិពលពីបរិស្ថានធម្មជាតិនៅជុំវិញខ្លួន ។ តទៅនេះ ជាសំណួមពរខ្លះៗ អំពីប្រធានបទសំរាប់ធ្វើការពិភាក្សា :*

- *ការស្លៀកពាក់*
- *សិប្បកម្ម*
- *ម្ហូបអាហារ*
- *ទីលំនៅ*
- *ពិធីបុណ្យទានផ្សេងៗ*
- *ទម្លាប់ និងជំនឿនៅតាមមូលដ្ឋាន ។*

*២. តើជីវភាពរស់នៅរបស់ព្រះតេជព្រះគុណ-លោកអ្នក មានសភាពខុសគ្នាយ៉ាងដូចម្ដេចខ្លះ បើធៀបនឹងការរស់នៅរបស់ប្រជាពលរដ្ឋ នៅកន្លែងផ្សេងៗទៀត នៅប្រទេសកម្ពុជា ?*

*៣. ចូរពិភាក្សាពីរបៀប ដែលបរិស្ថាននៅតាមមូលដ្ឋានរបស់ព្រះតេជព្រះគុណ-លោកអ្នក បានប្រែប្រួលនៅក្នុងរយៈពេល ១០ ឆ្នាំ កន្លងមកនេះ ។ តើការប្រែប្រួលទាំងនេះ មានឥទ្ធិពលយ៉ាងដូចម្ដេចខ្លះទៅលើមាគ៌ា ឬវិធីដែលមនុស្សទាំងឡាយ នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ដឹកនាំជីវិតរស់នៅរបស់គេ ?*



www.elibraryofcambodia.org





៣ក. បរិស្ថានសមស្របល្អ







www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន ៣២**

# ឆាកជីវិតរបស់ព្រះពុទ្ធ

ភាគច្រើននៃឆាកជីវិតរបស់ព្រះពុទ្ធជាអម្ចាស់ សុទ្ធតែមានការជាប់ពាក់ព័ន្ធ ជាមួយនឹងធម្មជាតិទាំងអស់ ។ ព្រះពុទ្ធបរមគ្រូទ្រង់បានប្រសូតមក អស់រយៈកាលជាង ២៥០០ ព្រះវស្សាកន្លងទៅហើយ នាក្រោមដើមសាលព្រឹក្ស ក្នុងឧទ្យាន **លុម្ពិនី** ក្បែរនគរ **កបិលពស្តុ** និងនគរ **ទេវទហៈ** នៃប្រទេសឥណ្ឌា នៅភ្នំហេមពាន្តខាងជើង ។ ការតាំងសមាធិលើកដំបូងរបស់ព្រះអង្គ បានកើតឡើងនៅក្រោមដើមជម្ពូព្រឹក្ស ហើយការត្រាស់ដឹងរបស់ព្រះអង្គទៀតសោត ក៏បានកើតឡើងនៅក្រោមដើមពោធិព្រឹក្ស ក្បែរឆ្នេរស្ទឹង **នេរញ្ជរា** ក្នុងដែន **មគធរដ្ឋ** នៃប្រទេសឥណ្ឌា ។ ការសំដែងធម៌ទេសនា ជាលើកទី ១ របស់ព្រះអង្គ បានកើតឡើងនៅក្នុងឧទ្យាននៃព្រៃ **ឥសិបតនៈ** ជាទីដែលព្រះអង្គបានបំបួសតាបសប្រាំរូប ឱ្យទៅជាព្រះភិក្ខុសង្ឃលើកដំបូងបង្អស់ ។ ការចូលបរិនិព្វានរបស់ព្រះអង្គ បានកើតឡើងនៅក្នុងឧទ្យាន **សាលវ័ន** នៅចន្លោះដើមសាលព្រឹក្សទាំងគូ ។ នៅក្នុងវគ្គមួយនិយាយថា ក្នុងពេលដែលព្រះអង្គប្រសូត ត្រាស់ដឹង និងចូលព្រះបរិនិព្វាននោះ ដើមឈើទាំងឡាយ បានបញ្ចេញផ្កាផ្លែខុសរដូវកាល ។

សម័យកាលដែលព្រះពុទ្ធអង្គគង់នៅ ការរៀបចំនគរមានលក្ខណៈខុសគ្នាឆ្ងាយ មិនដូចអ្វីដែលយើងបានឃើញក្នុងបច្ចុប្បន្នកាលនេះឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ព្រះសម្មាសម្ពុទ្ធទ្រង់បានធ្វើសេចក្ដីសម្រេចព្រះទ័យលះបង់ ដោយការយាងចេញចាកពីបរមរាជវាំង ដែលធ្លាប់ជាទីកន្លែងរស់នៅដ៏ប្រណីត និងមានការថែរក្សាការពារព្រះអង្គយ៉ាងប្រុងប្រយ័ត្ន ក្រោយពេលដែលព្រះអង្គបានជួបប្រទះនឹងសេចក្ដីទុក្ខឈឺចាប់ពីពិភពលោកខាងក្រៅ (ដូចជាមនុស្សចាស់ជរា ឈឺ ស្លាប់ និងភេទអ្នកបួស) រួចមក ។ ចាប់តាំងពីពេលនោះមក ទើបព្រះអង្គសម្រេចព្រះទ័យស្វែងរកមោក្ខធម៌ និងសច្ចធម៌ ។ មនុស្សភាគច្រើនមិនដូចព្រះពុទ្ធទេ ពួកគេមើលមិនឃើញសេចក្ដីឈឺចាប់របស់ពិភពខាងក្រៅឡើយ ហើយប្រឹងស្វះស្វែងរកគ្រប់មធ្យោបាយ ដើម្បីបំពេញបំណងប្រាថ្នា និងតណ្ហាភ្លាមៗរបស់ខ្លួនផ្ទាល់តែប៉ុណ្ណោះ ។ គេងាយនឹងទទួលយកប្រាក់ ជាថ្នូរនឹងការកាប់បំផ្លាញព្រៃឈើ ដោយពុំបានគិតគូរដល់សេចក្ដីទុក្ខឈឺចាប់ ដែលនឹងកើតមានដល់មនុស្ស ទាំងអស់ក្នុងសហគមន៍ ដែលពួកគេកំពុងរស់នៅ និងពឹងផ្អែកលើព្រៃឈើតែមួយមុខ ដើម្បីរស់រានទៅមុខទៀតឡើយ ។ ការរងទុក្ខវេទនានេះ អាចកើតមានផងដែរ ដល់ពួកសត្វទាំងឡាយ ដែលបានបាត់បង់ទីជំរកធម្មជាតិរបស់វា ដល់ពួកត្រីទាំងឡាយ ដែលបាត់បង់ទីកន្លែងសំរាប់ពង នៅទីម

www.elibraryofcambodia.org

ពេលដែលទន្លេស្ទឹងទាំងឡាយកាន់តែរាក់ទៅៗ ដោយសារកក់ល្បាប់ចាក់បំពេញ ។ គ្រួសារទាំងឡាយនឹងទទួលរងទុក្ខវេទនា ដោយការខ្វះខាតស្រូវ ត្រី ឬភោគផលកសិកម្ម ។

រឿងរ៉ាវនៃវគ្គជីវិតរបស់ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ បានពន្យល់បង្ហាញឱ្យឃើញពីសារសំខាន់ដែលមនុស្សទាំងអស់ត្រូវចាំទុកក្នុងចិត្តថា ខ្លួនគេផ្ទាល់ក៏ជាផ្នែកមួយនៃបរិស្ថានដែរ ។ ការកែលំអបរិស្ថានដើម្បីធ្វើឱ្យសហគមន៍របស់យើង ទៅជាទីកន្លែងមួយរឹតតែល្អប្រសើរឡើងៗ ក្នុងការរស់នៅនោះ មិនមែនមានន័យថា ត្រូវពឹងផ្អែកតែទៅលើអ្នកដទៃសុទ្ធសាធនោះទេ ប៉ុន្តែត្រូវពឹងផ្អែកលើខ្លួនឯងផងដែរ ដោយរួបរួមទាំងព្រះតេជព្រះគុណ-លោកអ្នក និងរូបខ្ញុំព្រះករុណា-ខ្ញុំបាទផងដែរ ។

## សំណួរពិភាក្សា

*១. ចូរពិភាក្សាពីអំពើទាំងឡាយ ដែលព្រះតេជព្រះគុណ-លោកអ្នក ឬក៏សមាជិកទាំងឡាយ ក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក បានប្រព្រឹត្ត ដែលនឹងអាចបង្កគ្រោះថ្នាក់ដល់បរិស្ថានទៅវិញ ។ តើអំពើទាំងនេះ បង្កឱ្យមានការរងទុក្ខវេទនា ឈឺចាប់យ៉ាងដូចម្តេចខ្លះ ?*

*២. ចូរពិភាក្សារកមាគ៌ាអនុវត្តជាក់ស្តែង ដែលព្រះតេជព្រះគុណ-លោកអ្នក អាចជូនដំណឹងទៅដល់មនុស្សទាំងឡាយ អំពីការឈឺចាប់កើតឡើងពីអំពើរបស់ពួកគេ ។*



www.elibraryofcambodia.org




www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន ៣ គ**

# ទឹកជាប្រភពនៃជីវិត

សត្វទាំងឡាយត្រូវការអាស្រ័យនៅក្បែរទឹក ដើម្បីរស់រានមានជីវិត ។ យ៉ាងណាមិញ អាទិភាពចំបងសម្រាប់ការស្នាក់អាស្រ័យនៅរបស់មនុស្ស គឺត្រូវស្វែងរកប្រភពទឹកនៅក្បែរខ្លួន ដែលអាចទ្រទ្រង់ដល់ជីវិតរស់នៅរបស់មនុស្សទាំងពួងបាន ។ ព្រះពុទ្ធសាសនាបានចាត់ទុកទឹកថាជាធាតុ ឬមហាភូតរូបមួយ ក្នុងចំណោមមហាភូតរូបទាំង ៤ ដែលបង្កើតបានជាពិភពលោកយើងនេះ ។ ទោះបីជារស់នៅក្នុងពិភពមួយ ដែលសម្បូណ៌ទៅដោយធនធានធម្មជាតិក៏ដោយ ក៏ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ទ្រង់បានធ្វើឱ្យសាវ័ករបស់ព្រះអង្គ មានការភ្ញាក់រឭកយល់ដឹង អំពីសារប្រយោជន៍នៃការការពារ និងថែរក្សាប្រភពទឹក ។ ព្រះអង្គទ្រង់បានធ្វើការទូន្មាន ដល់ភិក្ខុសង្ឃទាំងឡាយណា ដែលប្រើប្រាស់ទឹក ដោយគ្មានការចេះគិតពិចារណា ហើយបានលើកសរសើរភិក្ខុទាំងឡាយណា ដែលបានជីកអណ្តូងទឹក និងស្រះទឹក សម្រាប់ជាផលប្រយោជន៍សហគមន៍ប្រើប្រាស់ ។ ពិសិដ្ឋភាពនៃទឹក ត្រូវបានគេលើកយកមកពន្យល់នៅក្នុងពិធីមួយ ដែលគេប្រើប្រាស់ដើម្បីប្រសិទ្ធិពរជ័យ ដល់ជនប្រុសស្រីទាំងឡាយ នៅក្នុងពិធីបុណ្យនានារបស់ព្រះពុទ្ធសាសនា ។ ដោយសារតែទឹកជាមហាភូតរូបម្យ៉ាង ដែលអាចពន្លត់ភ្លើងបាន ហើយដែលគេស្គាល់ថា ភ្លើងជាមហាភូតរូបបំផ្លាញលោកនោះ ទឹកក៏ជានិមិត្តរូបនៃសន្តិភាព និងការផ្សះផ្សា ស្រុះស្រួលចិត្តគ្នាផងដែរ ។ នៅប្រទេសកម្ពុជា មានប្រព័ន្ធធារាសាស្ត្រដ៏វិសេសមួយ ដែលមានបឹងទន្លេសាប ទន្លេមេគង្គ និងទន្លេស្ទឹងផ្សេងទៀត ។ នៅរដូវវស្សា បឹងទន្លេសាបដើរតួជាអាងផ្ទុកទឹកជំនន់ទន្លេមេគង្គ ។ ទឹកទន្លេមេគង្គហូរទៅទិសខាងជើង កាត់តាមដងទន្លេសាប ចាក់បំពេញបឹងទន្លេសាប ។ នៅពេលខ្យល់មូសុងវស្សាបញ្ចប់ទៅ ទឹកក៏ហូរបញ្ច្រាសចុះមកវិញ ។ បឹង និងស្ទឹងទន្លេ តែងតែផ្តល់ដល់ប្រជាជនកម្ពុជានូវទឹក និងត្រី ព្រមទាំងទ្រទ្រង់ដល់ប្រព័ន្ធកសិកម្ម និងការដឹកជញ្ជូនទៀតផង ។ ពិធី **បុណ្យអុំទូក** ដែលគេប្រារព្ធធ្វើឡើង នៅរៀងរាល់ជិតដំណាច់រដូវវស្សា តែងតែផ្តល់ឱកាសឱ្យប្រជាជនកម្ពុជាគោរព និងដឹងគុណ ចំពោះប្រព័ន្ធទឹកដ៏សំខាន់នេះ ។ ទឹកគឺជានិមិត្តរូបមួយដ៏សំខាន់ សម្រាប់ប្រជាពលរដ្ឋកម្ពុជា ដែលបានជ្រៀតចូលទៅក្នុងវប្បធម៌ ភាសា ផ្គត់ផ្គង់ជីវិត និងការរស់នៅរបស់គេ ។ ការទាញយកអំពីនិមិត្តរូបនេះ ជួយប្រជាពលរដ្ឋកម្ពុជា ឱ្យគោរពតាមដំបូន្មានរបស់ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ដើម្បីការពារ និងថែរក្សាប្រភពទឹក សម្រាប់មនុស្ស និងសត្វគ្រប់រូបទាំងអស់ ។



www.elibraryofcambodia.org

## សំណួរពិភាក្សា

១. តើប្រភពទឹកដ៏សំខាន់ៗទាំងឡាយ សំរាប់សហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក មានទីតាំងនៅឯណា ? និងមានអ្វីខ្លះ ?

២. តើសហគមន៍ព្រះតេជព្រះគុណ-លោកអ្នក ប្រើប្រាស់ប្រភពទឹកនៅតាមមូលដ្ឋាន សំរាប់ធ្វើអ្វីខ្លះ ?

៣. តើមានពិធីបុណ្យ និងទំនៀមទម្លាប់អ្វីខ្លះ នៅតាមមូលដ្ឋានក្នុងសហគមន៍របស់ព្រះតេជគុណ-លោកអ្នក ដែលទទួលស្គាល់សារសំខាន់នៃប្រភពទឹកទាំងនេះ ?

៤. ចូរសាកល្បងរកដំណឹង និងរឿងរ៉ាវទាំងឡាយ (ពីមនុស្សវ័យចាស់ ឬពីសៀវភៅផ្សេងៗ) ទាក់ទងនឹងបឹងទន្លេសាប និងប្រព័ន្ធស្ទឹងទន្លេនៅប្រទេសកម្ពុជា ។



www.elibraryofcambodia.org

## ៣៩. ទឹកជាប្រភពនៃជីវិត



www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន ៣ ឃ**

# ជំនឿ និង ទម្លាប់នៅតាមមូលដ្ឋាន

ព្រះពុទ្ធសាសនាជាសាសនាមួយ ដែលមានលក្ខណៈប្រកបដោយក្តីសន្តោសប្រណីជាងគេបំផុត នៅក្នុងចំណោមសាសនានានា ក្នុងសកលលោក ។ ព្រោះហេតុនេះហើយ ទើបការចូលរួមវិភាគទានរបស់ព្រះពុទ្ធសាសនា ចំពោះការថែរក្សាការពារបរិស្ថាន បានសង្កត់ធ្ងន់លើការនៅរួមរស់ជាមួយគ្នា ដោយសហវិជ្ជមានជាមួយសាសនា និងជំនឿទាំងឡាយដទៃទៀត ។ នៅក្នុង **មហាបរិនិព្វានសូត្រ** ព្រះពុទ្ធទ្រង់មានពុទ្ធដីកាយ៉ាងដូច្នេះថា : *ដរាបណាមនុស្សនៅតែគោរពលើជំនឿសាសនាផ្សេងៗទៀត ហើយនិងទីកន្លែងដ៏ពិសិដ្ឋពីបុរាណមកនោះ បរិស្ថានសង្គមនឹងមានស្ថានភាពល្អដដែល* ។ នៅក្នុងឆ្នាំ ១៩៩៧ ពុទ្ធសាសនបណ្ឌិត្យនៅទីក្រុងភ្នំពេញ បានរៀបចំបង្កើតសិក្ខាសាលាប្រចាំតំបន់អាស៊ីមួយ ស្តីអំពីអភិសមាចារ ឬក្រមសីលធម៌បរិស្ថាន ដែលរួមមានការចូលរួមវិភាគទានពីសាសនិកជនអ៊ិស្លាមនៅប្រទេសកម្ពុជា ម៉ាឡេស៊ី និង ឥណ្ឌូណេស៊ី ព្រមទាំងពីទស្សនៈទាំងឡាយរបស់ជនអន្តោប្រវេសន៍ និងតំណាងកុលសម្ព័ន្ធព្រៃភ្នំមកពីប្រទេសថៃ ហ្វីលីពីន និងកម្ពុជាផងដែរ ។

ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា និងនៅប្រទេសជិតខាងទាំងឡាយ ក៏មានអត្ថិភាពរួមគ្នា ប្រកបដោយសន្តិវិធីផងដែរ ជាមួយនឹងជំនឿប្រជាជន ដែលមានមូលដ្ឋានលើ *ព្រលឹង ឬអ្នកតា* និងការបូជាចំពោះបុព្វការីជន ។ ជំនឿទាំងនេះ មិនត្រឹមតែបានដើរតួនាទីដ៏សំខាន់ ក្នុងការរក្សាភាពស្រុះស្រួលគ្នា រវាងមនុស្ស និងធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែជំនឿទាំងនេះក៏បានចូលរួមវិភាគទាន ឱ្យដល់ការថែរក្សា ការពារបរិស្ថានផងដែរ ។ ប្រសិនបើជំនឿមានជាប្រពៃណី គប់យ៉ាងជ្រៅបែបនេះទៅហើយ ត្រូវតែមិនយកចិត្តទុកដាក់ ឬធ្វើមិនដឹងមិនឮ ឬត្រូវតែចាត់ទុកថា "*ជឿថយក្រោយ*" ទៀតនោះ ប្រជាពលរដ្ឋនឹងលែងមានអារម្មណ៍ជិតស្និទ្ធ ឬរវល់គិតដើម្បីស្តាប់គំនិតថ្មីៗ ឬធ្វើកិច្ចសហប្រតិបត្តិការជាមួយ នៅក្នុងសកម្មភាពបរិស្ថាន ជាមិនខានឡើយ ។ ព្រះពុទ្ធសាសនាអាចជួយបង្ហាញពីតួនាទីដ៏មានតម្លៃរបស់ប្រពៃណី និងជំនឿពីបុរាណទាំងឡាយ ដែលអាចមាននៅក្នុងពិភពសម័យទំនើបនេះ ។ វត្តជាច្រើននៅប្រទេសថៃ លាវ កម្ពុជា និងប្រទេសដទៃផ្សេងទៀត នៅតែមានទីកន្លែងធ្វើពិធីសក្ការបូជា ចំពោះអាទិទេព និងអារក្សអ្នកតាទាំងឡាយ នៅក្នុងមូលដ្ឋានរបស់គេ ។ ព្រះភិក្ខុសង្ឃបរិស្ថាន ដែលទទួលបានជ័យជំនះច្រើនជាងគេបង្អស់នោះ គឺភិក្ខុសង្ឃអង្គ



www.elibraryofcambodia.org

ណាក ដែលបង្កើតបានទំនាក់ទំនងដ៏ស្និតស្នាល ជាមួយនឹងអ្នកស្រុកអ្នកភូមិនៅតាមមូលដ្ឋាន ហើយគោរពស្រឡាញ់ចំណេះដឹង និងជំនឿរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាននោះ ។

នៅខេត្ត **ណាន** នៃប្រទេសថៃ ព្រះគ្រូចៅអធិការព្រះនាម **ព្រះគ្រូពិជិតណានតាខុម** មានការយល់ដឹងអំពីខ្លឹមសារនៃជំនឿខាងផ្លូវចិត្ត នៅក្នុងចំណោមកសិករទាំងឡាយ ក្នុងភូមិកំណើតរបស់ព្រះអង្គ ។ ព្រះអង្គបានបើកផ្លូវ ដើម្បីបញ្ចូលជំនឿទាំងនោះ ទៅក្នុងគំរោងការបរិស្ថាន ។ នៅពេលប៉ុន្មានថ្ងៃមុននៃពិធីបុណ្យបំបួសដើមឈើរបស់ភូមិមួយ (សូមមើលមេរៀនការបំបួសដើមឈើ) អ្នកស្រុកក្នុងភូមិបានប្រារព្ធពិធីបុណ្យឱ្យដល់រុក្ខទេវតា ដោយជូនដំណឹងដល់រុក្ខទេវតានោះ អំពីពិធីបំបួស ព្រមទាំងបានស្នើសុំឱ្យរុក្ខទេវតាទាំងអស់នោះ ជួយថែរក្សាការពារព្រៃព្រឹក្សានោះទៀតផង ។ នៅក្នុងករណីបែបនេះ ជំនឿនៅតាមមូលដ្ឋាន និងព្រះពុទ្ធសាសនា បានធ្វើការរួមគៀកគ្នា ដើម្បីថែរក្សាការពារព្រៃឈើ ដែលជាហេតុធ្វើឱ្យគំរោងការនោះអាចទទួលយកបាន និងមានការចូលរួមពីមនុស្សម្នាទាំងអស់ ដែលរស់នៅក្នុងសហគមន៍ទៀតផង ។

## សំណួរពិភាក្សា

១. *តើសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក មានជំនឿ និងទម្លាប់មូលដ្ឋានអ្វីខ្លះ ? ប្រសិនបើមាន តើការធ្វើសក្ការបូជា ចំពោះព្រះអាទិទេព ឬអារក្សអ្នកតាទាំងនោះ មានអ្វីខ្លះ នៅក្នុងវត្តរបស់ព្រះតេជព្រះគុណ -លោកអ្នក ?*

២. *ចូរធ្វើការពិភាក្សាថា តើជំនឿទាំងនេះបានចូលរួម ឬអាចចូលរួមវិភាគទានយ៉ាងណា ចំពោះការថែរក្សាការពារបរិស្ថាន នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ?*



www.elibraryofcambodia.org



www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន**
**៣ ១**

# សត្វសេក និង ដើមជ្រៃ

កាលពីព្រេងនាយ មានស្តេចសេកនិងបរិវារជាច្រើន រស់នៅលើដើមជ្រៃមួយដើមក្នុងព្រៃមួយ ។ រាល់ពេលដែលដើមជ្រៃជ្រុះផ្លែនិងស្លឹកអស់ ស្តេចសេកពុំដែលមានចិត្តលះបង់ទីស្ថាននេះម្តងណាឡើយ និងរស់ដោយការបរិភោគតែអ្វី ដែលខ្លួនបានប្រទះឃើញនៅសល់លើដើមជ្រៃតែប៉ុណ្ណោះ ។ ស្តេចសេកមានសេចក្តីសប្បាយរីករាយ និងពេញចិត្តជាខ្លាំង ចំពោះទីស្នាក់អាស្រ័យណា ដែលខ្លួនធ្លាប់បានរស់នៅ ។ មានថ្ងៃមួយ សក្កទេវរាជជាស្តេចទេវតា បានធ្វើការសាកល្បងចិត្តស្តេចសេកនោះ ។ ដោយមហិទ្ធិឫទ្ធិរបស់ព្រះអង្គ ស្តេចសក្កទេវរាជបានធ្វើឱ្យដើមជ្រៃនោះប្រែជាស្វិតស្រពោន ។ ពេលដឹងដោយទិព្វចក្ខុថា រឿងនេះមិនបានធ្វើឱ្យសត្វសេកផ្លាស់ប្តូរចិត្តបានដោយងាយនោះ ស្តេចសក្កទេវរាជក៏ក្លែងភេទព្រះអង្គ ធ្វើជាស្តេចក្ងានមួយសំដៅទៅកាន់សំណាក់ស្តេចសេក ដើម្បីសួរឱ្យបានដឹងច្បាស់នូវមូលហេតុដែលស្តេចសេកនោះ នៅតែរីករាយពេញចិត្តនឹងរស់នៅតែលើដើមជ្រៃ ដែលស្វិតស្រពោន និងពុកផុយបែបនេះដដែល ។ ស្តេចសេកបានឆ្លើយតបថា : "*ដើមជ្រៃនេះ ធ្លាប់តែជាដើមឈើដ៏ល្អប្រសើរមួយសម្រាប់ខ្ញុំ អស់កាលដ៏យូរលង់ណាស់មកហើយ ។ តើវាមានប្រយោជន៍អ្វី ដែលខ្ញុំត្រូវកាត់ចោលដើមជ្រៃនោះ ?*" ។ នៅពេលនោះ សក្កទេវរាជក៏បានបណ្តាលហេតុឱ្យដើមជ្រៃនោះ មានផ្កាផ្លែជាថ្មីឡើងវិញ ។

រឿងនេះបានដកស្រង់ពី **មហាសុខជាតក** ដែលបានពន្យល់ឱ្យឃើញពីសញ្ញាណដើមនៃធម៌កតញ្ញូតា នៅពេលដែលស្តេចសេកបដិសេធ មិនបោះបង់ចោលដើមជ្រៃ ដែលធ្លាប់ផ្តល់ជាលំនៅស្ថានដ៏សុខសាន្តរបស់ខ្លួន ។ ដូចគ្នានេះដែរ មនុស្សទាំងឡាយក៏បានពង្រីកន័យអំពីសម្ពន្ធភាពជាមួយបរិស្ថានទាំងមូល នៅក្នុងមូលដ្ឋានដែលគេរស់នៅ ។ ប្រជាពលរដ្ឋនៅជនបទ និងនៅតំបន់ខ្ពង់រាប បានគ្រប់គ្រងធនធានធម្មជាតិរបស់គេ ទៅតាមវិធីជាប្រពៃណីបុរាណ ជាយូរមកហើយ ដោយបានបង្កើតឡើង តាមរយៈនៃការដកពិសោធន៍ក្នុងការរស់នៅ ដោយមានសម្ពន្ធយ៉ាងជិតស្និទ្ធបំផុត ជាមួយនឹងបរិស្ថានជុំវិញរបស់គេ ។ ប្រសិនបើបរិស្ថានរបស់គេទទួលរងការបំផ្លិចបំផ្លាញ ឬបំបាត់ចោល នោះភាពចុះសម្រុងគ្នារវាងមនុស្ស វប្បធម៌ និងធម្មជាតិក៏ត្រូវទទួលការបង្អាក់ ឬបំផ្លាញចោលដែរ ។ ការផ្លាស់ប្តូរទីកន្លែងរស់នៅជាថ្មី របស់សហគមន៍ទាំងឡាយចេញពីទឹកដីកំណើត តាំងពីបុរាណកាលមក ដោយសារតែលទ្ធផលនៃគម្រោងការអភិវឌ្ឍសេដ្ឋកិច្ច ដែលមានទ្រង់ទ្រាយធំ ឬក៏ដោយសារចំបាំងទាស់ទែងគ្នាក្នុងស្រុកវែងអន្លាយ ក៏ធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមាន ទៅ



www.elibraryofcambodia.org

លើបរិស្ថានផងដែរ ។ នៅពេលដែលពួកគេធ្វើការផ្លាស់ប្តូរទីកន្លែង ចេញពីទឹកដីកំណើតរបស់ខ្លួនម្តងៗនោះ សហគមន៍ទាំងឡាយ មុខតែទទួលរងការបាត់បង់នូវមនោសញ្ចេតនានៃសម្ពន្ធភាពរបស់គេ ជាមួយបរិស្ថាន ដែលនៅជុំវិញជាក់ជាមិនខានឡើយ ។ម្យ៉ាងទៀត ការប្រតិបត្តិដែលជាទម្លាប់ជាយូរមកហើយរបស់គេ នឹងជួបភាពរអាក់រអួល ហើយរឿងនេះក៏នឹងធ្វើឱ្យមានការបំផ្លិចបំផ្លាញដល់បរិស្ថានថ្មីទៀតផង ។ តម្រូវការដើម្បីកសាងជីវភាពជាថ្មីឡើងវិញ របស់គេនៅទីកន្លែងថ្មីមិនធ្លាប់ស្គាល់ ឬជួបប្រទះពីមុនៗមក និងបង្កើតឱ្យមានបញ្ហាសង្គម និងភាពក្រីក្រផងដែរ ។ នៅទីបញ្ចប់ ហេតុការណ៍នេះតែងនាំទៅដល់ការអនុវត្តនូវការគ្រប់គ្រងធនធានមួយ ដែលមិនធានាបាននូវនិរន្តរភាព ពីព្រោះប្រជាពលរដ្ឋទាំងនោះត្រូវប្រឹងស្វះស្វែងរកប្រាក់ចំណូល ដើម្បីទប់ទល់នឹងជីវភាពមួយថ្មីស្រឡាងសាឡើងវិញ ។

## សំណួរពិភាក្សា

*១. ចូរកំណត់រកមនុស្សនៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ដែលធ្លាប់បានផ្លាស់ទីកន្លែងពីទឹកដីកំណើតរបស់គេមករស់នៅទីនេះ ។ តើមនុស្សទាំងនេះ ធ្លាប់បានប្រឈមមុខនឹងបញ្ហាអ្វីខ្លះ ? តើឥរិយាបថរបស់គេចំពោះបរិស្ថាននៅក្នុងមូលដ្ឋាន មានសភាពខុសគ្នាពីឥរិយាបថរបស់សមាជិកសហគមន៍ ដែលធ្លាប់បានរស់នៅក្នុងតំបន់នេះ អស់កាលយូរលង់មកហើយដែរឬទេ ?*

*២. តើសហគមន៍អាចមានវិធីបែបណា ដើម្បីលើកទឹកចិត្តចំពោះសមាជិកថ្មី ឱ្យពួកគេស្គាល់ច្បាស់នូវបរិស្ថានថ្មីរបស់ពួកគេ ?*



www.elibraryofcambodia.org

## ៣១. សត្វសេក និងដើមជ្រៃ



www.elibraryofcambodia.org

www.elibraryofcambodia.org

មេរៀន
៣ ៦

# ការធ្វើបុណ្យកុសលតាមរយៈអំណោយសួនឧទ្យាន

លំហអាកាស លំនៅឋានធម្មជាតិ ដើមឈើ ផ្កា និងរុក្ខជាតិគ្រប់ប្រភេទ ជាទីចាប់អារម្មណ៍ ឬទាក់ទាញចិត្តជាពិសេស ចំពោះពុទ្ធសាសនិកជន ដែលតែងយល់ថា ជានិមិត្តរូបនៃសេរីភាព និងធម្មជាតិ ដែលមិនត្រូវរំខានដោយសកម្មភាពរបស់មនុស្ស ។ មានសួនឧទ្យាន និងព្រៃសម្រាប់កំសាន្តជាច្រើនកន្លែង ដែលគេបានស្ថាបនានៅក្នុងសម័យពុទ្ធកាល ។ នៅវត្ត **ជេតពន** ក្នុងនគរ **កោសលៈ** មានសេដ្ឋីមួយរូបឈ្មោះ **អនាថបិណ្ឌិក** បានស្វែងរកទិញព្រៃសម្រាប់កំសាន្តមួយកន្លែង ដែលជាកម្មសិទ្ធិរបស់ព្រះអង្គម្ចាស់ព្រះនាម **ជេត** សំរាប់យកទៅថ្វាយព្រះសម្មាសម្ពុទ្ធ ។ ដើមដំបូងឡើយ ព្រះអង្គម្ចាស់ពុំមានបំណងលក់ដីនោះទេ ហើយក៏បានដាក់តម្លៃដ៏ខ្ពស់បំផុត ដោយកំណត់ជាចំនួនដុំមាស អាចក្រាលគ្របលើផ្ទៃដីនោះបាន ។ **អនាថ-បិណ្ឌិកសេដ្ឋី** បានសម្រេចថា នឹងទិញយកដីនោះឱ្យទាល់តែបាន ។ ដោយឃើញបំណងប្រាថ្នាដ៏ល្អរបស់គាត់យ៉ាងដូច្នេះ ព្រះអង្គម្ចាស់ **ជេត** មានការអៀនខ្មាស និងស្តាយក្រោយ ចំពោះអំពើដែលខ្លួនបានធ្វើ ហើយក៏បានធ្វើជាទានវិញនូវដីនោះ ដែលក្រោយមក **អនាថបិណ្ឌិកសេដ្ឋី** បានសាងជាវត្តមួយ ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បានគង់ចាំព្រះវស្សាច្រើនជាងគេបំផុត នៅក្នុងឧទ្យាននោះ ហើយ **អនាថបិណ្ឌិកសេដ្ឋី** ព្រមទាំងព្រះអង្គម្ចាស់ **ជេត** ទាំងពីរនាក់ ក៏បានទៅសោយសុខក្នុងសម្បត្តិសួគ៌ ទៅឋានស្ថានទេវលោក នៅក្នុងជាតិបន្ទាប់មកទៀត ។ នៅក្នុង **គម្ពីរសំយុត្តនិកាយ** ព្រះពុទ្ធជាម្ចាស់ទ្រង់បានត្រាស់សំដែងធម៌ដូចតទៅថា :

*" អ្នកដាំព្រៃឈើ និងឈើស៊ីផ្លែ ព្រមទាំងអ្នកទាំងឡាយណា ដែលបានស្ថាបនាផ្តល់ស្ពាន ទំនប់ទឹក ជីកអណ្តូងទឹក និងស្ថាបនាសាលាទាន ឱ្យទានទឹក អ្នកទាំងឡាយនោះ មានឈ្មោះថាឱ្យនូវទីជំរកដល់អ្នកដែលគ្មានផ្ទះសំបែងនោះដែរ : កុសលក៏នឹងកើតមានដល់បុគ្គលទាំងឡាយនោះគ្រប់ទិនទិវាករាត្រីឥតបីឃ្លៀងឃ្លាតឡើយ ។ ហើយដោយអំណាចផលានិសង្ស ដែលកើតឡើងពីអំពើត្រឹមត្រូវ និងគុណធម៌នៃបុគ្គលនោះ លុះចាកលោកនេះទៅនឹងបានទៅកើតក្នុងស្ថានសួគ៌ ជាមិនខានឡើយ "* ។

ការស្ថាបនាសួនឧទ្យាន និងព្រៃព្រឹក្សា សម្រាប់ប្រើប្រាស់ជាសាធារណៈបែបនេះ ត្រូវគេចាត់ថា ជាអំពើនៃមហាកុសលកម្មមួយ ។ សកម្មភាពទាំងឡាយរបស់ពុទ្ធសាសនិកជន ក្នុងអតីតកាល និងបច្ចុប្បន្ន ក្នុងការឱ្យសួនឧទ្យានជាទាន បានចូលរួមវិភាគទានយ៉ាងធំធេង ចំពោះការថែរក្សាការពារតំបន់ ដែលមាន



www.elibraryofcambodia.org

សោភណភាពធម្មជាតិ ឬដែលមានអត្ថន័យខាងវប្បធម៌ ។ វត្តអារាម ក៏ជាសួនឧទ្យានល្អប្រណីតនៃសន្តិភាព និងជាបដិសរណដ្ឋាន ពុំមែនសម្រាប់តែមនុស្សប៉ុណ្ណោះទេ សូម្បីតែចំពោះសត្វក៏ដូច្នោះដែរ ។ ពេលថ្មីៗនេះ វត្តចាស់នៅក្នុងខេត្តកំពង់ចាម បានដំណើរការបន្តធ្វើឡើងវិញ លើទំហំដីចំនួន ១០ ហិចតា ឱ្យទៅជាសួនឧទ្យានសាធារណៈមួយ ។ ប្រទេសកម្ពុជា ជាប្រទេសទីមួយហើយនៅតំបន់អាស៊ីភាគអាគ្នេយ៍ ដែលបានស្ថាបនាឧទ្យានជាតិមួយ នៅពេលដែលប្រាសាទអង្គរ និងព្រៃឈើព័ទ្ធជុំវិញនោះ បានត្រូវគេប្រកាសថា ជាតំបន់ការពារធម្មជាតិមួយ នៅក្នុងឆ្នាំ ១៩២៥ ។ នៅក្នុងទ្រង់ទ្រាយតូច ការបង្កើតសួនឧទ្យានក្នុងទីក្រុង និងទីប្រជុំជន បានជួយធ្វើឱ្យបរិស្ថានទីក្រុង ក្លាយទៅជាទីកន្លែងសប្បាយមនោរម្យ ដើម្បីរស់នៅ និងធ្វើការងារ ។

## សំណួរពិភាក្សា

១. *ចូរពិភាក្សាថា តើព្រោះហេតុអ្វីបានជាព្រះតេជព្រះគុណ-លោកអ្នកគិតថា ការមានសួនឧទ្យាន និងតំបន់ធម្មជាតិ ជារឿងសំខាន់សម្រាប់មនុស្សទាំងឡាយ ? តើសួនឧទ្យានមានតម្លៃខាងផ្នែកបរិស្ថានអ្វីខ្លះ ?*

២. *តើនៅក្នុងមូលដ្ឋានរបស់ព្រះតេជព្រះគុណ-លោកអ្នក មានដី ដែលអាចធ្វើជាសួនឧទ្យាន សំរាប់សហគមន៍ ដែរឬទេ ?*



www.elibraryofcambodia.org

៣៥. ការធ្វើបុណ្យកុសលតាមរយៈអំណោយសួនឧទ្យាន



www.elibraryofcambodia.org

www.elibraryofcambodia.org

## សកម្មភាព

# ការបង្កើតឱ្យមានបរិស្ថានសមស្រប

១. **វត្ថុបំណង** : ដើម្បីពិនិត្យពិចារណាបញ្ហាបរិស្ថាន និងសង្គម ដែលកើតមានឡើង នៅពេលដែលប្រជាពលរដ្ឋរស់នៅក្នុងបរិស្ថានមួយ ដែលគេមិនធ្លាប់ស្គាល់ ឬមិនសមស្រប និងដើម្បីអង្កេតស្រាវជ្រាវរកវិធី ឬមធ្យោបាយ ដើម្បីដោះស្រាយបញ្ហាអស់ទាំងនោះ ។

២. **សកម្មភាព** :

❶ ចូរបែងចែកក្រុមធំ ឱ្យទៅជាក្រុមតូចៗពីរ ។ រួចហើយឱ្យក្រុមតូចនីមួយៗសិក្សារឿងណាមួយនៅក្នុងចំណោមរឿងសិក្សាចំនួនពីរខាងក្រោមនេះ ហើយសូមឱ្យក្រុមនីមួយៗ អាន រួចពិភាក្សា និងសាកល្បងដោះស្រាយបញ្ហាទាំងឡាយ ដែលផ្តល់មកឱ្យនេះ ។

*រឿងសិក្សាទី ១ :*

សាខន កើតនៅក្រុងភ្នំពេញ ហើយរស់នៅទីនោះអស់រយៈពេល ១៦ ឆ្នាំ ។ ក្រោយពីឪពុកស្លាប់ទៅ ម្តាយកុមារសាខនក៏សម្រេចចិត្តថា នឹងផ្លាស់ប្តូរផ្ទះសំបែង ត្រឡប់ទៅនៅស្រុកកំណើតវិញ ។ ជីដូនជីតាខាងម្តាយសាខន រស់នៅក្នុងភូមិនោះនៅឡើយ ក្នុងជីវភាពដ៏សាមញ្ញមួយដោយការធ្វើស្រែ និងចិញ្ចឹមជ្រូក ។ នៅពេលដែលពួកគេបានមកដល់ភូមិកំណើតវិញ សាខនមានសេចក្តីតក់ស្លុតយ៉ាងក្រៃលែង ដោយបានឃើញថា ជីដូនជីតារបស់គេក្រីក្រណាស់ ឯផ្ទះរបស់គាត់ក៏តូចមែនទែន ហើយភូមិផ្ទាល់កខ្វក់ក្រៃណាកខ្វក់ ។ សាខនបាននឹករលឹកដល់មិត្តភក្តិជាសិស្សរបស់គេ និងទោចក្រយានយន្តរបស់ពួកគេ ។ សាខនបាននឹកទៅដល់ការទៅមើលភាពយន្ត និងទូរទស្សន៍ ។ វាក៏នឹកទៅដល់ការទៅទិញសំលៀកបំពាក់ដ៏ល្អៗមានម៉ូតចុងក្រោយគេបង្អស់នៅក្នុងផ្សារ ។ ហើយចុងបញ្ចប់ វាមានអារម្មណ៍កព្ភោចកំលោះម្នាក់ឯង និងមានទុក្ខព្រួយជាខ្លាំង ។ ម្តាយវា ក៏មានសេចក្តីទុក្ខព្រួយខ្លាំងដែរ ហើយក៏សំរេចចិត្តទៅកាន់វត្តនៅក្នុងមូលដ្ឋានមួយ ដើម្បីស្នើដល់ព្រះសង្ឃឱ្យជួយផ្តល់ដំបូន្មានដល់ពួកគេ ។

*តើព្រះតេជព្រះគុណ-លោកអ្នកមានការណែនាំអ្វីខ្លះ ដើម្បីផ្តល់ឱ្យដល់ម្តាយកុមារសាខនបាន ?*



www.elibraryofcambodia.org

*រឿងសិក្សាទី២:*

អ៊ំស្រី សម យី បានរស់នៅក្នុងភូមិដដែលនោះ អស់មួយជីវិតរបស់គាត់ចំនួន ៥០ ឆ្នាំកន្លងមកហើយ ។ គ្រួសាររបស់អ៊ំស្រី បានប្រកបរបរចិញ្ចឹមជីវិតអស់រយៈកាលជាច្រើនជំនាន់មកហើយ ដោយការដាំបន្លែយកទៅលក់ក្នុងផ្សារ នៅភូមិក្នុងមូលដ្ឋានរបស់គាត់ ។ ព្រោះតែដីធ្លីដែលភូមិរបស់អ៊ំស្រីតាំងនៅនោះជាដីល្អ និងសម្បូរដោយជីជាតិ មានពាណិជ្ជករអ្នកមានទ្រព្យសម្បត្តិមួយរូបមកពីក្រុងភ្នំពេញ ហើយបានទិញយកដីនោះទាំងអស់ ដោយបានសម្រេចចិត្តដាំដើមដូងប្រេងវិញ ។ គេបានអង្វរករ អ្នកភូមិទាំងអស់ឱ្យលក់ដីរបស់ខ្លួន ហើយឱ្យផ្លាស់ផ្ទះសំបែងទៅនៅកន្លែងផ្សេងទៀតនៅជិតវត្តវិញ ។ ដីធ្លីនៅទីនេះ ខុសប្លែកពីដីភូមិធ្លាប់រស់នៅ ។ ដូច្នេះអ៊ំស្រី សម យី មើលឃើញថា ខ្លួនគាត់មិនអាចដាំបន្លែបានយូរអង្វែងតទៅទៀតបានទេ ។ អ្នកស្រុកភូមិបានដឹងច្បាស់ថា ពួកគាត់ចាញ់បោកគេ ហើយឯប្រាក់លក់ដីភូមិទៀតសោតក៏ចាយអស់រលីងទៀត ហើយពួកគាត់ដឹងថា ពួកគាត់គ្មានផ្លូវនឹងចិញ្ចឹមខ្លួន និងគ្រួសាររបស់ពួកគាត់បានទេ ។ អ៊ំស្រី សម យី ក៏បានសម្រេចចិត្តទៅកាន់វត្ត នៅមូលដ្ឋាននោះ ដើម្បីស្នើសុំការណែនាំទូន្មានពីព្រះសង្ឃ ។

*តើព្រះតេជព្រះគុណ-លោកអ្នក គួរឱ្យដំបូន្មានយ៉ាងដូចម្ដេចខ្លះ ចំពោះអ៊ំស្រី សម យីនេះ ?*

❷ នៅពេលដែលក្រុមតូចៗ បានពិភាក្សារឿងសិក្សាទាំងពីររួចហើយ ចូរធ្វើការរួមប្រជុំជាក្រុមធំ ដើម្បីបង្ហាញដល់ក្រុមនិមួយៗ អំពីគំនិតមតិ និងសេចក្ដីសន្និដ្ឋាន ។

❸ ចូរពិភាក្សាពីការយល់ដឹង និងគោលគំនិតទាំងឡាយនៅក្នុងក្រុមធំ ។

## និរន្តរភាពក្នុងការអភិវឌ្ឍ គឺជាការការពារបរិស្ថាន



www.elibraryofcambodia.org

# ជំពូកទី ៤

# ការរក្សាការពារធនធានធម្មជាតិ

មេរៀន ៤ក : ការប្រើប្រាស់ធនធានធម្មជាតិ

មេរៀន ៤ខ : វត្តប្រតិបត្តិ ៤ យ៉ាង

មេរៀន ៤គ : អ្នកជំនួញ និង ដើមពោធិ

មេរៀន ៤ឃ : ការប្រើប្រាស់ដ៏ត្រឹមត្រូវនៃផលព្រឹក្ស

មេរៀន ៤ង : តម្លៃនៃផលព្រឹក្ស

*សកម្មភាព : ការប្រើប្រាស់ធនធានធម្មជាតិ*

www.elibraryofcambodia.org

www.elibraryofcambodia.org

មេរៀន
៤ ក

# ការប្រើប្រាស់ធនធានធម្មជាតិ

នៅក្នុងប្រពៃណីព្រះពុទ្ធសាសនា គេហៅបាលបុគ្គលត្រូវតែប្រមែប្រមូលសន្សំទ្រព្យសម្បត្តិ ដូចជាឃ្មុំតែងតែប្រមូលលំអងពីផ្កាដូច្នោះដែរ ។ ឃ្មុំមិនធ្វើឱ្យអន្តរាយដល់សោភណភាព ឬក្លិនក្រអូបរបស់ផ្កាទេ វាគ្រាន់តែប្រមូលលំអងផ្កា ដើម្បីបង្វែរលំអងផ្កានោះ ឱ្យទៅជាទឹកឃ្មុំដ៏ផ្អែមឈ្ងុយឈ្ងប់ប៉ុណ្ណោះ ។ យ៉ាងណាមិញ មនុស្សយើងគួរតែប្រើប្រាស់ធនធានពីធម្មជាតិយ៉ាងណា កុំឱ្យមានការខូចខាតអន្តរាយដល់បរិស្ថានឱ្យសោះ ។ ដូចជាគម្ពីរធម្មបទបានលើកឡើងថា :

*"ដូចជាសត្វឃ្មុំ មិនធ្វើឱ្យមានការខូចខាតដល់ផ្កា ពណ៌សម្បុរ*
*និងក្លិនរបស់ផ្កាឡើយ ។ រួចវាហើរចាត់ទៅ វាក្រេបយកតែ*
*ទឹកដមផ្កាប៉ុណ្ណោះឯង យ៉ាងណាមិញ បណ្ឌិតទាំងឡាយជា*
*អ្នកប្រាជ្ញគប្បីត្រាច់ចរទៅក្នុងភូមិ ស្រុក ក៏ដូច្នោះដែរ "* ។

ធនធានធម្មជាតិ គឺជាអ្វីៗដែលមាននៅក្នុងធម្មជាតិ និងមានតម្លៃចំពោះជីវិតរបស់មនុស្ស ។ ទឹក ព្រៃព្រឹក្សា រ៉ែក្នុងដី និងរុក្ខជាតិទាំងឡាយ ទាំងអស់នេះសុទ្ធតែជាធនធានធម្មជាតិ ។ ធម្មតា ធនធានធម្មជាតិមួយចំនួនអាចកើតឡើងជាថ្មីវិញបាន ។ ជាឧទាហរណ៍មាន ត្រី និងដើមឈើជាដើម អាចនឹងបន្តទៅតាមធម្មជាតិដែលបង្កើតវាយូរអង្វែង ល្គឹកណាយើងប្រើប្រាស់ធនធានទាំងនេះទៅតាមបែបបទមួយ ប្រកបដោយនិរន្តរភាព ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាបរិស្ថានជាច្រើនដែលយើងកំពុងជួបប្រទះនៅជុំវិញពិភពលោក និងនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ តែងបង្កឡើងដោយការប្រើប្រាស់ធនធានទាំងឡាយលើផែនដីនេះ ពីសំណាក់មនុស្សលោកមិនបានសមស្របល្អ ។ ធនធានទាំងឡាយ ត្រូវគេដាក់នៅក្រោមសម្ពាធកាន់តែខ្លាំងឡើង ដើម្បីផ្គត់ផ្គង់តម្រូវការឱ្យដល់សង្គមអ្នកប្រើប្រាស់ ទាំងផ្នែកឧស្សាហកម្ម និងទីក្រុង ។ ធនធានធម្មជាតិត្រូវតែវិនិច្ឆ័យតាមតម្លៃសេដ្ឋកិច្ចរបស់វាតែមួយគត់ ជាជាងតាមសមត្ថភាពទ្រទ្រង់ជីវិតសត្វលោកទេវិញ ។

វិធីទាញយកផលធនធានតាមបែបសម័យទំនើបៗជាច្រើន សុទ្ធតែធ្វើឱ្យមានការខូចបង់ ឬគ្រោះថ្នាក់ដល់បរិស្ថានជានិច្ច ។ ដរាបណាតម្រូវការចំពោះធនធានធម្មជាតិចេះតែកើនឡើង ដរាបនោះបច្ចេកទេសថ្មីៗ និងត្រូវគេអភិវឌ្ឍថែមទៀត ដើម្បីជួយឱ្យគេអាចទាញយកផលពីធនធានបានកាន់តែច្រើន និងលឿនរហ័សបំផុត ។ ហេតុដូច្នេះហើយ ទើបប៉ែលត្រូវគេជំនួសដោយត្រាក់ទ័រប៊ុលដូហ្សេរ ហើយពូថៅត្រូវ



www.elibraryofcambodia.org

ជំនួសដោយរណារច្រវ៉ាក់ និងសំណាញ់ជំនួសដោយគ្រឿងរំសេវផ្ទុះ ។ វិធីទាំងអស់នេះឯងអាចទាញយកផលពីធនធានក្នុងកិរិតធំឡើង ជាងដំណើរការកើតឡើងវិញសាជាថ្មី ដែលបានដឹកនាំទៅដល់ការហិនហោចនៃធនធានធម្មជាតិ និងញ៉ាំងឱ្យមានការរេចរឹលបរិស្ថានទៀតផង ។

## សំណួរពិភាក្សា

*១. តើសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ប្រមូលធនធានធម្មជាតិតាមរបៀបយ៉ាងដូចម្តេចខ្លះ ?*

*២. តើវិធីប្រមែប្រមូលយកធនធានធម្មជាតិអ្វីខ្លះ ទៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ដែលធ្វើឱ្យហិនហោចខូចខាតដល់បរិស្ថាន ?*

*៣. តើមានវិធីជ្រើសរើសណាផ្សេងទៀត ដែលប្រកបដោយនិរន្តរភាព អាចត្រូវគេយកទៅប្រើប្រាស់ជំនួសបានដែរឬទេ ?*

*៤. ចូរពិភាក្សាអំពីវិធីរកប្រាក់ចំណូល ដែលគ្មានគ្រោះថ្នាក់ដល់អ្នកដទៃ ?*



www.elibraryofcambodia.org

៤ក. ការប្រើប្រាស់ធនធានធម្មជាតិ



www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន**
**៤ ២**

# វត្តប្រតិបត្តិ ៤ យ៉ាង

ពាក្យប្រៀនប្រដៅជាដំបូងបង្អស់ចំពោះគ្រហស្ថទាំងឡាយ ដែលកំពុងឈានចូលទៅក្នុងភេទជាបព្វជិត ជាភាសាបាលីហៅថា " *និស្ស័យ ៤* " (ចត្តារោ និស្សយធម្មា) ឬវត្តប្រតិបត្តិ ឬកិច្ចវត្ត ៤ យ៉ាងក៏បាន ។ វត្តប្រតិបត្តិទាំង ៤ យ៉ាងនេះ គឺមានការត្រាច់ចរបិណ្ឌបាត ការស្លៀកដណ្តប់ដោយសំពត់សាមញ្ញធម្មតា និងចាស់ ការរស់នៅទៀបគល់ឈើ និងការប្រើប្រាស់ឱសថធម្មជាតិ (តិណទេស ទឹកនោមជាដើម) ។ ថ្វីត្បិតតែស្តាប់ទៅ ហាក់ដូចជាបំផ្លើសនៅក្នុងបរិបទសម័យទំនើបនេះក៏ដោយ ក៏ការប្រតិបត្តិទាំង ៤ យ៉ាង ឬនិស្ស័យទាំង ៤ នោះ បង្ហាញឱ្យឃើញពីការប៉ងប្រាថ្នារបស់ព្រះពុទ្ធ ចំពោះភិក្ខុសង្ឃទាំងឡាយ ឱ្យចេះរស់នៅយ៉ាងសាមញ្ញ ចេះសន្សំសំចៃ និងរស់នៅស្របទៅតាមធម្មជាតិ ។ វត្តប្រតិបត្តិទាំង ៤ នោះ មានតួនាទីជាការរំលឹកឱ្យឃើញថា មនុស្សរស់នៅត្រូវតែពឹងផ្អែកលើធម្មជាតិ សម្រាប់តម្រូវការជាច្រើនរបស់ខ្លួន រួមមានម្ហូបអាហារ សំលៀកបំពាក់ និងទីជម្រក ។ រឿងនេះវាផ្ទុយគ្នាយ៉ាងខ្លាំងទៅនឹងបញ្ញត្តិស័ព្ទនៃ " ទ្រឹស្តីនៃការផ្គត់ផ្គង់គ្រឿងឧបភោគ-បរិភោគ " [១៥] ដែលប្រព្រឹត្តតាមសញ្ញាណនៃការបំពេញបំណងប្រាថ្នារបស់បុគ្គលម្នាក់ៗ ដោយគ្មានកំរិតព្រំដែនឡើយ ។

នៅក្នុងទសវត្សរ៍កន្លងទៅនេះ ប្រជាពលរដ្ឋក្នុងតំបន់ទីក្រុងនៅកម្ពុជា ចេះតែកើនឡើង ។ ទីក្រុងបានធ្វើឱ្យមនុស្សម្នា ឱ្យស្ថិតនៅក្នុងបរិស្ថានមួយ ដែលធ្វើឡើងដោយមនុស្ស ហើយបានកាត់ផ្តាច់ពួកគេឱ្យចេញផុតពីបរិស្ថានធម្មជាតិរបស់គេតែម្តង ។ សង្គមទីក្រុង បានលើកទឹកចិត្តទ្រឹស្តីនៃការផ្គត់ផ្គង់គ្រឿងឧបភោគ-បរិភោគ ហើយធនធានធម្មជាតិទាំងឡាយ បានកាត់បន្ថយមកត្រឹមជាតម្លៃរូបិយប័ណ្ណតែមួយប៉ុណ្ណោះ ។ ឈើ ត្រី និងរ៉ែ បានក្លាយទៅជាវត្ថុប្រើប្រាស់ ដែលគេធ្វើអាជីវកម្មដោះដូរគ្នានៅក្នុងសេដ្ឋកិច្ចទីផ្សារ ។ ជាការសំខាន់ណាស់ ដែលត្រូវចងចាំថា ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ទោះជានៅជនបទ ឬទីក្រុងក៏ដោយ ពិតជាផុតទៅនៅតែពឹងពាក់ទៅលើធនធានធម្មជាតិ ដែលប្រទេសផ្តល់ឱ្យ ។ ធនធានធម្មជាតិអាចត្រូវគេបម្លែងឱ្យទៅជាប្រាក់កាស ប៉ុន្តែប្រាក់កាសមិនអាចដាក់ជំនួសបរិស្ថានធម្មជាតិបានឡើយ ។

---

[១៥] *ទ្រឹស្តីនៃការផ្គត់ផ្គង់គ្រឿងឧបភោគ-បរិភោគ ៖ ការចិញ្ចឹមជីវិតដោយបំផ្លើស និងសេវាកម្មនៅក្នុងសេដ្ឋកិច្ចរូបិយវត្ថុ ។*



www.elibraryofcambodia.org

## សំណួរពិភាក្សា

១. តើធនធានធម្មជាតិណាខ្លះ ដែលសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ឱ្យតម្លៃខ្ពស់ជាងគេបំផុត ?

២. តើធនធានទាំងឡាយនោះ មានតម្លៃសម្រាប់តែប្រាក់កាស ឬក៏ព្រោះតែធនធានទាំងនោះ បំពេញដល់តម្រូវការនៅក្នុងមូលដ្ឋាន ?

៣. តើអ្នកណាខ្លះ បានទទួលផលប្រយោជន៍អំពីធនធានទាំងនោះ ជាប្រាក់កាស ? ហើយតើមានអ្នកណាខ្លះ ដែលទទួលបានផលប្រយោជន៍អំពីធនធានទាំងនោះ ពុំមែនជាប្រាក់កាស ?

៤. ចូរជ្រើសរើសយកធនធានធម្មជាតិមួយណាក៏បាន នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក (ឧទាហរណ៍ : ដើមឈើ ប្រភពទឹក រ៉ែ និងសត្វជាដើម) ហើយចូរនាំគ្នាពិភាក្សារកហេតុផលថា ព្រោះហេតុអ្វី បានជាធនធាននោះ ជាវត្ថុមានតម្លៃចំពោះសហគមន៍ ផ្សេងពីប្រាក់កាសទៅវិញ ។



www.elibraryofcambodia.org




៤១. ចក្កប្បតិបត្តិ ៤ យ៉ាង

www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន**
**៤ គ**

# អ្នកជំនួញ និង ដើមពោធិ

នាទីក្រុងពារាណសីនៃប្រទេសឥណ្ឌា មានអ្នកជំនួញមួយក្រុមបានសំរេចចិត្តថា នឹងសម្រាកនៅក្រោមដើមពោធិធំមួយដើម មានម្លប់ដ៏ត្រជាក់ល្អិម ។ នៅពេលដែលពួកគេកំពុងសម្រាកនោះ ពួកគេបានកត់សំគាល់ឃើញមែកពោធិនៅទិសខាងកើត មានទឹកកំពុងស្រក់ធ្លាក់ចុះ ពេលនោះពួកគេក៏បានសម្រេចចិត្តថា នឹងកាត់មែកពោធិនោះ ដើម្បីផឹក និងងូត ។ លំដាប់មកទៀត មែកនៅទិសខាងត្បូងក្រឡេកមើលទៅឃើញមានបាយ និងសាច់ ហើយពួកគេក៏បានកាប់មែកទាំងនោះទៀតយ៉ាងរហ័ស ដើម្បីបំពេញបំណងនៃការស្រេកឃ្លានរបស់ខ្លួន ។ បន្តបន្ទាប់មក មាននារីពេញវ័យ ២៥ រូប បានលេចធ្លោឡើង នៅត្រង់មែកផ្នែកខាងលិច ហើយឈ្មួញទាំងនោះបានកាប់មែកនោះទៀត ដើម្បីបំពេញតម្រេកត្រេកត្រអាលរបស់ពួកគេទៅ ។ នៅពេលនោះ ពួកឈ្មួញក៏បានសម្លឹងទៅរកមែកនៅទិសខាងជើង ដែលនៅសល់ជាបន្តទៀត ស្រាប់តែប្រទះឃើញត្បូងពេជ្រដ៏មានតម្លៃលេចធ្លោឡើងដែរ ។ ឈ្មួញទាំងអស់ ក៏នាំគ្នាកាប់មែកនោះទៀត ហើយក្រសោបយកត្បូងពេជ្រដ៏មានតម្លៃទាំងនោះដាក់ទៅក្នុងថង់រៀងៗខ្លួន ។ ឈ្មួញទាំងអស់មិនអាចជឿបាននូវជោគវាសនារបស់ខ្លួនឡើយ ហើយដោយសារសេចក្ដីលោភលន់របស់ខ្លួន ពួកគេក៏បានសម្រេចចិត្តថា នឹងកាប់រំលំ និងគាស់គល់ដើមពោធិតែម្ដង ដោយសង្ឃឹមថា នឹងទទួលទ្រព្យសម្បត្តិល្អៗថែមទៀត ។ នៅខណៈនោះ មានពស់នាគរាជ ២៥ ក្បាល បានលេចធ្លោឡើង ដោយមានកម្លាំងសម្រាប់ការពារ រួមជាមួយទាហាន ៣០០ នាក់ ប្រដាប់ដោយធ្នូស្នា និងទាហាន ៦.០០០ នាក់ទៀត ប្រដាប់ដោយខែលសម្រាប់ការពារផង ។ ឈ្មួញទាំងនោះ ស្រឡាំងកាំងភិតភ័យណាស់ ហើយក៏បានលើកដៃប្រណម្យធ្វើអភិវន្ទនា និងសុំខមាទោស ។ ឈ្មួញទាំងអស់បានស្លាប់ ហើយរូបកាយរបស់ពួកគេបានក្លាយទៅជាផេះផង់ធូលី លើកលែងតែឈ្មួញម្នាក់ប៉ុណ្ណោះនៅរស់រានមានជីវិត ។ ចាប់តាំងពីខណៈនោះមក ឈ្មួញដែលនៅសល់ពីស្លាប់នោះ បានដាក់បញ្ញត្តហាមប្រាមដល់អ្នកបំរើក្រោមឱវាទទាំងឡាយរបស់គាត់ និងជនដទៃទៀត មិនឱ្យកាប់រំលំដើមឈើទាំងពួងឡើយ ។

រឿងនេះ ឆ្លុះបង្ហាញឱ្យឃើញពីជំនឿក្នុងព្រះពុទ្ធសាសនា ដែលថា អំពើលោភលន់ តែងតែធ្វើឱ្យធម្មជាតិមានការផ្លាស់ប្ដូរ ហើយថាដំណើរការរបស់ធម្មជាតិ អាចទទួលរងឥទ្ធិពលដោយសារសកម្មភាពរបស់មនុស្សជាតិ ។ ព្រះពុទ្ធសាសនាជឿថា ថ្វីបើការប្រែប្រួល ឬការផ្លាស់ប្ដូរ ជាកត្តាមួយមាននៅជាប់ស្រាប់ជាមួយធម្មជាតិក៏ដោយ តែការធ្លាក់ចុះសីលធម៌របស់សង្គមមនុស្ស តែងតែពន្លឿនដំណើរការនៃការប្រែប្រួល



www.elibraryofcambodia.org

ដែលប្រឆាំងដល់សុខុមាលភាព និងសុភមង្គលរបស់មនុស្សទៅវិញ ។ ម្ល៉ោះហើយទើបព្រះពុទ្ធសាសនាធ្លាប់បានអះអាងថា វាមានការទាក់ទងជិតស្និទ្ធមួយ រវាងចរិយាធម៌ ឬសីលធម៌របស់មនុស្ស និងគុណភាពនៃបរិស្ថាន និងជីវិត ។ មនុស្សជាតិ ត្រូវតែប្រើប្រាស់ធនធានធម្មជាតិ ដើម្បីបំពេញចិត្ត និងតម្រូវការជាមូលដ្ឋានទាំងឡាយរបស់ខ្លួនប៉ុណ្ណោះបានហើយ ។ កាលបើយើងចាប់ផ្ដើមធ្វើអាជីវកម្មយកផលលើធនធានធម្មជាតិ ដើម្បីមហិច្ឆតាតែមួយមុខនោះ បរិស្ថាន និងគុណភាពនៃជីវិតរបស់មនុស្សជាតិទាំងមូល មុខតែទទួលរងទុក្ខវេទនាខ្លោចផ្សាចៀសមិនផុត ។

*"ដើមឈើដែលធ្លាប់ឱ្យម្លប់ដ៏ត្រជាក់ត្រឈៃដល់អ្នកសម្រាប់អង្គុយលេង*
*ឬដេកលេងតាមតម្រូវការ អ្នកមិនត្រូវបែកកាប់ មែកធាងវាចុះទេ*
*អំពើព្រៃផ្សៃគ្មានត្រាប្រណី នឹងកើតឡើង" (ជាតកភាគទី៤)* ។

## សំណួរពិភាក្សា

១. *តើមានធនធានអ្វីខ្លះនៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ត្រូវគេប្រើប្រាស់ដើម្បីបំពេញតម្រូវការជាមូលដ្ឋាននោះ ?*

២. *តើមានធនធានអ្វីខ្លះ ត្រូវគេប្រើប្រាស់ ដើម្បីត្រឹមតែសេចក្ដីលោភលន់ ឬមហិច្ឆតានោះ ?*

៣. *តើមានការខុសប្លែកគ្នាយ៉ាងណា ក្នុងភាពដែលអាចរកបាននៃធនធានធម្មជាតិ នៅពេលដែលធនធានទាំងនោះ ត្រូវគេប្រមូលផលសម្រាប់បំពេញសេចក្ដីត្រូវការ ឬក៏សម្រាប់តែសេចក្ដីលោភលន់តែមួយមុខ ? បើមាន ចូរពិភាក្សារកហេតុផលចំពោះរឿងនេះ ។*



www.elibraryofcambodia.org



៤៨. អ្នកចំណូញ និងដើមកោធិ

www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន**
**៤ ឃ**

# ការប្រើប្រាស់ដ៏ត្រឹមត្រូវនៃផលព្រឹក្ស

តាំងពីដើមមកម្ល៉េះ សហគមន៍ព្រះពុទ្ធសាសនាភាគច្រើន ច្រើនរស់នៅក្នុងព្រៃ និងរស់រានមានជីវិតទៅបានអាស្រ័យលើផលានុផលព្រៃឈើ មានដូចជាផ្លែឈើជាដើម ។ ព្រៃឈើ និងរុក្ខជាតិមានតួនាទីដ៏សំខាន់មួយ ក្នុងការបំរើសេចក្តីត្រូវការរបស់ភិក្ខុសង្ឃ សំរាប់ប្រើជាចង្ហាន់ សម្ភារៈសំណង់ និងឱសថ ។ ម្យ៉ាងទៀត ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ទ្រង់បានសំដែងថា គេគប្បីយកចិត្តទុកដាក់ពិតគួរ នូវអ្វីដែលគេទទួលបានពីព្រៃឈើ ។ នាសម័យថ្ងៃមួយ ព្រះបាទ **ពិម្ពិសារ** ជាព្រះរាជានៃ **មគធរដ្ឋ** ប្រទេសឥណ្ឌា បានប្រគេនផ្លែស្វាយនៅក្នុងឧទ្យានរបស់ព្រះអង្គ ដល់ព្រះភិក្ខុសង្ឃមួយក្រុម ប៉ុន្តែមានព្រះភិក្ខុអង្គខ្លះ បានបេះផ្លែស្វាយនោះយកទាំងអស់ ដោយពុំមានទុកឱ្យនៅសេសសល់មួយផ្លែណាឡើយ ។ ពេលនោះ ពុទ្ធបរិស័ទបានរិះគន់ទិតៀនចំពោះអំពើខុសឆ្គង របស់ព្រះភិក្ខុទាំងនោះ ព្រោះតែជាអំពើមិនសមរម្យទាល់តែសោះ ។ នៅពេលដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បានព្រះសណ្តាប់នូវឧបទ្ទវហេតុនេះហើយ ទើបព្រះអង្គទ្រង់បានបញ្ញត្តិវិន័យទប់ទល់នឹងសកម្មភាពដ៏ហួសហេតុនេះ ។ ព្រះអង្គទ្រង់បានប្រកាសថា **តិរូទេ** ម្នាលភិក្ខុ អ្នកទាំងឡាយអាចឆាន់បានតែផ្លែឈើ៣ ដែលរើសពីដី ឬប្រសិនបើផ្លែឈើទាំងនោះត្រូវគេវិកប្បដោយភ្លើង កាំបិត ក្រចកម្រាមដៃ ឬប្រសិនបើផ្លែឈើនោះគ្មានគ្រាប់ ឬក៏គ្រាប់នោះត្រូវគេឆ្កឹះយកចេញរួចហើយតែប៉ុណ្ណោះ ។ ច្បាប់នេះ ថ្វីត្បិតតែជាច្បាប់សម្រាប់ភិក្ខុទាំងឡាយមែនក៏ដោយ តែគេក៏អាចយល់បានថា វាជាច្បាប់ទូទៅមួយស្តីអំពីរបៀបដែលគេត្រូវប្រើប្រាស់ផ្លែឈើធម្មជាតិផងដែរ ។ មានរឿងមួយទៀត និទានអំពីព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលបានទទួលផ្លែស្វាយ ហើយបន្ទាប់មក ព្រះអង្គក៏បានប្រគល់គ្រាប់ស្វាយនោះឱ្យដល់កសិករវិញ ដើម្បីយកទៅបណ្តុះដាំ ។

សំរ៉ង ជាផ្លែឈើដ៏ពិសេសមួយបែប ដែលច្រើនមានដុះនៅភូមិភាគឦសាន នៃប្រទេសកម្ពុជា ។ គេនិយមយកផ្លែឈើនេះ ទៅបរិភោគជាមួយស្ករធ្វើជាបង្អែម ។ ជាប្រពៃណីទៅហើយ ផ្លែសំរ៉ងនេះ គេច្រើនប្រមូលកើបយក ក្រោយពេលដែលផ្លែទាំងនោះវាទុំ ហើយជ្រុះធ្លាក់ទៅលើដី ឬមួយគេឡើងបេះតែម្តង ។ ទោះបីជាយ៉ាងនេះក៏ដោយ នៅពេលដែលតម្រូវការទីផ្សារ និងតម្លៃរបស់វាកាន់តែឡើងខ្ពស់យ៉ាងឆាប់រហ័សនៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ អ្នកស្រុកអ្នកភូមិ បាននាំគ្នាផ្តើលប្រមូលផ្លែសំរ៉ងនេះ ដោយកាប់



www.elibraryofcambodia.org

ផ្លូវលំទាំងដើមតែម្តង ដើម្បីអាចឱ្យពួកគេប្រមូលកើបយកភ្លាមៗបានទាំងអស់ ។ ការអនុវត្តរបៀបនេះនឹងធ្វើឱ្យផ្លែស្រវៀងនេះ កាន់តែខ្សត់ទៅៗ នៅពេលអនាគតដ៏ឆាប់ខាងមុខនេះជាក់ជាមិនខានឡើយ ។

## សំណួរពិភាក្សា

*១. តើមានផ្លែឈើអ្វីខ្លះ ដែលមានដុះនៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ?*

*២. តើគេប្រមូលផលផ្លែឈើទាំងនោះ បានប៉ុន្មានដងក្នុងមួយឆ្នាំ ?*

*៣. តើវិធីប្រមូលផលទាំងនេះ អាចជាវិធីធានាបាននូវនិរន្តរភាពដែរឬទេ ?*

*៤. ចូរពិភាក្សារកវិធីដែលព្រះតេជព្រះគុណ-លោកអ្នក អាចជួយជំរុញឱ្យមានការប្រមូលផលផ្លែឈើដែលធានាបាននូវនិរន្តរភាព ។*



www.elibraryofcambodia.org



៤ឃ. ការប្រើប្រាស់ដីត្រឹមត្រូវនៃផលព្រឹក្ស

www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន ៤១**

# តម្លៃនៃផលព្រឹក្ស

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បានអនុញ្ញាតឱ្យភិក្ខុទាំងឡាយ ប្រើប្រាស់បាននូវផលិតផលរបស់ព្រៃឈើ មានដូចជា ឬស មើម ដើម មែក សំបក ស្លឹក ផ្លែ ផ្កា និងជ័រឈើជាដើម សម្រាប់ព្យាបាលភិក្ខុសង្ឃទាំងឡាយដែលមានជំងឺ ។ ដោយមានការទទួលស្គាល់នូវតួនាទីដ៏សំខាន់ៗ របស់រុក្ខជាតិ និងបន្លែបង្ការទាំងពួង នៅក្នុងជីវភាពរស់នៅរបស់មនុស្សជាតិ និងភាវៈរស់ដទៃទៀតនោះ ព្រះសម្មាសម្ពុទ្ធសមណគោតមនៃយើង ទ្រង់បានប្រៀនប្រដៅថា គេមិនគប្បីបំផ្លាញជីវិតរុក្ខជាតិឡើយ ។ នៅក្នុងវិន័យរបស់បព្វជិត ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ទ្រង់ដាក់បញ្ញត្តយ៉ាងតឹងតែងទៅក្នុងគម្ពីរ **អង្គុត្តរនិកាយ** ថា ភិក្ខុទាំងឡាយមិនត្រូវធ្វើឱ្យរបួសដល់ជីវិតរុក្ខជាតិតាមរបៀប ឬរូបភាពណាមួយក៏ដោយ ។

> *"បុគ្គលណាមួយដែលចៀសវាងរួចអំពីការធ្វើឱ្យរបួសគ្រោះថ្នាក់ដល់ជីវិតគ្រាប់ពូជ និងជីវិតរុក្ខជាតិ... លះបង់ចោលនូវសេចក្តីសៅហ្មង ដែលកើតអំពីបំណងអាក្រក់ ប្រកបដោយចិត្តចេញផុតពីបំណងអាក្រក់ បុគ្គលនោះនឹងរស់នៅដោយមានការការពារចំពោះសុខុមាលភាព និងមានអារម្មណ៍ប្រកបដោយមេត្តា ករុណា ចំពោះគ្រប់ភាវៈ ដែលមានជីវិតទាំងអស់ បុគ្គលនោះមានឈ្មោះថា បានសំអាតនូវចិត្តរបស់ខ្លួន ដែលសៅហ្មងដោយបំណងអាក្រក់"* ។

សហគមន៍ជាច្រើន នៅគ្រប់ទីកន្លែងនៃប្រទេសកម្ពុជា នៅតែពឹងផ្អែកទៅលើផលិតផលគ្រប់បែបយ៉ាងរបស់រុក្ខជាតិ ដើម្បីបំពេញបន្ថែមក្នុងការចិញ្ចឹមជីវិតរបស់ពួកគេ ។ អាហារព្រៃមានដូចជា តំណទេស ទឹកឃ្មុំ ស្លឹកឈើ មើមឈើ ផ្លែឈើ និងរុក្ខជាតិតូចៗជាដើម បានផ្តល់ឱ្យយើងនូវជីវជាតិប្រូតេអ៊ីន និងសារធាតុខនិជ ឬរ៉ែដ៏សំខាន់ៗ មាននៅក្នុងអាហារបរិភោគរាល់ថ្ងៃ ហើយក៏តែងតែប្រើប្រាស់ជាឱសថបានទៀតផង ។ ឬស្សី និងផ្តៅត្រូវនិយមប្រើប្រាស់ជាខ្លាំង នៅតាមសហគមន៍ទាំងឡាយ សម្រាប់ស្ថាបនាផ្ទះសំបែង បំពង់ បូមទឹក អន្ទាក់ដាក់សត្វព្រៃ លប ឬទ្រូដាក់ត្រី ឧបករណ៍ចំអិនអាហារ សិប្បកម្មកន្ទេល និងរបងផ្ទះ ។ សហគមន៍អស់ទាំងនេះ តែងតែយល់ដឹងយ៉ាងច្បាស់ អំពីតម្លៃនៃផលិតផលព្រៃឈើ ចំពោះជីវភាពរស់នៅរបស់ពួកគេ ហើយច្រើនតែប្រើប្រាស់ធនធានព្រៃឈើទាំងនេះ ដោយមានការយកចិត្តទុកដាក់ ដើម្បីទ្រទ្រង់



www.elibraryofcambodia.org

ឱ្យដល់ការផ្គត់ផ្គង់មួយ ដែលមានលំនឹងជានិច្ច ។ ការគាស់រំលើងឫស ឬការកាប់រំលំដើមឈើស៊ីផ្លែ ដើម្បីគ្រាន់តែប្រមូលយកផ្លែតែមួយមុខប៉ុណ្ណោះ ជាលទ្ធផល ធនធានទាំងអស់មុខតែខ្សោះទៅៗ នៅបណ្តាឆ្នាំខាងមុខនេះជាមិនខានឡើយ ។

## សំណួរពិភាក្សា

*១. តើសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ប្រើប្រាស់ផលិតផលព្រៃឈើអ្វីខ្លះ ?*

*២. តើផលិតផលព្រៃឈើ ត្រូវគេប្រើប្រាស់ បានត្រឹមត្រូវដែរឬទេ ?*

*៣. តើព្រះតេជព្រះគុណ-លោកអ្នក យល់ថា វិធីប្រមូលផល និងគ្រប់គ្រងផលិតផលព្រៃឈើ អាចត្រូវកែលំអបានដោយរបៀបណា ?*



www.elibraryofcambodia.org

## ៤០. តម្លៃនៃផលព្រឹក្ស



www.elibraryofcambodia.org

www.elibraryofcambodia.org

# សកម្មភាព

## ការប្រើប្រាស់ធនធានធម្មជាតិ

១. វត្ថុបំណង ៖ ដើម្បីកំណត់នូវធនធានធម្មជាតិទាំងឡាយ ដែលកំពុងប្រើប្រាស់ដោយសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក និងដើម្បីពិនិត្យមើលមធ្យោបាយ ដែលប្រើសំរាប់ទាញយកផលពីធនធានទាំងនោះ ។

២. សកម្មភាព ៖

❶ ចូរពិភាក្សាថា តើធនធានធម្មជាតិណាមួយ ដែលសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នកបានប្រើប្រាស់ ។

❷ ចូរពិភាក្សាពីរបៀបទាញយកផលពីធនធានធម្មជាតិ ។

❸ តើវិធីទាញយកផលទាំងនេះ មានឥទ្ធិពលប៉ះពាល់អ្វីខ្លះទៅលើបរិស្ថាន និងភាពបំរុងទុកនៃធនធានទាំងនេះ ?

❹ តើយើងអាចធ្វើអ្វីខ្លះ ដើម្បីជំរុញឱ្យមានការទាញយកផលពីធនធានទាំងនោះ ប្រកបដោយនិរន្តរភាព ?

*សកម្មភាពនេះអាចរៀបចំធ្វើជាក្រុមតូចៗ ដោយឱ្យក្រុមនីមួយៗបង្កើតតារាងមួយ ដូចមានខាងក្រោមនេះ ៖*

| *ធនធាន* | *វិធីទាញយកផល* | *ឥទ្ធិពល* | *ដំណោះស្រាយ* |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |

❺ ចូរពិភាក្សាលទ្ធផលរបស់ព្រះតេជព្រះគុណ-លោកអ្នក ទៅក្នុងក្រុមធំ ។

**អភិវឌ្ឍន៍ត្រូវមានបរិស្ថានល្អ**



www.elibraryofcambodia.org

www.elibraryofcambodia.org

# ជំពូកទី ៥

# តម្លៃនៃព្រៃឈើ

មេរៀន ៥ក : តម្លៃនៃព្រៃឈើ

មេរៀន ៥ខ : ដើមឈើសំខាន់ៗក្នុងឆាកជីវិតរបស់ព្រះពុទ្ធ

មេរៀន ៥គ : ដើមពោធិព្រឹក្ស

មេរៀន ៥ឃ : ព្រៃឈើសហគមន៍នៅប្រទេសកម្ពុជា

មេរៀន ៥ង : ព្រះភិក្ខុ និង រុក្ខទេវី

*សកម្មភាព* : *តម្លៃនៃព្រៃឈើ*

www.elibraryofcambodia.org

www.elibraryofcambodia.org

មេរៀន
៥ ក

# តម្លៃនៃព្រៃឈើ

មុនពេលក្លាយជាព្រះពុទ្ធ ព្រះអង្គបានសំរេចចិត្តលះបង់លោកិយនេះ ដោយការចាកចេញពីព្រះបរមរាជវាំងដ៏ល្អប្រណីត ទៅស្នាក់អាស្រ័យនៅក្នុងព្រៃ ក្នុងគុហា និងគង់ប្រថាប់នៅក្រោមដើមឈើ អស់ពេលជាច្រើនឆ្នាំ ។ នៅក្នុង **គម្ពីរសុត្តន្ត** ព្រះពុទ្ធជាម្ចាស់ ទ្រង់បានលើកសរសើរចំពោះបុគ្គលណា ដែលអង្គុយនៅទៀបគល់ឈើ ក្នុងបំណងប្រាថ្នាចង់បានវិវេកភាព និងការប្រាថ្នាតិចតួចបំផុត ។ ព្រះអង្គទ្រង់ជ្រាបថា ភាពស្ងប់ស្ងាត់ និងវិវេកដ្ឋាន អាចជួយមនុស្សឱ្យទទួលបានការតាំងសមាធិ ដើម្បីចំរើនភាវនាអំពីចិត្តរបស់បុគ្គលម្នាក់ៗ ។ ភាពស្ងប់ស្ងាត់ និងវិវេកដ្ឋាននេះ ជួយដល់ភិក្ខុសង្ឃ ឱ្យមើលឃើញការចំរើនជឿនលឿនទៅមុខនៃជីវិត នៅក្នុងព្រៃ ទៅតាមរបៀបធម្មជាតិ មើលឃើញមែកឈើពណ៌បៃតងខៀវខ្ចី ផ្លែ និងស្លឹកឈើទុំ ហើយជាទីបញ្ចប់ ឃើញស្លឹកងាប់ជ្រុះចាកទងធ្លាក់មកដី ដោយប្រៀបធៀបហេតុការណ៍នេះ ជាមួយនឹងទិដ្ឋភាពធម្មជាតិ នៃជីវិតរបស់មនុស្សទាំងពួង ដែលកើតមកហើយរមែងតែចាស់ ឈឺ និងស្លាប់ទៅវិញដូច្នេះដែរ ។ សមដូចគាថាមួយក្នុង **ធម្មបទដ្ឋកថា** ដែលថ្លែងអំពីតម្លៃនៃព្រៃឈើយ៉ាងដូច្នេះថា :

*" ព្រៃព្រឹក្សា គឺជាកន្លែងមនោរម្យ ដែលនៅទីនោះ*
*មនុស្សសាមញ្ញធម្មតា ស្វះស្វែងរកមិនឃើញការសប្បាយ ។*
*មនុស្សព្រាសចាកតណ្ហា និងត្រេកអរនៅទីនោះ*
*សម្រាប់មនុស្សទាំងឡាយ ដែលមិនស្វែងរកការសប្បាយ*
*ខាងផ្លូវកាមកិលេស " ។*

ទោះបីជាព្រៃឈើនៅប្រទេសកម្ពុជា កំពុងទទួលរងការវិនាសអន្តរាយ យ៉ាងឆាប់រហ័សយ៉ាងណាក៏ដោយ ក៏ព្រៃឈើនៅតែមានសារសំខាន់បំផុតនៅឡើយ ចំពោះការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋខ្មែរ និងក៏ជាធនធានធម្មជាតិដ៏សំខាន់មួយរបស់ប្រទេសជាតិដែរ ។ ព្រៃឈើបង្កឱ្យមានភ្លៀងធ្លាក់ និងជួយការពារដីកុំឱ្យហូរច្រោះ ។ ព្រៃឈើស្រូបយកពន្លឺព្រះអាទិត្យ និងឧស្ម័នកាបូនិច ដើម្បីបង្កើតបានជាខ្យល់អុកស៊ីសែនបញ្ចេញមកក្នុងបរិយាកាសវិញ សំរាប់ឱ្យមនុស្ស សត្វ មានខ្យល់ដកដង្ហើមបាន ។ ព្រៃឈើជួយរក្សាបរិយាកាសឱ្យត្រជាក់ជាប់ជានិច្ច ។ ព្រៃឈើផ្តល់ទីជម្រក និងអាហារសម្រាប់សត្វព្រៃតិរច្ឆាន និងបក្សាបក្សីគ្រប់ប្រភេទ ។ ព្រៃឈើអាចជួយកាត់បន្ថយការបំពុលដោយសូរសំឡេង និងខ្យល់កខ្វក់ ឬពុល ។ ព្រៃ



www.elibraryofcambodia.org

ឈើផ្តល់ដល់អ្នកស្រុកភូមិ នូវផលប្រយោជន៍ដ៏ទូលំទូលាយ ខាងសេដ្ឋកិច្ចនៅក្នុងមូលដ្ឋាន រួមមានទាំងផ្ទះសម្បែង អុសដុត ម្ហូបអាហារ គ្រឿងសង្ហារៈសំណង់ និងឱសថគ្រប់ប្រភេទ ។ ធនធានធម្មជាតិដ៏មានតម្លៃបែបនេះ គប្បីយើងម្នាក់ៗត្រូវនាំគ្នាថែរក្សា ការពារឱ្យបានម៉ត់ចត់ ប្រកបដោយសេចក្តីគោរពស្រឡាញ់ និងការគិតគូរយកចិត្តទុកដាក់ជាទីបំផុត ។ ការបំផ្លិចបំផ្លាញព្រៃឈើនៅប្រទេសកម្ពុជាបច្ចុប្បន្ន តាមរយៈនៃការប្រើប្រាស់ដ៏ហួសប្រមាណ នូវធនធានធម្មជាតិ ឬការកាប់រំលំឈើលក់នោះ នឹងមានផលដ៏សែនអាក្រក់ ចំពោះវិស័យកសិកម្ម រួចមកចំពោះសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងប្រទេសជាតិទាំងមូល ។

## សំណួរពិភាក្សា

១. *ចូរពិភាក្សា អំពីផលប្រយោជន៍នៃព្រៃឈើទាំងឡាយ ដែលសហគមន៍នៅក្នុងមូលដ្ឋានរបស់ព្រះតេជព្រះគុណ-លោកអ្នក ទទួលបាន ។ ព្រះតេជព្រះគុណ-លោកអ្នក អាចធ្វើតារាងបញ្ជីអំពីផលប្រយោជន៍ទាំងនោះ ទៅតាមប្រធានបទខាងក្រោមដូចតទៅនេះ :*

- *ផ្នែកបរិស្ថាន*
- *ផ្នែកសង្គម*
- *ផ្នែកចិត្តគំនិត និងវប្បធម៌*
- *ផ្នែកសេដ្ឋកិច្ច*

២. *ចូរពិភាក្សារកវិធីសាស្ត្រ ដែលអាចធ្វើឱ្យសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ឱ្យមានការយល់ដឹងកាន់តែច្រើនថែមទៀត អំពីតម្លៃផ្សេងៗគ្នានៃព្រៃឈើនៅប្រទេសកម្ពុជា ។*



www.elibraryofcambodia.org

៥៣. គុណនៃព្រៃឈើ



www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន**
**៥ ២**

# ដើមឈើសំខាន់ៗក្នុងឆាកជីវិតរបស់ព្រះពុទ្ធ

មានដើមឈើសំខាន់ៗជាច្រើន ដែលត្រូវគេលើកយកមករៀបរាប់ នៅក្នុងមួយដំណើរនៃឆាកជីវិតរបស់ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ។ ព្រះអង្គទ្រង់ប្រសូតនៅក្រោមដើម **សាលព្រឹក្ស** នៅពេលដែលព្រះមាតារបស់ព្រះអង្គ កំពុងយាងទៅកាន់ឧទ្យាន **លុម្ពិនី** ។ ពេលដ៏សំខាន់ជាងគេបំផុត នៃព្រះជន្មជីវិតរបស់ព្រះអង្គនោះ គឺពេលដែលព្រះអង្គ បានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ហើយបានក្លាយទៅជាព្រះសព្វញ្ញុពុទ្ធនៅក្រោមដើម **ពោធិព្រឹក្ស** ។ សូម្បីតែក្រោយពីព្រះអង្គបានត្រាស់ដឹងហើយភ្លាម ព្រះអង្គបានចំណាយពេលអស់ប្រាំពីរថ្ងៃ ក្រោមដើមពោធិដដែលនេះ ដើម្បីតាំងសមាធិចំរើនមេត្តាភាវនា អំពីការសំរេចបរមសុខរបស់ព្រះអង្គ ។ នៅសប្តាហ៍ទីពីរ ព្រះអង្គបានតាំងសមាធិ នៅចំពីមុខដើមពោធិព្រឹក្សដដែល ។ ក្រោយមក ព្រះអង្គបានចំណាយពេលមួយសប្តាហ៍បន្ទាប់ទៀត ដើម្បីតាំងសមាធិ ចំរើនមេត្តាភាវនានៅក្រោមដើមជ្រៃមួយឈ្មោះថា **អជបាលនិគ្រោធ** ។ ប្រាំពីរថ្ងៃក្រោយមកទៀត ព្រះអង្គបានយាងទៅទិសខាងត្បូង ដើម្បីទៅគង់នៅក្រោមដើមឈើមួយទៀតឈ្មោះ **រាជាយតនៈ** ដែលនៅទីនោះ ព្រះអង្គបានចំណាយពេលចំនួនប្រាំពីរថ្ងៃដែរ ។ ក្រោយពីចំណាយពេលអស់ចំនួន ៤៥ ព្រះវស្សា ដើម្បីត្រាច់ចរនៅក្នុងលំហព្រៃ ពីភូមិមួយទៅភូមិមួយទៀត ដើម្បីសំដែងព្រះធម៌ដល់ជនានុជនរួចមក ព្រះអង្គបានជ្រើសយកការចូលព្រះបរិនិព្វាន នៅចន្លោះដើម **សាលព្រឹក្ស** នៅក្នុងព្រៃសាលវ័ន នាទីក្រុងដ៏តូចមួយឈ្មោះ **កុសិនារា** ។

ពូជឈើទាំងអស់នេះ បានទទួលការប្រតិបត្តិគោរពយ៉ាងខ្ពង់ខ្ពស់ ដោយពុទ្ធមាមកជនទាំងឡាយនៅទូទាំងពិភពលោក ប្រកបដោយកតញ្ញូតាធម៌ ចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់រហូតមកទល់សព្វថ្ងៃនេះ ។ ដើមឈើដ៏ធំស្ដឹមស្ដៃ ដូចជាដើមសាលព្រឹក្ស និងដើមជ្រៃជាដើម ត្រូវបានគេទទួលស្គាល់គោរពបូជា ដូចជាដើមពោធិ នៅក្នុងសម័យពុទ្ធកាលដែរ ។ លទ្ធផលជាវិជ្ជមានដោយចំពោះនៃកិរិយាបថនេះ គឺជាការថែរក្សាការពារពូជឈើសំខាន់ៗ ទាំងអស់នេះឯង ។ ជាពិសេស ដើមពោធិបានត្រូវគេការពារ និងត្រូវដាំឡើងវិញម្តងហើយម្តងទៀតនៅគ្រប់ទីកន្លែង ដែលព្រះពុទ្ធសាសនាបានចាក់ឫសប្រតិស្ឋាន ។ ការផ្សារភ្ជាប់រវាងដើមឈើទាំងអស់ជាមួយព្រះពុទ្ធសាសនាបែបនេះ បានត្រូវគេផ្តល់ឈ្មោះក្នុងភាសាឡាតាំងថា "ហ្វីគុស រេលីហ្សូសា" (Ficus religiosa) ។



www.elibraryofcambodia.org

## សំណួរពិភាក្សា

១. តើមានឈើសំខាន់ៗ ចំនួនប៉ុន្មានដើម ដែលព្រះតេជព្រះគុណ-លោកអ្នក អាចស្គាល់នៅក្នុង ឬនៅជុំវិញសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ?

២. តើដើមឈើទាំងនេះ មានការទទួលស្គាល់ដោយសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ថាជាដើមឈើទាក់ទងក្នុងព្រះពុទ្ធសាសនាដែរឬទេ ?

៣. ចូរពិភាក្សារកវិធី ដែលព្រះតេជព្រះគុណ-លោកអ្នក អាចប្រើ ដើម្បីលើកកំពស់ការយល់ដឹងរបស់សហគមន៍ ស្តីពីសារសំខាន់នៃដើមឈើទាំងនេះ ។



www.elibraryofcambodia.org



៥១. ដើមឈើសំខាន់ៗក្នុងឆាកជីវិតរបស់ព្រះពុទ្ធ



www.elibraryofcambodia.org

www.elibraryofcambodia.org

មេរៀន
៥ គ

# ដើមពោធិព្រឹក្ស

ពាក្យ " **ពោធិ** " មានន័យថា " **ការត្រាស់ដឹង**" រីឯការត្រាស់ដឹងនោះទៀតសោត គឺឋិតនៅក្រោមដើមពោធិព្រឹក្ស ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ បានសម្រេចនូវសម្មាសម្ពោធិញ្ញាណ ។ មានព្រះពុទ្ធជាច្រើនអង្គនៅក្នុងអតីតកាល ក៏ទ្រង់បានសម្រេចនូវការត្រាស់ដឹង នៅក្រោមពូជដើមពោធិព្រឹក្សផ្សេងៗគ្នាដែរ ។ ព្រះពុទ្ធព្រះនាម **កក្កុសន្ធោ** បានត្រាស់ដឹងនៅក្រោមដើមពោធិព្រឹក្សដ៏ធំមួយឈ្មោះ **សិរីសា** ឬដើមច្រេស ហើយព្រះពុទ្ធ **ព្រះកោនាគមនោ** បានត្រាស់ដឹងនៅក្រោមដើមពោធិព្រឹក្សឈ្មោះ **ឧទុម្ពរា** ឬដើមល្វា និងព្រះពុទ្ធព្រះនាម **កស្សបោ** បានត្រាស់ដឹងនៅក្រោមដើមពោធិព្រឹក្សឈ្មោះ **និគ្រោធា** ឬដើមជ្រៃ ។ រីឯព្រះពុទបច្ចុប្បន្ន **គោតមោ** បានត្រាស់ដឹងនៅក្រោមដើមពោធិព្រឹក្សឈ្មោះ **អស្សត្ថា** ឬដើមពោធិ ហើយអនាគតព្រះពុទ្ធ **មេត្តេយ្យោ** ឬ **ព្រះសិរអារ្យមេត្រី** និងបានសម្រេចការត្រាស់ដឹងនៅក្រោមដើមពោធិព្រឹក្ស ឈ្មោះ **នាគា** ឬដើមខ្លឹង ។

ខ្លឹមសារនៃដើមពោធិព្រឹក្ស មានគូសបញ្ជាក់ស្រាប់នៅក្នុង **គម្ពីរមេរិនិព្វានសុត្ត** ។ មហាជននៅទីក្រុង **សាវត្ថី** បានធ្វើសក្ការបូជានៅវត្តមួយក្នុងឧទ្យាន **ជេតពន** ហើយបានដាក់គ្រឿងក្រអូប និងកម្រងមាលា របស់គេនៅទ្វៀបទ្វារគន្ធកុដិ ។ មានសេដ្ឋីមួយរូបឈ្មោះ **អនាថបិណ្ឌិកៈ** បានដឹងនូវរឿងនេះ ហើយបានទៅជួបព្រះ **អានន្ទ** ដើម្បីសុំឱ្យក្រាបទូលសួរបន្ត ចំពោះព្រះសម្មាសម្ពុទ្ធជាអម្ចាស់ អំពីភាពដ៏សមរម្យនៃអំពើទាំងឡាយនេះ ។ ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ទ្រង់មានព្រះពុទ្ធដីកាឆ្លើយតបថា តម្លៃនៃការធ្វើសក្ការបូជាចំពោះចេតិយ៍ដ៏ពិតប្រាកដទាំងឡាយនោះ គឺ **សារីរិកចេតីយ** (ចេតិយ៍សម្រាប់ដំកល់អដ្ឋិធាតុរបស់ព្រះពុទ្ធ បរមគ្រូជាម្ចាស់) **បរិភោគៈចេតីយ៍** (ចេតិយ៍សម្រាប់ដំកល់តម្វាយចង្ហាន់) និង **ឧទ្ទិសិកៈចេតីយ៍** (ចេតិយ៍សម្រាប់ការតាំងសមាធិភាវនា) ។ ប៉ុន្តែព្រះអង្គមានព្រះពុទ្ធដីកាបន្តទៀតថា ចេតិយ៍មួយដែលគេអាចគោរពបាននៅគ្រប់ពេលវេលានោះ គឺដើម **ព្រះពោធិព្រឹក្ស** នេះឯង ។ នៅពេលនោះ **ព្រះមហាអានន្ទត្ថេរ** បានក្រាបទូលសុំព្រះដ៏មានព្រះភាគជាអម្ចាស់ ចំពោះកូនដើមព្រះពោធិព្រឹក្សនៅក្នុងដែន **គយា** ដើម្បីឱ្យព្រះ **អានន្ទត្ថេរ** អង្គនោះ អាចបណ្តុះដាំនៅទ្វៀបទ្វារវត្ត **ជេតពន** បាន ។ ព្រះមហាថេរមួយព្រះអង្គព្រះនាមព្រះ **មោគ្គល្លាន** បាននាំផ្លែពោធិព្រឹក្សទុំឆ្អោះទៅកាន់វត្ត ហើយនៅក្នុងវេលារសៀល កូន



www.elibraryofcambodia.org

ឈើទាំងនោះ បានត្រូវគេយកទៅដាំនៅក្នុងសុវណ្ណភាជន៍មួយ ។ ដើមពោធិព្រឹក្ស ដែលត្រូវគេបណ្ដុះផ្សាំចេញពីកូនឈើពោធិព្រឹក្សនោះ ត្រូវគេឱ្យឈ្មោះថា **អានន្ទពោធិ** ។

តាំងពីពេលនោះមក ដើមពោធិព្រឹក្សបានត្រូវគេចាត់ទុកថា ជាដើមឈើពិសិដ្ឋ និងត្រូវគេថែរក្សា និងការពារទូទាំងប្រទេសទាំងឡាយណា ដែលកាន់ព្រះពុទ្ធសាសនា ។ ព្រះបាទ **នរោត្តម** ក៏ធ្លាប់បាននាំយកដើម **មហាពោធិព្រឹក្ស** ពីប្រទេសស្រីលង្កា មកកាន់ប្រទេសកម្ពុជាមកដាំដែរ នៅក្នុងពុទ្ធសករាជ ២៤៣០ នៃគ្រិស្តសករាជ ១៨៨៧ ។ ដើមពោធិនេះ បានត្រូវគេយកទៅដាំនៅមុខវត្ត **ព្រះបទុមវតី** ក្រុងភ្នំពេញ ដែលនៅរស់នៅឡើយ រហូតមកដល់សព្វថ្ងៃនេះ ។ នៅក្នុងអំឡុងពេលនៃការធ្វើធម្មយាត្រាលើកទី ១ នាឆ្នាំ ១៩៩២ កន្លងមក កូនឈើពោធិព្រឹក្សជាច្រើន ដែលជាអំណោយមកពីប្រទេសស្រីលង្កា បានត្រូវគេយកទៅដាំនៅក្នុងវត្តទាំងឡាយ នៅតាមផ្លូវធ្វើធម្មយាត្រានេះ ។

## សំណួរពិភាក្សា

*១. តើវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក មានដើមពោធិព្រឹក្សនឹងគេដែរឬទេ ? បើមាន តើដើមពោធិព្រឹក្សនោះ មានអាយុប៉ុន្មានហើយ ? ហើយតើបានមកពីកន្លែងណា ?*

*២. ចូរពិភាក្សាអំពីវិធី ដែលព្រះតេជព្រះគុណ-លោកអ្នក អាចទាក់ទាញអារម្មណ៍ចំពោះសារសំខាន់នៃដើមពោធិព្រឹក្ស នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ។*



www.elibraryofcambodia.org

៥៣. ដើមពោធិព្រឹក្ស



www.elibraryofcambodia.org

**មេរៀន**
**៥ ឃ**

# ព្រៃឈើសហគមន៍នៅប្រទេសកម្ពុជា

បញ្ញត្តិនៃស័ព្ទ " **ព្រៃឈើសហគមន៍** " បានទៅជាផ្នែកមួយនៃពុទ្ធិកប្បវេណី ជាយូរអង្វែងណាស់មកហើយ ។ ព្រៃឈើសហគមន៍ បានទទួលការអភិវឌ្ឍឡើង នៅពេលដែលមហាជននៅមូលដ្ឋានយកចិត្តទុកដាក់ថែរក្សា និងគ្រប់គ្រងព្រៃឈើ ដែលពួកគេតែងតែពឹងអាស្រ័យ សម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគេ ។ ប្រជាពលរដ្ឋមូលដ្ឋានបានប្រើប្រាស់ព្រៃឈើ ទៅតាមបែបបទមួយដែលធានាបាននូវនិរន្តរភាព ដើម្បីឱ្យព្រៃឈើនោះនៅស្ថិតស្ថេរគង់វង្ស ជាធនធានធម្មជាតិមួយ ដែលអាចប្រើបានយូរមិនចេះរីងស្ងួត ។ ព្រៃឈើសហគមន៍ក៏រួមមានទាំងការដាំឈើឡើងវិញ នៅទីព្រៃឈើណាដែលទទួលការរេចរឹល ឬក៏អាចជាការដាំ និងការយកចិត្តទុកដាក់ថែទាំកូនឈើតូចៗ នៅក្នុងក្របខ័ណ្ឌសហគមន៍ ដូចជាវត្ត និងសាលារៀនជាដើម ។

គំរោងការនានានៃព្រៃឈើសហគមន៍ អាចផ្តួចផ្តើមគំនិតឡើង ពីសំណាក់ព្រះសង្ឃតែម្តង ។ ព្រះភិក្ខុ **ឡៀម គឹមគេង** បានបង្កើតអង្គការ **សន្តិសេនា** នៅក្នុងខេត្តស្វាយរៀង ដើម្បីទទួលរ៉ាប់រងធ្វើការថែរក្សាការពារបរិស្ថាន ។ ព្រៃឈើសហគមន៍មួយកន្លែងនៅ *ព្រៃចំការគគីរទី១* នៅក្នុងស្រុកចន្ទ្រា ខេត្តស្វាយរៀង បានត្រូវគេអភិវឌ្ឍឡើង ដោយការច្របាច់បញ្ចូលគ្នា រវាងលទ្ធិព្រះពុទ្ធសាសនា និងជំនឿប្រពៃណីរបស់សហគមន៍ ដើម្បីការពារ និងដាំដើមឈើឡើងវិញ នៅតំបន់ព្រៃឈើនេះ ។ អ្នកស្រុកទាំងឡាយនៅទីនោះ បានទទួលការបណ្តុះបណ្តាល អំពីការយល់ដឹងបរិស្ថាន និងសារសំខាន់នៃការថែរក្សាការពារ និងការដាំព្រៃឈើឡើងវិញ ។ គម្រោងការនេះ បានជួយបង្កើនការយល់ដឹងរបស់អ្នកស្រុកភូមិ អំពីតម្លៃនៃព្រៃឈើបន្ថែមទៅលើការកែតំបន់ព្រៃឈើឡើងវិញ នៅក្នុងខេត្តដែលមានធនធានធម្មជាតិដ៏ខ្សត់ខ្សោយ ។ វត្ត និងព្រះសង្ឃទាំងឡាយ អាចជួយផ្តួចផ្តើមជាគំនិត ឱ្យមានជាគំរោងការព្រៃឈើសហគមន៍បែបនេះបាន និងជួយឧត្តម្ភការរៀបចំ ឱ្យមានការប្រជុំសហគមន៍ជាទៀងទាត់ រៀបចំកាលវិភាគការងារបានត្រឹមត្រូវ និងជួយដោះស្រាយជម្លោះបានសមស្រប ទៅតាមលទ្ធភាព ។



www.elibraryofcambodia.org

## សំណួរពិភាក្សា

១. តើនៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក មានតំបន់ណាមួយ ដែលអាចកំណត់យក និង ជ្រើសរើស ទុកធ្វើជាព្រៃឈើសហគមន៍ដែរឬទេ ?

២. ចូរពិភាក្សារកវិធី ដែលអាចជួយសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ឱ្យចេះបង្កើតព្រៃឈើសហគមន៍នឹងគេមួយ ។

៣. ចូរពិភាក្សាអំពីផលប្រយោជន៍ និងបញ្ហា ដែលព្រៃឈើសហគមន៍ អាចផ្តល់ដល់សហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ។

៤. ចូរពិភាក្សារកវិធីដោះស្រាយ បញ្ហាទាំងឡាយរបស់ព្រៃឈើសហគមន៍មួយ ដែលនឹងកើតមានឡើង ។



www.elibraryofcambodia.org

៥ឃ. ព្រៃឈើសហគមន៍នៅប្រទេសកម្ពុជា



www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន**
**៥ ១**

# ព្រះភិក្ខុ និង រុក្ខទេវី

ក្នុងកាលកន្លងយូរលង់ណាស់មកហើយ មានភិក្ខុមួយអង្គគង់នៅដែន **អាឡវី** បានសម្រេចព្រះទ័យថា នឹងស្ថាបនាកុដិមួយខ្នងដោយព្រះអង្គឯង ម្ល៉ោះហើយ ទើបភិក្ខុអង្គនោះ ក៏បានចាប់ផ្ដើមកាប់រំលំដើមឈើមួយដើម ។ រុក្ខទេវី ដែលកំពុងស្នាក់អាស្រ័យនៅក្នុងដើមឈើនោះ ក៏បានចេញមកឃាត់ភិក្ខុអង្គនោះ កុំឱ្យកាប់រំលំដើមឈើនេះអី ក៏ប៉ុន្តែលោកបានបដិសេធនឹងការអង្វរករនេះ ។ ពេលនោះរុក្ខទេវីបានគិតថា ព្រះភិក្ខុអង្គនោះ មុខតែមានការអាណិតអាសូរជាមិនខាន កាលបើបានបង្ហាញកូនរបស់ខ្លួន ។ គិតយ៉ាងដូច្នេះហើយ រុក្ខទេវីក៏បានដាក់កូនរបស់នាងនៅលើមែកឈើនោះទៅ ។ ទោះបីជាយ៉ាងនេះក៏ដោយ ព្រះភិក្ខុនោះមិនអាចទប់កម្លាំងពូថៅ ដែលលើកយារអស់មួយទំហឹងឡើងលើជាស្រេចនោះបានទេ ហើយក៏បានជ្រុលជ្រុសកាប់ចំដៃក្មេងនោះទៅ ។ ភ្លាមនោះ រុក្ខទេវីក៏បានទប់កំហឹង និងសន្ដុះចិត្តរបស់នាងទាន់ ដែលប៉ងសម្លាប់ព្រះភិក្ខុនោះជាការសងសឹក ហើយបានប្រែចិត្តទៅរាយការណ៍រឿងរ៉ាវដ៏អាក្រក់នេះ ប្រគេនចំពោះព្រះសម្មាសម្ពុទ្ធជាអម្ចាស់វិញ ។ ព្រះសព្វញ្ញុពុទ្ធបរមគ្រូទ្រង់បានសរសើរនាងទេពធីតា ចំពោះសេចក្ដីអត់ធ្មត់ផ្ទាល់ខ្លួនរបស់នាង ហើយទ្រង់ក៏ប្រគល់ដើមឈើមួយផ្សេងទៀត ដល់នាងទេពធីតានោះ ដើម្បីរស់នៅជាបន្តទៀត **(ទិន័យឆាចិត្តិយៈ)** ។

ព្រះសម្មាសម្ពុទ្ធបរមគ្រូ ទ្រង់បានឆ្លៀតឱកាសនេះ ដើម្បីដាក់បញ្ញត្តដល់ព្រះភិក្ខុទាំងឡាយ ឱ្យគោរពប្រតិបត្តិតាមសិក្ខាបទ ដែលថែងមិនបង្កឱ្យមានរបួស ឬខូចខាតដល់រុក្ខជាតិ និងដើមឈើគ្រប់ប្រភេទឡើយ ។ នេះជារឿងដ៏មានសារសំខាន់មួយ ព្រោះថា រឿងនេះបង្ហាញប្រាប់ឱ្យយើងដឹងពីវិធី ដែលមនុស្សទាំងពួង រួមទាំងភិក្ខុទាំងឡាយផង រៀនសូត្រមេរៀនបរិស្ថាន តាមរបៀបនៃបទពិសោធន៍ ដែលធ្លាប់ទទួលបាន ។ ផលវិបាកទាំងស្រុង នៃការបំផ្លិចបំផ្លាញបរិស្ថាន តែងតែត្រូវគេយល់ដឹងច្បាស់ និងទទួលស្គាល់ក្រោយពេលដែលការបំផ្លិចបំផ្លាញនោះបានកើតឡើងរួចទៅហើយ ។ ជំនឿលើរុក្ខទេព្ដា ត្រូវបានគេប្រើប្រាស់ជាញឹកញាប់ នៅក្នុងយុទ្ធនាការការពារបរិស្ថាន នៅក្នុងបណ្ដាប្រទេសកាន់ព្រះពុទ្ធសាសនា ដើម្បីលើកទឹកចិត្តឱ្យដល់មនុស្សទាំងពួង ឱ្យចេះស្រឡាញ់គោរពព្រៃឈើ និងឱ្យចេះលះបង់ចោលនូវសកម្មភាពដែលបង្កឱ្យមានការវិនាសអន្តរាយ ។ រឿងនេះ ក៏បានដាស់តឿនក្រើនរំលឹកដល់យើងរាល់គ្នា អំពីវិធីដែលជំនឿអារក្សអ្នកតាមានតាំងពីបុរាណកាលមក អាចផ្ដល់ការការពារធម្មជាតិបានយ៉ាងណានោះ ។ ប្រជាពលរដ្ឋ



www.elibraryofcambodia.org

នៅជនបទភាគច្រើន និងជនអន្តោប្រវេសន៍នៅប្រទេសកម្ពុជាជឿថា នៅលើពិភពលោកយើងនេះមានភាវៈមានមហិទ្ធិឫទ្ធិខ្លាំងក្លា ដែលជាញឹកញាប់ គេសំដៅទៅលើឥទ្ធិពលរបស់អារក្ស អ្នកតាទាំងឡាយ ។ អារក្ស អ្នកតាត្រូវគេជឿថា មានអានុភាព និងមានឥទ្ធិពលទៅលើសុខភាព សុខុមាលភាព និងវិបុលភាពរបស់ភូមិស្រុក ។ តំបន់ព្រៃឈើចាស់ៗ ដែលនៅហ៊ុំព័ទ្ធភូមិស្រុក តែងតែត្រូវគេជឿថា ជាតំបន់ដែលមានទេព្ដារក្សាព្រៃព្រឹក្សា ប្រកបដោយមហិទ្ធិឫទ្ធិខ្លាំងពូកែ ហើយដើមឈើទាំងនេះ ត្រូវគេហាមមិនឱ្យកាប់ឡើយ ។ ព្រោះតែទីកន្លែងដ៏ពិសិដ្ឋរបស់សហគមន៍ និងព្រៃអ្នកតា ជាកន្លែងដែលគេហាមប្រាមមិនឱ្យប៉ះពាល់ ឬប្រើប្រាស់ពីសំណាក់មនុស្សលោកនោះ តំបន់ទាំងនេះបានចូលរួមវិភាគទានដ៏សំខាន់មួយ នៅក្នុងការថែរក្សាការពារបរិស្ថាន ។

## សំណួរពិភាក្សា

១. *តើមានដើមឈើណាខ្លះ នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ដែលមានទេវតា អារក្ស អ្នកតាថែរក្សា ?*

២. *តើជំនឿទាំងនេះ បានជួយការពារតំបន់ព្រៃឈើ នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ដែរឬទេ ?*

៣. *ចូរពិភាក្សាពីវិធីដែលទេវតា អារក្ស អ្នកតា តាមបែបពុទ្ធសាសនា អាចត្រូវយកមកប្រើក្រោយៗមកទៀត នៅក្នុងឯកសារ និងសកម្មភាពទាំងឡាយនៃការយល់ដឹងបរិស្ថាន ។*



www.elibraryofcambodia.org

៥១. ព្រះភិក្ខុ និងរុក្ខទេវី



www.elibraryofcambodia.org

www.elibraryofcambodia.org

## សកម្មភាព

# តម្លៃនៃព្រៃឈើ

១. វត្ថុបំណង : ដើម្បីពិចារណាអំពីតម្លៃនៃព្រៃឈើ នៅក្នុងលក្ខខណ្ឌនៃផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច បរិស្ថាន វប្បធម៌ និងសង្គម ។

២. សកម្មភាព :

❶ ចូរបំបែកក្រុមធំឱ្យទៅជាក្រុមតូចៗ ដែលមានសមាជិក៤ រូបក្នុងមួយក្រុមៗ និងផ្តល់ក្រដាសធំមួយសន្លឹក មានរូបដើមឈើមួយដើមផង ដល់ក្រុមនិមួយៗ ។

❷ រួចចូរផ្តល់ប្រធានបទណាមួយ ក្នុងចំណោមប្រធានបទដូចតទៅនេះ ឱ្យក្រុមនិមួយៗ បំពេញកិច្ចការ :

- ❑ ផលប្រយោជន៍សេដ្ឋកិច្ច
- ❑ ផលប្រយោជន៍បរិស្ថាន
- ❑ ផលប្រយោជន៍វប្បធម៌
- ❑ ផលប្រយោជន៍សង្គម ។

❸ ចូរឱ្យក្រុមនិមួយៗពិភាក្សាគូរកតម្លៃនៃព្រៃឈើ នៅក្នុងលក្ខខណ្ឌនៃប្រធានបទនិមួយៗដែលគេបានផ្តល់ជូន ។ ក្រុមនិមួយៗអាចសរសេរ ឬគូរគំនូរបំពេញ ស្តីពីផលប្រយោជន៍ផ្សេងៗ នៅលើរូបគំនូរដើមឈើនេះ ។

❹ ចូរប្រមូលក្រុមនិមួយៗ ឱ្យទៅជាក្រុមធំវិញ ហើយសូមឱ្យក្រុមនិមួយៗ ឡើងរាយការណ៍ពីគំនិតមតិរបស់ក្រុមខ្លួន ដែលទទួលបានពីការពិភាក្សា ។



www.elibraryofcambodia.org

## ព្រៃឈើ ឬ វាលរហោស្ថាន ?

១. **វត្ថុបំណង** : ដើម្បីពិចារណាអំពីផលវិបាកនៃការកាប់ឈើក្នុងទ្រង់ទ្រាយធំ ។

២. **សកម្មភាព** :

❶ ចូរបំបែកក្រុមធំជាពីរក្រុមតូចៗ ហើយផ្ដល់ក្រដាសមួយសន្លឹកធំដល់ក្រុមនិមួយៗ ។

❷ ចូរឱ្យក្រុមទី ១ គូររូបទេសភាពណាមួយ តាមការនឹកស្រមៃ ដែលពណ៌នាអំពីទិដ្ឋភាពនៃតំបន់មួយ ដែលដើមឈើទាំងឡាយត្រូវបានគេកាត់ផ្ដួលរំលំអស់ ។ ឯក្រុមទី ២ ចូរឱ្យគូររូបគំនូរទេសភាពមួយ តាមការនឹកស្រមៃ ដែលពណ៌នាអំពីទិដ្ឋភាពនៃតំបន់មួយ ដែលគ្របដណ្ដប់ដោយព្រៃឈើ ។

❸ ចូររៀបជាក្រុមធំឡើងវិញ រួចពិភាក្សាគ្នា និងប្រៀបធៀបរូបភាពទាំងពីរនេះ ។

**ការអភិរក្សធនធានធម្មជាតិ គឺរក្សាការពារបរិស្ថាន**



www.elibraryofcambodia.org

# ជំពូកទី ៦

# ការស្វែងយល់តម្លៃ

# សត្វព្រៃ

មេរៀន ៦ក : សត្វព្រៃ និង ព្រៃព្រឹក្សា

មេរៀន ៦ខ : ករុណាធម៌របស់ព្រះពុទ្ធចំពោះសត្វ

មេរៀន ៦គ : ធម៌ក្នុងព្រះពុទ្ធសាសនា

មេរៀន ៦ឃ : ព្រានប្រម៉ាញ់ និង សត្វធំ

មេរៀន ៦ង : រឿងសុវណ្ណសាម

មេរៀន ៦ច : បុរសបរិភោគសុតសត្វ

មេរៀន ៦ឆ : នាគ

*សកម្មភាព : ការស្វែងយល់តម្លៃសត្វព្រៃ*

www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន**
**៦ ក**

# សត្វព្រៃ និង ព្រៃព្រឹក្សា

ព្រៃព្រឹក្សា រមែងតែងត្រូវបានគេលើកយកមកអធិប្បាយជាញឹកញាប់ នៅក្នុងពុទ្ធប្បវត្តិ ដោយចាត់ទុកជាលំនៅឋានធម្មជាតិរបស់សត្វព្រៃ រាប់តាំងពីសត្វល្អិតតូចតាចបំផុត រហូតទៅដល់សត្វព្រៃធំល្អស្រស់ឆើតឆាយ ។ មានរឿងព្រេងព្រះពុទ្ធសាសនាមួយ បានលើកឯណាលអំពីបុរសកាប់ឈើម្នាក់ ដែលបានប្រកបការងារប្រចាំថ្ងៃរបស់គាត់ជាអ្នកពុះអុសលក់ ។ មានថ្ងៃមួយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់យាងកាត់តាមទីនោះ បានឈប់ ហើយពន្យល់ថា កិច្ចការរបស់អ្នក គឺកាប់សម្លាប់សត្វស្រមោចទាំងឡាយ ដែលកំពុងរស់នៅក្នុងឈើនោះឯងប៉ុណ្ណោះ ។ ពេលនោះ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ទ្រង់បានសំដែងព្រះធម្មទេសនាពីការគោរពដ៏ជ្រាលជ្រៅ ចំពោះរាល់ជីវិតទាំងអស់លើផែនដីយើងនេះ ។ ក្រោយពីយល់នូវអំពើរបស់ខ្លួនហើយ បុរសនោះក៏ទម្លាក់ពូថៅរបស់ខ្លួនចុះ ហើយបានចូលបួសជាសង្ឃវិញ ។ រឿងនេះ បានរំលឹកដល់យើងគ្រប់ៗគ្នាថា ការកាប់រំលំដើមឈើ មិនគ្រាន់តែបំផ្លាញដើមឈើប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំផ្លាញនូវទីជម្រកម្រឹគម្រឹគា បក្សាបក្សី សត្វល្អិត និងរុក្ខជាតិដែលរស់នៅក្នុង និងជុំវិញដើមឈើទាំងឡាយនោះទៀតផង ។ សមដូចក្នុងគាថាមួយក្នុង ជាតក ដែលបានលើកអំពីទំនាក់ទំនងរវាងខ្លា និងព្រៃឈើ យ៉ាងដូច្នេះថា :

*" ម្នាលខ្លាទាំងឡាយអើយ ! ចូរអ្នកវិលត្រឡប់ទៅកាន់ព្រៃរបស់អ្នកវិញទៅ ។*
*ហើយចូរអ្នកកុំធ្វើឱ្យព្រៃនោះ ក្លាយទៅជាវាលល្ហល្ហេវដូច្នោះ ព្រោះថា*
*បើគ្មានអ្នកទេ ព្រៃឈើមុខតែនឹងត្រូវគេកាប់រំលំឱ្យរាបជាមិនខាន ។*
*បើគ្មានព្រៃឈើ អ្នកមុខតែគ្មានទីជម្រកជារៀងរហូតទៅ " ។*

នៅក្នុងទស្សវត្សឆ្នាំ ១៩៩០ នេះ ប្រទេសកម្ពុជាកំពុងតែប្រឈមមុខ ចំពោះអត្រាដ៏ខ្ពស់បំផុតមួយនៃការបាត់បង់ព្រៃឈើ នៅលើពិភពលោកយើងនេះ ។ វិសាលភាពព្រៃឈើ ដែលត្រូវគេប៉ាន់ស្មានថាមានចំនួនប្រមាណ ៧៣ ភាគរយ ក្នុងឆ្នាំ ១៩៧០ នោះ ឥឡូវនេះត្រូវគេជឿថា នៅសល់ប្រមាណមិនដល់ ៤០ ភាគរយផង ហើយសព្វថ្ងៃនេះទៀត ក៏កំពុងធ្លាក់ដាក្បាលចុះ ដោយការទទួលរងការបំផ្លិចបំផ្លាញ ក្នុងល្បឿនមួយយ៉ាងលឿនរហ័ស ។ ផលវិបាកមួយ នៅក្នុងចំណោមផលវិបាកជាច្រើន នៃការបាត់បង់នូវព្រៃឈើនេះ គឺការកើនឡើងនៃការបាត់បង់ទីជម្រកធម្មជាតិ សម្រាប់សត្វព្រៃគ្រប់ប្រភេទ ។ ជាឧទាហរណ៍ ការកាប់ឈើក្នុងទ្រង់ទ្រាយដ៏ធំមួយនៅស្រុកស្នួល ខេត្តក្រចេះ បានធ្វើឱ្យសត្វព្រៃជាច្រើនភ័យស្លន់ស្លោ ស្ទុះស្វែងរកទី



www.elibraryofcambodia.org

ជម្រកថ្មីនៅក្នុងតំបន់ព្រៃ ដែលនៅសេសសល់ក្នុងខេត្តមណ្ឌលគិរីវិញ ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏តំបន់ទាំងនោះ កំពុងតែក្លាយទៅជាតំបន់មួយ ដែលលំបាកនឹងស្វះស្វែងរកឱ្យឃើញសត្វព្រៃ ហើយបរិមាណនៃសត្វព្រៃទាំងនេះ កំពុងតែថយចំនួនចុះទៅៗ យ៉ាងឆាប់រហ័សដែរ នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងបច្ចុប្បន្ននេះ ។

## សំណួរពិភាក្សា

១. *ចូររក និងពិភាក្សាជាមួយប្រជាពលរដ្ឋ នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ដែលនៅចងចាំបានថា មានសត្វអ្វីខ្លះ ដែលធ្លាប់បានរស់នៅក្នុងព្រៃ តាំងពីពេលមុនមក ។ នៅក្នុងចំណោមសត្វទាំងនេះ តើមានសត្វអ្វីខ្លះ ដែលបានបាត់បង់ទៅ និងសត្វណាខ្លះដែលនៅសេសសល់ ? ចូរពិភាក្សារកហេតុផល ចំពោះការបាត់បង់ពូជសត្វអស់ទាំងនោះ ។*

២. *ចូរពិភាក្សារកវិធី ដែលសត្វព្រៃអាចមានជីវិតរស់នៅ និងរីកចំរើននៅក្នុងតំបន់ របស់ព្រះតេជព្រះគុណ-លោកអ្នក ។*



www.elibraryofcambodia.org

៦៣. សត្វព្រៃ និងព្រៃព្រឹក្សា



www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន ៦ ខ**

# ករុណាធម៌របស់ព្រះពុទ្ធចំពោះសត្វ

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បានលើកដំកើងឱ្យមានសេចក្តីអាណិតអាសូរ ចំពោះសត្វមានជីវិតទាំងអស់ ។ សិក្ខាបទទី១ គឺការមិនសម្លាប់សត្វ ជាមូលដ្ឋានដ៏សំខាន់មួយ ស្តីពីករុណាមេត្តាធម៌ ដែលជាកម្លាំងដ៏សំខាន់មួយ នៃលទ្ធិព្រះពុទ្ធសាសនា ។ សិក្ខាបទនេះ គាំទ្រឱ្យដល់គំនិតនៃការថែរក្សាការពារសត្វទាំងឡាយ ។ ឥរិយាបថសុភាពរាបសារ និងអហឹង្សា ចំពោះសត្វទាំងអស់ ទោះតូចឬធំក្តី វាជាប្រភពនៃកុសលធម៌មួយ ដែលតម្រូវឱ្យមនុស្សលោក ធ្វើការកែលំអកុសលកម្មរបស់ខ្លួននៅក្នុងសំសារវដ្ត ។ ដូចនៅបណ្តាប្រទេសកាន់ព្រះពុទ្ធសាសនាជាច្រើនដែរ វត្តនៅប្រទេសកម្ពុជា តែងតែចិញ្ចឹមសត្វបំបរបង់ទាំងឡាយ មានដូចជាឆ្កែ និងឆ្មាជាដើម ហើយវត្ត បានត្រូវគេទទួលស្គាល់ថា ជាបដិសរណដ្ឋាន ឬជាទីជម្រករបស់សត្វព្រៃ ឬជាមន្ទិរពេទ្យរបស់សត្វទាំងឡាយ ដែលរងរបួសផងដែរ ។ មានម្តងនោះ នៅពេលដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ កំពុងយាងបិណ្ឌបាត នៅក្នុងទីក្រុង **សាវត្ថី** ព្រះអង្គបានទតឃើញកុមារាមួយក្រុម កំពុងឆាឆៅជន្លួជន្លេញពស់វែកមួយក្បាល ។ នៅពេលដែលព្រះអង្គបានចោទសួរថា ហេតុអ្វីបានជាអ្នកទាំងអស់គ្នាឆាឆៅ រុកគួនពស់វែកបែបនេះ ។ ពួកគេបានក្រាបទូលព្រះអង្គវិញថា ព្រោះតែពស់វែកជាសត្វអសិរពិស ហើយតែងតែចឹកពួកគេ ។ នៅពេលនោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានសំដែងធម៌ទូន្មានប្រៀនប្រដៅយ៉ាងដូច្នេះថា :

> *"សព្វសត្វទាំងអស់ ដែលបានកើតឡើងហើយ ជានិច្ចកាលរមែងតែងតែត្រូវការនូវសេចក្តីសុខ និងអំពើល្អជាពិតប្រាកដ បុគ្គលទាំងឡាយណា ដែលស្វះស្វែងរកសេចក្តីសុខ ដោយការបៀតបៀនបុគ្គលដទៃ ដោយអំណាចឥទ្ធិពលរបស់ខ្លួន បុគ្គលទាំងឡាយនោះ លះបង់លោកនេះទៅនឹងមិនសម្រេចបាននូវសេចក្តីសុខពិតប្រាកដឡើយ ។ សព្វសត្វទាំងអស់ ដែលបានកើតឡើងហើយ រមែងតែប្រាថ្នាចង់បានសេចក្តីសុខ បុគ្គលទាំងឡាយណា ដែលស្វែងរកសេចក្តីសុខ ដោយប្រាសចាកការបៀតបៀនបុគ្គលទាំងឡាយដទៃ តាមអំណាចឥទ្ធិពលរបស់ខ្លួន បុគ្គលទាំងនោះ លះបង់លោកនេះហើយ នឹងបានសម្រេចនូវសេចក្តីសុខពិតប្រាកដ"* ។ (**គម្ពីរធម្មបទ-សុខវគ្គ**)



www.elibraryofcambodia.org

ជាទិច្ចកាល សត្វទាំងឡាយត្រូវគេធ្វើទុក្ខបុកម្នេញ យ៉ាងឃោរឃៅព្រៃផ្សៃ សំរាប់គោលបំណង របស់មនុស្ស តាំងពីបុរាណកាលមកម្ល៉េះ ។ ក្បាច់ចម្លាក់នៅប្រាសាទបាយ័ន នៅក្នុងជុំប្រាសាទអង្គរ បាន បង្ហាញឱ្យឃើញពីមនុស្សចូលចិត្តកីឡាប្រជល់មាន់ ។ នាបច្ចុប្បន្ននេះ សណ្ឋាគារ និងភោជនីយដ្ឋាន ប្រជាប្រិយមួយចំនួនមានដាក់តាំងបង្ហាញសត្វព្រៃ ដោយចងច្រវ៉ាក់ ឬដាក់ក្នុងទ្រុង នៅតាមច្រកទ្វារចូល របស់ខ្លួន ដើម្បីបង្ហាញពីសញ្ញានៃជោគវាសនាល្អ ឬឋានៈល្អប្រពៃ ។ ការប្រព្រឹត្តចំពោះសត្វបែបនេះ វាជា អំពើមួយឃោរឃៅព្រៃផ្សៃ និងមិនចាំបាច់ផង ។

## សំណួរពិភាក្សា

*១. ចូរពិភាក្សាពិនិត្យលើរបៀប ដែលសត្វទាំងឡាយត្រូវគេធ្វើបាប នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ។*

*២. ចូរពិភាក្សា រកវិធី ដែលព្រះតេជព្រះគុណ-លោកអ្នក អាចជួយប្រជាពលរដ្ឋ នៅក្នុងសហគមន៍ ឱ្យបង្កើតនូវកិរិយាបថ ប្រកបដោយករុណាធម៌ និងភាពទទួលខុសត្រូវចំពោះសត្វទាំងឡាយ ។*



www.elibraryofcambodia.org

៦២. ករុណាធម៌របស់ព្រះពុទ្ធចំពោះសត្វ



www.elibraryofcambodia.org

www.elibraryofcambodia.org

មេរៀន ៦ គ

# ដំរីក្នុងព្រះពុទ្ធសាសនា

ដំរីមានតួនាទីមួយយ៉ាងសំខាន់នៅអំឡុងកាលនៃរាគជីវិតរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។ នៅក្នុងលទ្ធិព្រះពុទ្ធសាសនា ដំរីជានិមិត្តរូបនៃភាពស្អិតស្អេរ រឹងប៉ឹង និងអត់ធ្មត់ ។ នៅប្រទេសកម្ពុជា ជញ្ជាំងព្រះវិហារតែងតែរំលេចរចនាដោយរូបភាពដំរី ដែលកំពុងបំរើព្រះពុទ្ធជាម្ចាស់ ។ ជាពិសេស ដំរីសមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះពុទ្ធសាសនា និងរាជពិធីខ្មែរ ម្ល៉ោះហើយទើបដំរីក្លាយជានិមិត្តរូបនៃការបង្រួបបង្រួមមួយដ៏សំខាន់នៅក្នុងវប្បធម៌ខ្មែរ ។ ព្រះពោធិសត្វ បានយាងចូលទៅកាន់ព្រះគភ៌ព្រះមាតារបស់ព្រះអង្គ គឺព្រះនាង **សិរីមហាមាយា** ស្ថិតក្នុងរូបរាងជាដំរីស ។ រឿងរ៉ាវរបស់ដំរីដ៏ល្បីល្បាញមួយផ្សេងទៀតដកស្រង់ចេញពី **មិជក** មានជាប់ទាក់ទិននឹង **ទេវទត្ត** ជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ដែលបានធ្វើការព្យាយាមជាច្រើនលើក ដើម្បីកំចាត់ព្រះអង្គឱ្យវិនាស ។ **ទេវទត្ត** បានញុះញង់ទាក់រុកព្រះបាទ **អជាតសត្រូវ** ឱ្យបញ្ជូនដំរីដ៏កាចសាហាវមួយឈ្មោះ **នាឡាគិរី** ទៅកាន់ទីកន្លែង ដែលព្រះសម្មាសម្ពុទ្ធជាអម្ចាស់ត្រូវយាងឆ្លងកាត់ ដើម្បីឱ្យដេញព្រេចព្រះអង្គ និងជ្រំជាន់ឈ្លីព្រះអង្គឱ្យខ្ទេច ។ ផ្ទុយទៅវិញ ពេលឃើញព្រះពុទ្ធជាម្ចាស់ ដំរីបែរជាស្លូតសុភាពរាបសារ ហើយលុតជង្គង់ថ្វាយបង្គំព្រះអង្គ បបោសធូលីចេញពីចីពររបស់ព្រះអង្គទៅវិញ ។ ព្រះពុទ្ធបរមគ្រូទ្រង់បានអរគុណ **ទេវទត្ត** ដែលបានបញ្ជូនដំរីមកថ្វាយបង្គំព្រះអង្គ ។

នាបច្ចុប្បន្ននេះ ដំរីត្រូវបានគេគាំទ្រចូលចិត្តផងដែរ ពីពុទ្ធមាមកជនទាំងឡាយ ដោយសារដំរីមានការឈ្លាសវៃ មាំមួន និងអត់ធ្មត់ ព្រមទាំងដោយសារសេវាកម្មរបស់វា នៅក្នុងវិស័យកសិកម្ម និងការដឹកជញ្ជូន ។ ទោះជាយ៉ាងណាក៏ដោយ ចំនួនដំរីនៅប្រទេសកម្ពុជាសព្វថ្ងៃនេះ កំពុងថយចុះយ៉ាងគំហុក ព្រោះតែខ្វះទីជម្រកធម្មជាតិ និងដោយសារការបរបាញ់ដោយលួចលាក់ ។ នៅប្រទេសមួយចំនួន គេបានលើកតម្កើងការថែរក្សាការពារសត្វខ្លះ មានដូចជាសត្វខ្លាឃ្មុំធំម៉្យាងនៅប្រទេសចិនជាដើម ។ នៅប្រទេសកម្ពុជា ដំរីអាចក្លាយទៅជានិមិត្តរូបដ៏សមស្របមួយ ដើម្បីជំរុញការការពារសត្វព្រៃ ។



www.elibraryofcambodia.org

## សំណួរពិភាក្សា

១. ចូរពិភាក្សារកមូលហេតុ ដែលដីបានក្លាយជាទៅជាសត្វដ៏សំខាន់បំផុតមួយ នៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ហើយចូរពិភាក្សាពីគុណសម្បត្តិរបស់ដីនេះ ។

២. ចូរពិភាក្សាអំពីគ្រោះថ្នាក់នានា ដែលបណ្តាលឱ្យចំនួនសត្វដីកំពុងប្រឈមមុខ នឹងការបាត់បង់ក្នុងពេលនេះ និងពិភាក្សារកវិធានការ ដើម្បីការពារដី កុំឱ្យបាត់បង់បរិមាណតទៅទៀត ។



www.elibraryofcambodia.org



៦៣. ជីវិតក្នុងព្រះពុទ្ធសាសនា

www.elibraryofcambodia.org

www.elibraryofcambodia.org

មេរៀន
៦ ឃ

# ព្រានប្រមាញ់ និង សត្វដំរី

នៅក្នុងទីក្រុង ពារាណសី នៃប្រទេសឥណ្ឌា មានអ្នកបរបាញ់ដំរីមួយរូប ប្រកបរបរចិញ្ចឹមជីវិតដោយការសម្លាប់ដំរីយកភ្លុក ក្រចក ពោះវៀន និងសាច់របស់វា សំរាប់លក់ដូរ ។ នៅក្នុងព្រៃខ្លះមានដំរីរាប់ពាន់ក្បាលរស់នៅ ។ មានថ្ងៃមួយ នៅពេលដែលដំរីទាំងនោះ ចេញទៅកាន់ព្រៃ ពួកវាបានប្រទះឃើញព្រះបច្ចេកពុទ្ធជាច្រើនអង្គ ។ ចាប់តាំងពីថ្ងៃនោះមក ហ្វូងដំរីទាំងនោះតែងតែវន្ទាគោរព ចំពោះព្រះបច្ចេកពុទ្ធទាំងនោះជានិច្ច មុនពេលបន្តដំណើរតាមផ្លូវរបស់ខ្លួនទៅមុខទៀត ។ មានពេលមួយនោះ អ្នកបរបាញ់ម្នាក់បានឃើញហ្វូងដំរីទាំងនេះហើយ ក៏គិតថា ប្រសិនបើអញមានស្បង់ចីពរពណ៌លឿងដែរ អញមុខតែអាចប្រើកលល្បិចបញ្ឆោតដំរីទាំងនេះ ហើយសម្លាប់ពួកវាបានជាមិនខាន ។ គិតដូច្នោះហើយ គាត់ក៏បានលួចយកស្បង់ចីពរមកគ្រង រួចហើយគាត់អង្គុយចុះ ដោយទាញស្បង់ចីពរមកគ្របបាំងធ្នូ ស្នា និងព្រួញរបស់គាត់ ។ ជារៀងរាល់ថ្ងៃ ដំរីទាំងនេះតែងតែបានវន្ទាគោរពអ្នកបរបាញ់ដំរីនោះជានិច្ច ទើបបន្តដំណើររបស់ខ្លួនទៅមុខទៀតដូចទម្លាប់ ។ ជារៀងរាល់ពេល អ្នកបរបាញ់ដំរីនោះតែងតែពន្លាក់ដំរី ដែលនៅចុងក្រោយគេបង្អស់រួចមកក៏បានសម្លាប់ដំរីនោះទៅ ។ ក្រោយពីបានយកភ្លុក និងផ្នែកដ៏មានតម្លៃផ្សេងៗទៀតរួចរាល់ហើយ នាយប្រមាញ់ដំរីនោះ ក៏បានកប់លាក់តួខ្លួនដំរីនោះទៅក្នុងដី ។ ពេលក្រោយៗមកទៀត ព្រះពោធិសត្វមួយនៃយើង បានយោនយកកំណើតជាសត្វដំរី ហើយក្រោយមកក៏បានក្លាយទៅជាអ្នកដឹកនាំហ្វូងដំរីដដែលនេះ ។ ព្រះពោធិសត្វ បានចាប់ផ្តើមកត់សំគាល់ឃើញថា ហ្វូងដំរីនេះកាន់តែថយចំនួនតិចទៅៗ ។ ដូច្នោះហើយ នាសម័យថ្ងៃមួយ ព្រះពោធិសត្វបានសម្រេចចិត្តថា នឹងដើរខាងក្រោយហ្វូងដំរីនេះម្តង ។ ដូចពេលមុនៗដូច្នោះដែរ អ្នកបរបាញ់ដំរីនោះបានលោតចេញមក ហើយបាញ់ព្រួញតម្រង់ទៅរកដំរីខាងក្រោយបង្អស់នោះទៅ ប៉ុន្តែដំរីព្រះពោធិសត្វបានឈានថយក្រោយវិញ ដើម្បីគេចឱ្យផុតពីផ្លែព្រួញនោះ ។ ថ្លែងទៅកាន់អ្នកបរបាញ់នោះ ព្រះពោធិសត្វបានពោលដូច្នេះថា :

*"អ្នកបានស្លៀកពាក់ស្បង់ចីពរ ដែលបានក្លាយទៅជាអ្នកបួសចាកតណ្ហា*
*ប៉ុន្តែពុំមែនក្លាយទៅដូចជាអ្នកដូច្នោះទេ ។ ក្នុងការធ្វើនូវអំពើមួយ*
*យ៉ាងដូច្នេះ សឱ្យឃើញថា អ្នកបានប្រព្រឹត្តអំពើបាបមួយដ៏ធ្ងន់ធ្ងរ"* ។



www.elibraryofcambodia.org

រឿងនេះ បង្ហាញឱ្យឃើញច្បាស់ពីបញ្ហានៃភាពក្លែងបន្លំ ។ មួយភាគធំ នៃការបរបាញ់សត្វព្រៃនៅប្រទេសកម្ពុជាសព្វថ្ងៃនេះ ត្រូវគេធ្វើឡើងដោយខុសច្បាប់ ទៅលើពូជសត្វដ៏កម្រ ដែលកំពុងត្រូវគេនាំចេញទៅលក់ កាត់តាមព្រំដែនឆ្ពោះទៅកាន់ប្រទេសថៃ ចិន និងវៀតណាម ដើម្បីប្រាក់កាសតែប៉ុណ្ណោះ ។ ពាណិជ្ជកម្មសត្វព្រៃ ព្រមទាំងអនុផលនៃសត្វព្រៃផងនោះ កំពុងក្លាយទៅជាការបៀតបៀនយាយីដ៏សំខាន់មួយ ចំពោះពូជសត្វជាច្រើន រួមមានដូចជា ខ្លាឃ្មុំ ខ្លាដំបង ខ្លាឃ្មុំស និងសត្វត្រកួត អន្សង ជាដើម ។ បរិមាណសត្វទាំងនេះ កំពុងថយចុះយ៉ាងលឿនរហ័ស ដោយសារលទ្ធផលនៃការរុករាន ដេញចាប់ និងការបរបាញ់ដោយលួចលាក់ ហើយនិងតាមការធ្វើឱ្យខូចខាតទីជម្រកធម្មជាតិ ដែលបង្កឡើងដោយការកាប់ព្រៃឈើដ៏មានទំហំធំហួសហេតុពេក ។

## សំណួរពិភាក្សា

*១. តើមានសត្វព្រៃអ្វីខ្លះ ដែលត្រូវគេសម្លាប់ ដើម្បីលុយកាក់ នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ? ប្រសិនបើព្រះតេជព្រះគុណ-លោកអ្នក មិនច្បាស់ព្រាកដ សូមនិមន្ត អញ្ជើញទៅទស្សនានៅតាមទីផ្សារក្នុងមូលដ្ឋាន ទោះមុខតែនឹងឃើញថា ពូជសត្វណាខ្លះ ដែលគេកំពុងតាំងលក់ដូរ ?*

*២. តើគេលក់សត្វព្រៃដើម្បីអ្វីខ្លះ ? (ឧទាហរណ៍ ដើម្បីយកស្បែក ធ្វើថ្នាំ សម្រាប់នាំចេញ ។ល។)*

*៣. ចូរពិភាក្សារកវិធីនានា ដែលសហគមន៍វត្តរបស់ព្រះតេជព្រះគុណ-លោកអ្នក អាចផ្សព្វផ្សាយដំណឹងដល់ប្រជាពលរដ្ឋ អំពីផលវិបាកទាំងឡាយនៃការជួញដូរសត្វព្រៃ នៅប្រទេសកម្ពុជា និងគ្រោះថ្នាក់ដែលបណ្តាលឱ្យខូចដល់បរិស្ថានទាំងមូល ។*



www.elibraryofcambodia.org



៦៥. ព្រានប្រមាញ់ និងសត្វដំរី

www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន ៦១**

# រឿង សុវណ្ណសាម

មានរឿងមួយ ដែលដកស្រង់ចេញពី **ជាតក** បានដំណាលថា មានកុមារមួយរូបឈ្មោះ **សុវណ្ណសាម** រស់នៅក្នុងព្រៃភ្នំ ។ កុមាររូបនេះ បានបូជាជីវិតរបស់ខ្លួន ដើម្បីបំរើមាតាបិតា ដែលពិការភ្នែកទាំងពីររបស់ខ្លួន ឈ្មោះ **ទុកូលបណ្ឌិត** និង **បារិកា** ។ ជារៀងរាល់ថ្ងៃ **សុវណ្ណសាមកុមារ** តែងតែដងទឹក និងរកម្ហូបអាហារនៅក្នុងព្រៃ មកជូនមាតាបិតារបស់ខ្លួនជានិច្ច ។ កុមារនេះ បានធំដឹងក្ដីហើយក៏បានទៅជាទីស្រឡាញ់រាប់អានពីសត្វក្ដាន់ទាំងឡាយ ដែលរស់នៅក្នុងព្រៃ ។ សម័យថ្ងៃមួយ ស្ដេច **កបិលិយក្ខ** បានយាងទៅបរបាញ់សត្វ ជាចៃដន្យ ទ្រង់បានបាញ់ត្រូវ **សុវណ្ណសាមកុមារ** ដែលឈរនៅក្បែរសត្វក្ដាន់ បណ្ដាលឱ្យមានគ្រោះថ្នាក់ដល់ជីវិត ។ **សុវណ្ណសាមកុមារ** ដែលហៀបជិតស្លាប់នោះចង់ដឹងខ្លាំងណាស់ ហើយសួរស្ដេចថា : ហេតុអ្វីបានជាព្រះអង្គសម្លាប់ទូលព្រះបង្គំ ? ស្ដេចនោះមានព្រះរាជឱង្ការកុហកតបវិញថា : ដោយសារកុមារឯងនេះ ជាក្មេងមានកំហុស មកបង្អើលសត្វក្ដាន់ដែលយើងបំរុងនឹងបាញ់ ។ **សុវណ្ណសាមកុមារ** បានទូលស្ដេចនោះវិញថា តាំងពីកុមារភាពមកម្ល៉េះ សូម្បីតែសត្វព្រៃកាចសាហាវជាងគេបំផុត ក៏មិនបានផ្អើលភ័យខ្លាចដោយសាររូបខ្ញុំឡើយ ហើយថាខ្ញុំមកកាន់ព្រៃនេះជារៀងរាល់ថ្ងៃមិនដែលលស់ ដើម្បីរកចំណីនិងទឹកនៅក្នុងព្រៃនេះ ។ ស្ដេចនោះ ក្រោយពីទ្រង់បានសណ្ដាប់រឿងរ៉ាវរបស់កុមារនេះហើយ ក៏ទ្រង់សារភាពថា ព្រះអង្គជាអ្នកខុសនៅក្នុងរឿងនេះហើយ ព្រះអង្គបានអំពាវនាវរកទេព្ដាឱ្យជួយ ។ ទេព្ដាក៏បានក្រាបទូលដល់ស្ដេចយក្ខនោះវិញថា ព្រះអង្គគួរតែយកព្រះទ័យទុកដាក់ចិញ្ចឹមបីបាច់ថែរក្សាមាតាបិតាពិការភ្នែករបស់ **សុវណ្ណសាមកុមារ** នេះជាជំនួសវិញ ។ នៅទីបញ្ចប់ ទេព្ដាក៏ប្រោសឱ្យ **សុវណ្ណសាមកុមារ** មានជីវិតរស់ដូចដើមឡើងវិញ ។

ពីដើមមក ទីជម្រកសត្វព្រៃនៅប្រទេសកម្ពុជា ពុំដែលបានទទួលរងការរំខានយាយី ពីសំណាក់សកម្មភាពរបស់មនុស្សឡើយ ។ មនុស្សសម័យនោះមានជីវភាពរស់នៅយ៉ាងសាមញ្ញ ហើយបានរំលោភឬរុករានទន្ទ្រានយ៉ាងតិចតួចបំផុត ទៅលើព្រំដែនដែនសីមារបស់សត្វព្រៃ ។ ប៉ុន្ដែសព្វថ្ងៃនេះ ការគាបសង្កត់ចេះតែកើនឡើងៗ គម្រាមមកលើទីជម្រកសត្វព្រៃទាំងនេះ ដោយការកាប់រំលំព្រៃឈើ និងការបរបាញ់សត្វដោយខុសច្បាប់ ព្រមទាំងការកាប់ឆ្ការព្រៃយកដីសម្រាប់គំរោងអភិវឌ្ឍន៍សេដ្ឋកិច្ច មានដូចជាកសិកម្មទ្រង់ទ្រាយធំ និងការបង្កើតអាងស្ដុកទឹកធំៗ សម្រាប់ទាញយកថាមពលវារីអគ្គិសនីជាដើម ។



www.elibraryofcambodia.org

## សំណួរពិភាក្សា

១. ចូរពិភាក្សាពីពិធីនានា ដែលសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក កំពុងរំលោភទន្ទ្រានទៅលើទីជម្រករបស់សត្វព្រៃ ។

២. ចូរពិភាក្សាអំពីដំណោះស្រាយ ដែលអាចរក្សាការពារទីជម្រករបស់សត្វព្រៃ ពីការរំលោភទន្ទ្រានរបស់មនុស្ស ។

៣. តើសហគមន៍អាចជួយ ដើម្បីថែរក្សាការពារទីជម្រករបស់សត្វព្រៃ នៅតាមសហគមន៍ ក្នុងមូលដ្ឋាន ដូចម្ដេចខ្លះ ?



www.elibraryofcambodia.org



៦១. រឿងសុវណ្ណសាម

www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន**
**៦ ច**

# បុរសបរិភោគសុីតសត្វ

ក្នុងកាលដែលកន្លងយូរលង់ណាស់មកហើយ ព្រះអង្គម្ចាស់ **វេពាធិ** នៅពេលចាប់កំណើតជាមនុស្សនាជាតិមុន បានសោយសុីតសត្វមួយចំនួន ហើយក៏បានក្លាយទៅជាអ្នកគ្មានបុត្រអស់មួយជីវិតព្រះអង្គ ។ រឿងនេះមានសេចក្ដីដំណាលថា : មានមនុស្សជាច្រើនរយនាក់ បានធ្វើដំណើរនៅក្នុងសំពៅមួយ ឆ្ពោះឆ្លងកាត់មហាសាគរ ។ លុះពេលដែលសំពៅនោះទៅដល់ពាក់កណ្ដាលមហាសាគរ ពួកគេបានទទួលរងទុក្ខ ដោយសារសំពៅធ្លាយ ហើយមនុស្សទាំងអស់ ដែលជិះនៅលើសំពៅនោះ បានបាត់បង់ជីវិតទាំងអស់គ្នា លើកលែងតែមនុស្សពីរនាក់ជាប្ដីប្រពន្ធតែប៉ុណ្ណោះ ។ ពួកគេទាំងពីរនាក់ប្ដីប្រពន្ធ ក៏បានប្រវេប្រវាតោងបានបន្ទះក្ដារមួយសន្លឹក ហើយបានហែលឆ្លងទៅរកកោះជិតខាងមួយ ។ នៅលើកោះនេះ មានហ្វូងបក្សាបក្សីជាច្រើនរស់នៅ ។ ប្ដី និងប្រពន្ធ ដែលពោរពេញទៅដោយការស្រេកឃ្លានផង និងដោយយល់ឃើញថា គ្មានអ្វីបរិភោគ ក៏បានស្មោរចំអិនសុីតសត្វទាំងនោះបរិភោគទៅ ។ លុះបរិភោគសុីតសត្វនោះអស់ ពីរនាក់ប្ដីប្រពន្ធបានចាប់យកកូនសត្វទាំងនោះបរិភោគជាបន្តទៀត ដើម្បីបំពេញសេចក្ដីស្រេកឃ្លានរបស់ខ្លួន ។ នៅក្នុងចំណោមពីរនាក់ប្ដីប្រពន្ធនោះ គ្មាននរណាម្នាក់យកចិត្តទុកដាក់ទៅនឹងអំពើរបស់គេទេ ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានព្រះពុទ្ធដីកា ដល់ព្រះរាជាអង្គនោះថា ប្រសិនបើព្រះអង្គយកចិត្តទុកដាក់ឱ្យបានខ្លាំងពីជាតិមុនរបស់ព្រះអង្គនោះព្រះអង្គមុខតែអាចទទួលបាននូវបុត្រា ឬបុត្រីមួយព្រះអង្គជាពុំខានឡើយ ។

តំបន់ *ដីសើម*[១៦] ដ៏ធំចេងនៅប្រទេសកម្ពុជា ជាតំបន់ដែលផ្ដល់ទីជម្រក និងបង្កើតកូនចៅដ៏ល្អឥតខ្ចោះមួយ សម្រាប់ពូជសត្វតំបន់ដីសើមជាច្រើនប្រភេទ ។ **វាលព្រែកតាល់** ជាតំបន់ព្រៃលិចទឹកមួយស្ថិតនៅតាមដងទន្លេសាប គឺជាតំបន់មួយនៅក្នុងចំណោមតំបន់ទាំងឡាយ ដែលមានពូជបក្សីទឹកធំៗជាច្រើនមានដូចជា កុកខ្ចូនស ត្រដក់ធំ ទុង និងបក្សាបក្សីដទៃទៀតជាច្រើនប្រភេទទៀតរស់នៅ ។ នៅឆ្នាំ ១៩៩៦ គេបានរាយការណ៍មកថា ចំនួនសត្វស្លាបទាំងឡាយបានធ្លាក់ចុះមកត្រឹម ១០ ភាគរយ នៃអត្រាសត្វស្លាបដែលមាននៅក្នុងទសវត្សរ៍នៃឆ្នាំ ១៩៧០ ដោយសារតែការប្រមូលយកសុីត និងចាប់កូនសត្វច្រើនសន្ធឹកសន្ធាប់ហួសប្រមាណ ។ ដោយគេចាត់ទុកជាអាហារដ៏ឆ្ងាញ់ពិសារ សុីតជាច្រើន ត្រូវគេនិយមបរិភោគនៅ

---

[១៦] *តំបន់ដីសើម : តំបន់ដែល [illegible]*

ពេលចូលឆ្នាំខ្មែរ ឬត្រូវគេយកទៅនៅប្រទេសជិតខាងដទៃទៀត ។ ពាណិជ្ជកម្មសត្វព្រៃជាអន្តរជាតិ ក៏ផ្តល់ជូននូវកំរៃច្រើនផងដែរ ចំពោះសត្វទឹកដែលកំពុងវិនាសពូជ អណ្តើក និងពស់ថ្លាន់ជាដើម ។

## សំណួរពិភាក្សា

១. តើមានសត្វស្លាបអ្វីខ្លះ រស់នៅក្នុងសហគមន៍ព្រះតេជព្រះគុណ-លោកអ្នក ? (ចូររកពត៌មានឱ្យបានច្រើន តាមលទ្ធភាពដែលអាចរកបានអំពីសត្វស្លាបនេះ ដូចជា វារស់នៅកន្លែងណា វាបង្កាត់ពូជនៅកន្លែងណា ? វាផ្លាស់ប្តូរកន្លែងទៅទីណា ?)

២. តើស៊ុតសត្វអ្វីខ្លះ ដែលសហគមន៍ព្រះតេជព្រះគុណ-លោកអ្នកចាត់ទុកជាអាហារដ៏ឆ្ងាញ់ពិសារ ?



www.elibraryofcambodia.org

## ៦៥. បុរសបរិភោគស៊ុតសត្វ



www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន**
**៦ ៩**

# នាគ

ក្រោយពេលព្រះសម្មាសម្ពុទ្ធ ទ្រង់បានសម្រេចសម្មាសម្ពោធិញ្ញាណបន្តិចមក ព្រះអង្គទ្រង់បានធ្វើសមាធិ នៅក្រោមម្លប់ឈើដ៏ធំមួយ នៅក្បែរស្រះឈ្មោះ **មុច្ចលិន្ទ** ។

ពួកមារបានបញ្ជូនព្យុះភ្លៀងដ៏កាចសាហាវមួយគម្រប់មករកព្រះពុទ្ធជាម្ចាស់ ក្នុងបំណងផ្ចាញ់កុំឱ្យធ្វើសមាធិបាន ។ ស្តេចនាគឈ្មោះ **មុច្ចលិន្ទ** បានចូលមកកាន់សំណាក់ព្រះពុទ្ធជាម្ចាស់ ហើយបានក្លាយរង្វេលខ្លួនទៅជាពែន សម្រាប់ថ្វាយព្រះពុទ្ធជាម្ចាស់គង់ពីលើ ហើយសិរសារបស់ស្តេចនាគនោះបើកពពារបានជាគម្របបាំងព្រះកេសា ដើម្បីការពារព្រះសម្មាសម្ពុទ្ធពីទឹកភ្លៀងដែលធ្លាក់ចុះយ៉ាងខ្លាំង ។

**នាគ** មានឋានៈពិសេសមួយនៅក្នុងព្រះពុទ្ធសាសនា និងត្រូវគេសំដែងឡើង ក្នុងទម្រង់ជាច្រើននៃសិល្បៈបែបព្រះពុទ្ធសាសនា ។ នាគត្រូវគេទទួលស្គាល់ថា ជាសត្វដែលគេគោរពបូជា និងជាអ្នកការពារព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ។ នៅប្រទេសកម្ពុជា នាគជារូបភាពរឿងព្រះពុទ្ធសាសនា ដ៏មានប្រជាប្រិយមួយដែលគេអាចមើលឃើញ ក្នុងការតុបតែងលំអបង្កាន់ដៃជណ្តើរ និងនៅជុំបូលវត្ត នៅទូទាំងប្រទេស ។

រូបព្រះពុទ្ធប្រក់នាគ ជាបដិមាមួយ ដែលគេប្រទះឃើញមានជាទូទៅនៅក្នុងសិល្បៈចម្លាក់របស់ខ្មែរ ។ នាគក៏បានលើកយកមកបង្ហាញផងដែរ នៅក្នុងប្រវត្តិរឿងព្រេងនិទានរបស់ប្រទេសកម្ពុជា ។ នាគទាំងនោះ រស់នៅក្នុងអាណាចក្រមួយនៅក្រោមដី ឬនៅក្នុងទឹក ប៉ុន្តែអាចឡើងមកកាន់ផ្ទៃខាងលើ ដើម្បីស្រូបយកខ្យល់អាកាស ហើយអាចប្រែខ្លួនទៅជាមនុស្សបានទៀតផង ។ **នាគ** ជានិមិត្តរូបនៃបរិស្ថានដ៏ល្អមួយ សម្រាប់បង្ហាញឱ្យឃើញ ពីលក្ខណៈពឹងផ្អែកគ្នានៃជីវិតនៅលើផែនដី ហើយនិងពិតម្រូវការក្នុងកិច្ចការពារធម្មជាតិមនុស្ស និងវប្បធម៌ផងដែរ ។

គោលការណ៍ស្តីពី **កម្ម** ( អំពើដែលឈរលើហេតុ និងផល នៅក្នុងព្រះពុទ្ធសាសនា ) និង **សំសារៈ** ( ដំណើរវិវត្តនៃការស្លាប់ និងការកើតឡើងវិញ) តែងតែត្រៀមរៀបចំពុទ្ធសាសនិកជនទាំងឡាយ ឱ្យជ្រើសយកឥរិយាបថ ប្រកបដោយសមានចិត្ត ចំពោះសត្វទាំងឡាយ ។ យោងតាមជំនឿនេះ មនុស្សយើងស្លាប់ទៅអាចទៅកើតជាសត្វវិញក៏មាន ។ ហេតុដូច្នេះហើយ វាជារឿងមួយដ៏ត្រូវណាស់ ដែលយើងទាំងអស់គ្នាគប្បីថែរក្សាការពារសត្វទាំងឡាយ ប្រកបដោយការអាណិតអាសូរ និងសន្តោសប្រណីជានិច្ច ។



www.elibraryofcambodia.org

## សំណួរពិភាក្សា

១. តើមានសត្វ ទេវកថា  រូបប្រតិក, ដទៃណាផ្សេងទៀត  ដែលអាចយកមកប្រើ ទៅក្នុងសហគមន៍ របស់ព្រះតេជព្រះគុណ-លោកអ្នក ដើម្បីជានិមិត្តរូបនៃសមរម្យនៃបរិស្ថាន ?

២. ចូរពិភាក្សាពីភាពតំណាងនៃសត្វក្នុងរឿងទេវកថាទាំងនេះមានអ្វីខ្លះ និងវិធីដែលគេអាចយកមកប្រើ ដើម្បីបង្កើតឱ្យមានការយល់ដឹងអំពីបញ្ហាបរិស្ថាន ដែលមានកើតឡើង ។



www.elibraryofcambodia.org



២៨. នាគ

www.elibraryofcambodia.org

www.elibraryofcambodia.org

## សកម្មភាព

## ១. ការស្វែងយល់ពីសត្វព្រៃក្នុងសហគមន៍

**១.វត្ថុបំណង :** ដើម្បីពិតពិចារណាថា តើសកម្មភាពទាំងឡាយរបស់មនុស្ស កំពុងបំផ្លិចបំផ្លាញទីជម្រករបស់សត្វព្រៃ និងធ្វើឱ្យប្រភេទសត្វខ្លះកំពុងវិនាសផុតពូជយ៉ាងណា ។

**២.សកម្មភាព :** សកម្មភាពនេះ ទាក់ទងទៅនឹងការបង្កើតតារាងពេលវេលាដូចតទៅនេះ :

| អតីតកាល<br>១៩៦៩ | បច្ចុប្បន្នកាល<br>១៩៩៩ | អនាគតកាល<br>២០៣៩ |
|---|---|---|
| | | |

❶ ចូរចែកក្រុមធំជាបីក្រុមតូច១ ហើយត្រូវផ្តល់តារាងពេលវេលាខាងលើមួយ ឱ្យគ្រប់ក្រុម ។

❷ នៅក្នុងក្រុមរបស់ព្រះតេជព្រះគុណ-លោកអ្នក ចូរពិភាក្សាគ្នាថា តើមានសត្វព្រៃអ្វីខ្លះធ្លាប់មាន/កំពុងមាន/នឹងមាននាពេលអនាគត នៅក្នុង ឬជុំវិញសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ?

❸ អាចបង្ហាញគំនិតយោបល់របស់ព្រះតេជព្រះគុណ-លោកអ្នក ជាបញ្ជីពូជសត្វព្រៃក៏បាន ឬជារូបភាពសត្វព្រៃក៏បាន ។

❹ ចូរធ្វើការប្រជុំក្រុមធំឡើងវិញ ដើម្បីឱ្យក្រុមតូចនិមួយ១ លើកបង្ហាញពន្យល់ និងប្រៀបធៀបលទ្ធផលរបស់គេ ។

## ២. ការចាប់សត្វ ការបរបាញ់ ការនេសាទ

**១.វត្ថុបំណង :** ដើម្បីពិគ្រោះពិចារណាវិធី នៃការប្រមូលភោគផលសត្វព្រៃណាមួយ ដែលធានាបាននូវ



www.elibraryofcambodia.org

និរន្តរភាព និងដើម្បីប្រៀបធៀបវិធីទាំងនោះ ជាមួយនិងវិធី ដែលគេប្រើប្រាស់ជាទូទៅជាងគេ នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ។

**២.សកម្មភាព** : ខាងក្រោមនេះ ជាតារាងបញ្ជីនៃវិធិ ដែលគេប្រើសម្រាប់សម្លាប់សត្វព្រៃ ។

*( បើមានទៀត សូមមេត្តាបន្ថែមទៅក្នុងបញ្ជីខាងក្រោមនេះ នូវវិធីផ្សេងៗទៀត)*

- ❏ អង្គប់ /អន្ទាក់
- ❏ មង/សំណាញ់
- ❏ ថ្នាំពុល
- ❏ កាំភ្លើង
- ❏ ធ្នូ ស្នា និងព្រួញ
- ❏ ដុតព្រៃ
- ❏ គ្រឿងផ្ទុះ

❶ ចូរសរសេរតារាងបញ្ជី នៅលើក្ដារខៀន ឬនៅលើក្រដាសក៏បាន ។

❷ ចូរបែងចែកជា ២ ក្រុមតូចៗ ។

❸ ចូរឱ្យក្រុមណាមួយតម្រៀបវិធីខាងលើនេះ ទៅតាមលំដាប់ពីការបំផ្លិចបំផ្លាញច្រើនជាងគេបំផុត មកលំដាប់ ដែលបំផ្លិចបំផ្លាញតិចជាងគេបំផុត ។

❹ ចូរឱ្យក្រុមមួយទៀត តម្រៀបវិធីខាងលើនេះ ទៅតាមលំដាប់នៃការប្រើប្រាស់ ជាទូទៅជាងគេបង្អស់នៅក្នុងសហគមន៍ មកលំដាប់នៃការប្រើប្រាស់ជាទូទៅតិចជាងបង្អស់ ។

❺ ចូរឱ្យក្រុមនិមួយៗ ឡើងមកបង្ហាញនូវលទ្ធផលរបស់គេ និងពន្យល់ពីហេតុផល ។

❻ ចូរប្រៀបធៀបលទ្ធផលរបស់ក្រុមទាំង ២ ហើយមើលឱ្យឃើញថា តើមានការជាប់ទាក់ទងគ្នាដល់កំរិតណា ។

## ការអភិរក្សធម្មជាតិ គឺដើម្បីថែរក្សាគុណភាពជីវិតរបស់ប្រជាពលរដ្ឋ



www.elibraryofcambodia.org

# ជំពូកទី ៧

# ការចៀសវាង
# ការបំពុល និង សំណល់

មេរៀន ៧ក : ការបំពុលប្រភពទឹក

មេរៀន ៧ខ : ការថែរក្សាបរិស្ថានឱ្យបានស្អាតជានិច្ច

មេរៀន ៧គ : សារសំខាន់នៃអនាម័យ

មេរៀន ៧ឃ : ការបំពុលដោយសូរសំឡេង

មេរៀន ៧ង : កំណែច្នៃជាថ្មីឡើងវិញ

*សកម្មភាព : យើងចៀសវាងការបំពុលបរិស្ថាន*

www.elibraryofcambodia.org

www.elibraryofcambodia.org

មេរៀន
៧ ក

# ការបំពុលប្រភពទឹក

ជាច្រើនសតវត្ស មុនពេលទឹកនៅលើផែនដីក្លាយជាកខ្វក់ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បានដាក់បទបញ្ញត្តិហាមប្រាមអំពីការធ្វើឱ្យទឹក ឬប្រភពទឹកកខ្វក់ ឬពុល ។ ពុទ្ធបញ្ញត្តិជាច្រើន ដែលមាននៅក្នុង **វិន័យបិដក** បានហាមប្រាមដល់ភិក្ខុសង្ឃទាំងឡាយ មិនឱ្យបំពុលដី និងទឹក ដោយការស្តោះទឹកមាត់ បន្ទោបង់លាមក និងទឹកមូត្រឡើយ ។ សំណល់របស់មនុស្សជាភ្នាក់ងារទូទៅមួយនៃការបំពុល នៅក្នុងសម័យពុទ្ធកាល ។ ការធ្វើឱ្យទឹកកខ្វក់ ឬបំពុល គឺមានន័យដូចគ្នានឹងការប្រព្រឹត្តនូវបាបកម្មមួយដែរ ព្រោះថាភាវៈមានជីវិតទាំងអស់ពឹងផ្អែកលើទឹក ។ ជានិច្ចកាល តម្រងទឹកជាបរិក្ខារប្រើប្រាស់មួយ នៅក្នុងចំណោមបរិក្ខារប្រើប្រាស់ជាមូលដ្ឋានរបស់ភិក្ខុសង្ឃទាំងប្រាំបីប្រការ ដែលត្រូវគេផ្តល់ជូនឱ្យ នៅពេលសាងព្រះផ្នួសម្តងៗ ។ សព្វថ្ងៃនេះ ភិក្ខុទាំងឡាយនៅតែទទួលយកប្រដាប់ច្រោះទឹកមកប្រើ ទុកជាគ្រឿងក្រេនរំលឹក ដើម្បីឱ្យឆាន់តែទឹកស្អាត និងការពារកុំឱ្យមានគ្រោះថ្នាក់ដល់សត្វល្អិត និងសត្វមានជីវិតផ្សេងៗទៀត ដែលរស់នៅក្នុងទឹក ។

នៅទន្ទឹមពេលដែលប្រជាពលរដ្ឋនៅក្នុងទីក្រុង និងទីប្រជុំជនតូចធំក្នុងប្រទេសកម្ពុជា ចេះតែកើនចំនួនច្រើនឡើងៗនោះ បញ្ហាអនាម័យក៏កាន់តែមានចោទជាបញ្ហាឡើងយ៉ាងខ្លាំងដែរ ។ ទឹកក៏ក្លាយទៅជាកខ្វក់ ឬពុល ដោយសារតែការបង្ហូរចេញទឹកស្អុយ សំណល់គីមីផ្សេងៗ ចូលទៅក្នុងទន្លេ ស្ទឹង ។ បញ្ហាមួយទៀតគឺថា ប្រជាពលរដ្ឋមានទម្លាប់បោះចោលសំរាម ឬចាក់សំណល់មានជាតិពុល (ជាតិគីមី ប្រេងរំអិល ថ្នាំសម្លាប់សត្វចង្រៃជាដើម) ចូលទៅក្នុងស្រះ ត្រពាំង អូរ និងព្រែកជីកទាំងឡាយ ។ ទឹកកខ្វក់ ឬពុល បង្កឱ្យមានជាគ្រោះថ្នាក់មួយដល់សុខភាពរបស់យើង ។ មានជំងឺជាច្រើនអាចឆ្លងរាលដាលដល់មនុស្ស តាមរយៈការផឹក ឬងូតទឹកដែលមិនស្អាតនោះ ។



www.elibraryofcambodia.org

## សំណួរពិភាក្សា

១. តើមានមូលហេតុអ្វីខ្លះ ដែលធ្វើឱ្យប្រភពទឹកក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក កខ្វក់ ឬពុល ?

២. ចូរពិភាក្សាពីវិធីអនុវត្តជាក់ស្តែង ដែលអាចថែរក្សាការពារប្រភពទឹកក្នុងសហគមន៍ មិនឱ្យកខ្វក់ ឬពុលបាន ។ (ឧទាហរណ៍ : ធ្វើរបងព័ទ្ធជុំវិញអណ្តូងទឹក និងស្រះទឹក ថែរក្សាប្រភពទឹកស្អាតឱ្យនៅឆ្ងាយដាច់ពីបង្គន់ និងតំបន់ចំរាញ់សារធាតុគីមី ហើយនិងការផ្តល់កន្លែង សំរាប់ស្តុកសំណល់ទុកប្រកបដោយសុវត្ថិភាព ។



www.elibraryofcambodia.org

## ៧ក. ការចំពុលប្រភពទឹក



www.elibraryofcambodia.org

www.elibraryofcambodia.org

| | |
|---|---|
| មេរៀន<br>៧ ១ | **ការថែរក្សាបរិស្ថានឱ្យបានស្អាតជានិច្ច** |

ក្រោយពេលដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ចូលបរិនិព្វានទៅ មានព្រះមហាភិក្ខុមួយអង្គ ដែលនៅគង់ចាំព្រះវស្សានាវត្តក្បែស្ទឹងធំមួយ បានប្រឹងប្រែងបោសសំអាតវត្តនោះ ឱ្យបានល្អស្អាតជារៀងរាល់ថ្ងៃ ។ នាសម័យថ្ងៃមួយ ព្រះភិក្ខុអង្គនោះបានបោសប្រមូល និងគរសំរាមទុកមួយកន្លែង ដើម្បីឱ្យគេយកទៅបោះចោលនៅទីឆ្ងាយ ។ កាលនោះ មានសុនខមួយ បានមកបន្ទោបង់លាមកនៅលើគំនរសំរាមនោះ ។ ពេលនោះ ព្រះភិក្ខុដែលមានវស្សាចាស់ជាង បានស្នើសុំឱ្យព្រះភិក្ខុ ដែលមានវស្សាក្មេងមួយអង្គ ប្រមូលកើបសំរាម និងលាមកនោះយកទៅបោះចោល ។ ទោះបីជាព្រះភិក្ខុដែលមានព្រះវស្សាក្មេងជាងនោះ មិនសប្បាយចិត្តអំពីកិច្ចការនោះក៏ដោយ ក៏លោកបានធ្វើតាមសំណូមពរដែរ ។ ព្រះភិក្ខុទាំងពីរអង្គនេះ ក្រោយមកបានទៅកើតក្នុងស្ថានសួគ៌ ។ យោងតាម **ព្រះវិន័យបិដក** ភិក្ខុទាំងឡាយត្រូវថែរក្សាការពារបរិស្ថាន ដែលលោកគង់នៅ ឱ្យបានស្អាតបាតល្អជានិច្ច ទាំងនៅក្នុងកុដិ និងក្នុងទីធ្លាវត្តផងដែរ ។ តារាងកាលវិភាគ ឬប្រតិទិនកិច្ចវត្ត ដែលបានរៀបចំឡើងដោយព្រះមហាថេរមុនៗមក បានតម្រូវឱ្យភិក្ខុទាំងឡាយ សំអាតវត្តនៅពេលព្រឹកព្រលឹម និងពេលព្រលប់ ។ បើភិក្ខុអង្គណាមួយ មិនបំពេញកាតព្វកិច្ចទាំងឡាយនេះទេ ភិក្ខុអង្គនោះមានឈ្មោះថា មិនបានដើរតាមសិក្ខាបទរបស់ខ្លួនគឺ ***សីលៈ*** ឡើយ ។

នៅតាមទីក្រុង និងទីប្រជុំជនទាំងឡាយនៃប្រទេសកម្ពុជា គេតែងបោះសំរាមចោលតាមដងផ្លូវជាញឹកញាប់ ។ នេះមិនគ្រាន់តែធ្វើឱ្យបាត់បង់សោភណភាព និងធ្វើឱ្យស្ទះលូបង្ហូរទឹកស្អុយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ជាទីជម្រកឱ្យដល់មូស និងកណ្តុរបង្កើតកូនទៀតផង ។ សំរាមក៏បង្កើតឱ្យមានគ្រោះថ្នាក់ភ្លើងឆេះផ្ទះផងដែរ ។ បរិស្ថានប្រកបដោយសុខភាពល្អ និងរីករាយ គឺជាបរិស្ថានមួយ ដែលស្អាតប្រកបដោយអនាម័យ ។ ការបោសសំអាតកន្លែងកខ្វក់ គឺការជួយកែលំអ និងធ្វើឱ្យស្ងប់ខាងផ្លូវចិត្ត ។ ការកំចាត់សំរាមជាការជួយការពារផងដែរ កុំឱ្យសាយភាយជំងឺ និងភ្លើងឆេះផ្ទះបាន ។ ប្រជាពលរដ្ឋរស់នៅតំបន់ក្នុងទីក្រុងចាំបាច់ត្រូវតែទទួលខុសត្រូវ ឱ្យរឹតតែខ្លាំងឡើងៗថែមទៀត ចំពោះបរិស្ថានរបស់ខ្លួន និងចូលរួមរិភាគទានចំពោះការថែរក្សាបរិស្ថានឱ្យបានល្អស្អាត ។ សំណល់នៅតាមផ្ទះសំបែង គប្បីទុកដាក់ដោយប្រុងប្រយ័ត្ន ហើយហាមកុមារទាំងឡាយ ក៏ដូចកុលបុត្រកុលធីតារបស់ខ្លួនដែរ កុំឱ្យទៅលេងនៅលើកន្លែងចាក់ ឬគំនរសំរាម ដែលអាចនាំឱ្យកើតជំងឺឆ្លង និងជំងឺតម្កាត់ផ្សេងៗ ។



www.elibraryofcambodia.org

## សំណួរពិភាក្សា

១. តើវត្តរបស់ព្រះតេជព្រះគុណ-លោកអ្នកស្អាតឬទេ ? ប្រសិនបើស្អាតហើយ តើធ្វើតាមរបៀបយ៉ាងដូចម្តេចទើបស្អាត ? ។ ប្រសិនបើមិនស្អាត ហេតុអ្វីបានជាទុកឱ្យវត្តនៅតែកខ្វក់រហូតអញ្ចឹង ?

២. តើតំបន់ខាងក្រៅវត្ត របស់ព្រះតេជព្រះគុណ-លោកអ្នកស្អាត ឬកខ្វក់ ដូចគ្នានឹងតំបន់ខាងក្នុងវត្តដែរឬទេ ? តើព្រះតេជព្រះគុណ-លោកអ្នក អាចជួយថែទាំបរិស្ថាន ទាំងក្នុងនិងក្រៅវត្តឱ្យស្អាតបានស្មើគ្នាតាមវិធីណា ?

៣. តើព្រះតេជព្រះគុណ-លោកអ្នក មានវិធីជួយផ្សព្វផ្សាយដំណឹងចំពោះអ្នកដទៃ អំពីផលវិបាក និងគ្រោះថ្នាក់ទាំងឡាយ ដែលបណ្តាលឡើងដោយការទុកដាក់ ឬបោះចោលសំរាមប្រាសចាកការទទួលខុសត្រូវ យ៉ាងដូចម្តេចខ្លះ ?



www.elibraryofcambodia.org

៧១. ការថែរក្សាបរិស្ថានឱ្យមានស្អាតជានិច្ច



www.elibraryofcambodia.org

www.elibraryofcambodia.org

មេរៀន
៧ គ

# សារសំខាន់នៃអនាម័យ

នៅក្នុងសម័យពុទ្ធកាល បង្គន់ត្រូវតែកសាងពីឥដ្ឋ ឬឈើ និងមានដំបូល ព្រមទាំងជញ្ជាំងបិទបាំងទៀតផង ។ គេមានជីករណ្ដៅមួយ ទុកសម្រាប់ស្តុកទឹកសំណល់មិនស្អាត និងមានកន្លែងដាច់ដោយឡែកមួយទៀតទុកដាក់ទឹកស្អាត សម្រាប់ដុសលាងដៃ ឬមុខមាត់ ។ នៅក្នុងគម្ពីរ **ចុល្លវគ្គ** មានសេចក្ដីអធិប្បាយដ៏ពិស្ដារមួយ អំពីរបៀបកសាងបង្គន់ ដោយក្រាលឥដ្ឋ ថ្ម ឬឈើ ហើយមានដាក់លូបង្ហូរទឹកចេញ ដើម្បីឱ្យកម្រាលឥដ្ឋ ឬក្ដារក្រាលនៅស្ងួតជាប់ជានិច្ច ។ បង្គន់រមែងតែមានរបង និងរានហាលខាងមុខ ហើយមានទ្វារមួយសម្រាប់ចេញចូល ។ គេមានទម្លាប់ដាក់ភាជន៍ ឬផើងធំមួយ សម្រាប់ដាក់ទឹក ដើម្បីលាងជម្រះផងដែរ ។

សហគមន៍ព្រះពុទ្ធសាសនា មានការយកចិត្តទុកដាក់ជាយូរយារណាស់មកហើយ អំពីការថែរក្សាការការបរិស្ថានឱ្យបានស្អាត និងមានសុខភាពល្អ ។ គេបានបង្រៀនភិក្ខុទាំងឡាយ ឱ្យចេះកសាងបង្គន់ផ្ទាល់របស់ខ្លួន ដើម្បីថែរក្សាភាពស្អាតបាត របស់បុគ្គលម្នាក់ៗផង និងបរិស្ថានផងដែរ ។ មានរឿងមួយបាននិទានអំពីភិក្ខុសង្ឃវ័យចំណាស់ និងមានឈ្មោះល្បីល្បាញមួយអង្គ មានបំណងអាក្រក់ក្នុងការដោះទឹកមូត្រ នៅទីកន្លែងល្អល្អៃ និងមានមនុស្សកុះករ ។ សង្កេតឃើញនូវរឿងនេះ មានគហបតីមួយរូបបានរួសរាន់សង់បង្គន់មួយ ដែលហ៊ុំជញ្ជាំងដោយកំណាត់សំពត់ ។ គហបតីរូបនោះ លុះក្រោយមក បានកើតជាទេវបុត្រនៅលើស្ថានសួគ៌ ដោយសារតែអំពើល្អរបស់ខ្លួន ។ អនាម័យខ្លួនប្រាណ ក៏ដូចជាអនាម័យខាងផ្លូវចិត្តដែរ ‹សមាធិ ភាវនា ក៏ដូចគ្នានឹងការធ្វើចិត្តឱ្យល្អបរិសុទ្ធដែរ› គឺជាជំហានដ៏សំខាន់ជាងគេបំផុត ក្នុងការអភិវឌ្ឍ និងការថែរក្សាបរិស្ថានឱ្យបានស្អាត និងមានសុខភាពល្អ ។ កាលបើយើងបានសិក្សាយល់បានច្បាស់ អំពីការថែរក្សាខ្លួនយើងបានហើយ នោះវាមុខតែនឹងមានការងាយស្រួល ក្នុងការថែរក្សាបរិស្ថាននៅជុំវិញយើងដែរ ។



www.elibraryofcambodia.org

## សំណួរពិភាក្សា

១- ចូរពិភាក្សារកវិធីកែលំអគ្រឿងបរិក្ខារអនាម័យ និងការអនុវត្តអនាម័យ នៅក្នុងវត្តព្រះតេជព្រះគុណ-លោកអ្នក និងសហគមន៍នៅជុំវិញ ។

២. ចូរពិភាក្សារកវិធីប្រតិបត្តិជាក់ស្តែង ដែលសហគមន៍វត្តអាចបង្រៀនអ្នកស្រុក អំពីអនាម័យជាមូលដ្ឋាន ដូចជា ការប្រើប្រាស់បង្គន់ និងការលាងសំអាតដៃជើង មុនឆាន់ចង្ហាន់ និងក្រោយពេលចេញពីបង្គន់ជាដើម ។



www.elibraryofcambodia.org



៧៩. សារសំខាន់នៃអនាម័យ

www.elibraryofcambodia.org

www.elibraryofcambodia.org

**មេរៀន**
**៧ ឃ**

# ការបំពុលដោយសូរសំឡេង

នាសម័យថ្ងៃមួយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បានទូន្មានប្រៀនប្រដៅ ដោយបានបញ្ជាក់នៅក្នុង **គម្ពីរមជ្ឈិមនិកាយ** ថា :

*" ម្នាលភិក្ខុទាំងឡាយ កាលណាអ្នកមកជួបជុំគ្នា*
*កាលនោះអ្នកគប្បីជជែកប្រជុំគ្នា អំពីប្រការទាំងឡាយ*
*ដែលប្រកបដោយអត្ថន័យផង គប្បីប្រកាន់យក*
*ភាពស្ងាត់ស្ងៀមដ៏ខ្ពង់ខ្ពស់ប្រសើរថ្លៃថ្លាផង "* ។

យោងតាមព្រះពុទ្ធដីកានេះ ការរក្សាភាពស្ងាត់ស្ងៀម គឺជាការប្រតិបត្តិដ៏ប្រសើរមួយ ។ ព្រះសម្មាសម្ពុទ្ធបរមគ្រូបានរិះគន់ ចំពោះសភាពអ៊ូអរទ្រហឹងអឹងកង ហើយគ្រាមួយ ទ្រង់បានត្រាស់បញ្ជាឱ្យភិក្ខុមួយក្រុមចាកចេញពីវត្ត ក៏ព្រោះតែអាកប្បកិរិយា បង្កភាពអ៊ូអរកងរំពងនេះ ។ នៅក្នុង **គម្ពីរអង្គុត្តរនិកាយ** ភាពអ៊ូអរកងរំពង ចាត់ទុកជាបន្លាមួយ ចំពោះបុគ្គលដែលកំពុងតាំងសមាធិភាវនាជាលើកដំបូងរបស់ខ្លួន ។ ទម្លាប់ស្ងៀមស្ងាត់ និងការរស់នៅស្ងាត់ដាច់ពីគេឯង ជំរុញឱ្យមានស្វ័យភ្ញាក់រលឹក ឬការដឹងដោយខ្លួនឯង ។

ការបំពុលដោយសូរសំឡេងអ៊ូអរយ៉ាងទ្រហឹង នៅបណ្តាទីក្រុង ទីប្រជុំជន និងភូមិទាំងឡាយជាច្រើននៅប្រទេសកម្ពុជា កំពុងមានការកើនឡើងជាខ្លាំង ដោយសារតែកំណើនដ៏គំហុកនៃការធ្វើចរាចររបស់យានយន្តគ្រប់ប្រភេទនៅលើផ្លូវ ឬតាមដងវិថីទាំងឡាយ ការប្រើប្រាស់ម៉ាស៊ីនភ្លើង ឧត្សាហកម្មសំណង់ និងម៉ាស៊ីនការ៉ាអូខេ ។ល។ សំឡេងជាភ្នាក់ងារបំពុលដ៏ធ្ងន់ធ្ងរមួយ សំរាប់មនុស្ស និងបរិស្ថាន ដែលអាចបណ្តាលឱ្យមានអារម្មណ៍រំខាន មួម៉ៅក្តៅក្រហាយ និងបណ្តាលឱ្យថ្លង់ ។ សំឡេងធ្វើឱ្យខ្ជះខ្ជាយពេល និងបន្ថយប្រសិទ្ធភាពការងារ ។ សំឡេងអាចរំខានដល់សមាជិកដទៃទៀតរបស់សហគមន៍ ដោយសារវារំខានដល់ការងារ ការសិក្សារៀនសូត្រ ដំណេក និងការសំរាកកំសាន្ត ដែលអាចងាយនាំទៅរកឱ្យមានជម្លោះ និងទំនាស់គ្នា ។



www.elibraryofcambodia.org

## សំណួរពិភាក្សា

១. ចូរនាំគ្នាអង្គុយជាក្រុម ដោយរក្សាភាពស្ងៀមស្ងាត់ ក្នុងរយៈពេលចំនួន ៥នាទី ។ តើព្រះតេជព្រះគុណ-លោកអ្នក មានឮសំឡេងអ្វីខ្លះទេ ? តើសំឡេងណាធ្វើឱ្យពេញចិត្ត ? ហើយតើមានសំឡេងបែបណាមួយ ដែលធ្វើមិនឱ្យពេញចិត្ត ? ចូរពិភាក្សា ?

២. ក្នុងការតាំងចិត្តឱ្យស្ងាត់ស្ងៀមមួយរយៈ ចូរអនុវត្ត ដោយការធ្វើសមាធិការនៅក្នុងក្រុម ក្នុងរយៈពេល ១០ នាទី ។ ចូរនាំគ្នាផ្តោតចិត្តផ្តោតអារម្មណ៍ ទៅលើការដកដង្ហើមចេញនិងចូល ហើយចូរធ្វើការកត់សំគាល់នូវចលនាទាំងឡាយ របស់រូបរាងកាយរបស់យើង ។ ចូរជៀសវាងកុំកត់សំគាល់យកភាពអ៊ូអរនៃសំឡេងពីខាងក្រៅ ។ ចូរពិភាក្សាពីចិត្ត ឬអារម្មណ៍ខាងក្នុង ដែលព្រះតេជព្រះគុណ-លោកអ្នក បានជួបប្រទះនេះ ។



www.elibraryofcambodia.org

## ៧ឃ. ការបំពុលដោយសូរសំឡេង




www.elibraryofcambodia.org

www.elibraryofcambodia.org

មេរៀន
៧ ១

## កំណែច្នៃជាថ្មីឡើងវិញ

ក្រោយពីព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ចូលបរិនិព្វានបានបន្តិចមក **ព្រះមហាអានន្ទ** ជាឧបដ្ឋាកៈរបស់ព្រះពុទ្ធជាម្ចាស់ បានធ្វើការពិភាក្សាមួយជាមួយស្តេច **ឧទេនរាជ** ។ នៅពេលនោះ បរិពារចំនួន ៥០០ នាក់ របស់ស្តេច **ឧទេន** បានទៅកាន់សំណាក់ព្រះ **អានន្ទ** ដើម្បីស្តាប់ព្រះធម៌ដែរ ។ ដោយមានសេចក្តីសប្បាយរីករាយជ្រះថ្លា ជាមួយពាក្យប្រៀនប្រដៅរបស់ព្រះ **អានន្ទ** នោះ បរិពារទាំង ៥០០ នាក់ ក៏បានប្រគេនចីពរចំនួន ៥០០ ត្រៃ ដល់ព្រះភិក្ខុអង្គនោះ ។ ភ្ញាក់ផ្អើលនឹងព្រឹត្តិការណ៍បែបនេះ ព្រះរាជាអង្គនោះ បានចូលទៅកាន់ព្រះ **អានន្ទ** ហើយបានទូលសួរថា :

*"ព្រះតេជព្រះគុណនឹងធ្វើអ្វីខ្លះ ជាមួយនឹងស្បង់ចីពរដ៏ច្រើនសន្ធឹកសន្ធាប់បែបនេះ ?*
*តើព្រះតេជព្រះគុណបំរុងនឹងបើកហាងលក់ស្បង់ចីពរទាំងអស់នេះ មែនដែរឬទេ ?"*
*ព្រះមហាអានន្ទបានឆ្លើយតបវិញថា : "អាត្មាភាពនឹងចែករំលែកស្បង់ចីពរទាំងនេះ*
*ប្រគេនដល់ភិក្ខុទាំងឡាយដទៃទៀត" ។ ព្រះរាជាអង្គនោះបានទូលសួរបន្តទៀតថា :*
*"តើភិក្ខុទាំងនោះនឹងយកស្បង់ចីពរចាស់ៗទាំងនោះ ទៅធ្វើអ្វីដែរ ?" ។*

ក្នុងការឆ្លើយតបនឹងសំណួរខាងលើនេះ ព្រះ **អានន្ទ** បានពន្យល់អំពីដំណើរការនៃការប្រើប្រាស់ស្បង់ចីពរចាស់ៗទាំងនោះឡើងវិញ ។ កាលណាគេបានទទួលស្បង់ចីពរថ្មី ស្បង់ចីពរចាស់ត្រូវគេយកទៅប្រើប្រាស់ជាកម្រាលពូក បើកម្រាលពូកនោះចាស់ទៅ ត្រូវយកទៅប្រើជាស្រោមពូក ហើយបើស្រោមពូកចាស់ទៅ ត្រូវយកទៅប្រើជាកម្រាលព្រំទៀត លុះកម្រាលព្រំចាស់ទៅ ត្រូវយកទៅប្រើជាក្រណាត់ជូតធូលី ហើយបើក្រណាត់ជូតធូលីនោះចាស់ទៅ គេយកទៅប្រើជាក្រណាត់ជូតជើង ហើយបើក្រណាត់ជូតជើងនេះចាស់រហែករយ៉ីរយ៉ៃទៅនោះ នៅទីបំផុត គេត្រូវយកវាមកច្របាច់លុញជាមួយដីឥដ្ឋ ដើម្បីប្រើសម្រាប់ជូសជុលក្តារក្រាល និងជញ្ជាំងដែលប្រហោង ឬប្រេះបែក (**ព្រះវិន័យបិដកភាគទី ២**) ។ ដូច្នេះ គ្មានរបស់អ្វីដែលអាចប្រើប្រាស់បាន ត្រូវគេបោះចោលនោះឡើយ ។ បុគ្គលទាំងឡាយណា ដែលខ្ជះខ្ជាយ បុគ្គលនោះត្រូវគេអធិប្បាយថាជា "អ្នកបរិភោគផ្លែឈើព្រៃ" អញ្ចឹង ។ មនុស្សអង្រួនមែកឈើ ហើយផ្លែទាំងអស់ទាំងទុំ ទាំងខ្ចី រមែងតែជ្រុះធ្លាក់មកលើដីទាំងអស់ ។ មនុស្សតែងតែប្រមូលយកនូវអ្វីដែលគេត្រូវការប៉ុណ្ណោះ ហើយបោះបង់ចោលរបស់សេសសល់ ដែលខ្លួនមិនត្រូវការ ឱ្យខូចស្អុយរលួយ (**គម្ពីរអង្គុត្តរនិកាយភាគ៤**) ។



www.elibraryofcambodia.org

## សំណួរពិភាក្សា

១. តើមានរបស់អ្វីខ្លះ ដែលវត្តរបស់ព្រះតេជព្រះគុណ និងផ្ទះសំបែងរបស់លោកអ្នក អាចយកមកកែច្នៃជាថ្មី ប្រើប្រាស់ឡើងវិញបានជាទៀងទាត់ ? តើមានរបស់របរដែលព្រះតេជព្រះគុណ-លោកអ្នកបោះចោល អាចយកមកប្រើប្រាស់ឡើងវិញបានដែរឬទេ ?

២. ចូរពិភាក្សារកវិធីទាំងឡាយ ដែលកំណែច្នៃជាថ្មីឡើងវិញ អាចធ្វើឱ្យទៅជាផ្នែកដ៏ទៀងទាត់មួយសំរាប់ជីវិតប្រចាំថ្ងៃ របស់វត្តរបស់ព្រះតេជព្រះគុណ និងផ្ទះសំបែងរបស់លោកអ្នក ។



www.elibraryofcambodia.org



៧១. កំណែរថ្លូជាថ្មីឡើងវិញ

www.elibraryofcambodia.org

www.elibraryofcambodia.org

## សកម្មភាព

# យើងចៀសវាងការបំពុលបរិស្ថាន

១. **វត្ថុបំណង** ៖ ដើម្បីវិភាគមើលវិធីទាំងឡាយ ដែលយើងបង្កឱ្យមានភាពកខ្វក់ ឬបំពុល នៅក្នុងជីវភាពប្រចាំថ្ងៃរបស់យើង និងដើម្បីស្វែងរកវិធីដ៏សាមញ្ញបំផុត ដែលអាចកាត់បន្ថយបាននូវការបំពុលបរិស្ថានរបស់យើង ។

២. **សកម្មភាព** ៖

**ក. ពិសោធន៍**

ចូរចាក់ទឹកទៅក្នុងពាងពីរឱ្យពេញ ប៉ុន្តែពាងមួយត្រូវគ្របបិទឱ្យជិត ។ រួចហើយយើងទុកចោលវាឱ្យបានចំនួនមួយសប្តាហ៍ ។ បន្ទាប់មក យើងត្រឡប់ទៅមើលពាងនិមួយៗវិញ តើទឹកពាងណាមួយ ដែលព្រះតេជព្រះគុណ-លោកអ្នក គួរឆាន់ ឬពិសារបាន ?

**ខ. ចូរនាំគ្នាសំអាតឡើងវិញ !**

ចូររកតំបន់ណាមួយ នៅក្នុងសហគមន៍របស់ព្រះតេជព្រះគុណ-លោកអ្នក ដែលរងការបំពុល អាចជាប្រភពទឹក ឬជាកន្លែងចាក់សំរាម ។ រួចចូរនាំគ្នានឹកគិតរកវិធី ដើម្បីរៀបចំសកម្មភាពរបស់សហគមន៍មួយ ( ស្រមទាន [១៧] ) ដើម្បីនាំគ្នាសំអាតតំបន់នេះ ហើយនិងដើម្បីថែរក្សាការពារវា ឱ្យបានស្អាតជាប់ជានិច្ច នៅក្នុងពេលអនាគត ។ ចូរប្រើគំនិតទាំងនេះឱ្យទៅជាការអនុវត្តជាក់ស្តែង ។

**គ. ចូរនាំគ្នាកែច្នៃជាថ្មីឡើងវិញ !**

ចូរធ្វើការកត់ត្រា ចំពោះអ្វីដែលព្រះតេជព្រះគុណ-លោកអ្នក បានបោះវត្ថុ ឬសំរាមចោលទៅក្រៅក្នុងរយៈពេលមួយសប្តាហ៍ ។ តើមានវត្ថុ ឬសំរាមចំនួនប៉ុន្មាន ដែលគេអាចយកទៅច្នៃ ប្រើប្រាស់ឡើងវិញបាន និងតាមវិធីបែបណា ? ចូរប្រើគំនិតទាំងនេះ ឱ្យទៅជាការអនុវត្តជាក់ស្តែង ។

---

[១៧] *ស្រមទាន ៖ គឺជាសកម្មភាពរបស់សហគមន៍ ដែលត្រូវបានរៀបចំបង្កើតឡើងដោយខ្លួនឯង ដើម្បីកែលំអនូវស្ថានភាពរស់នៅក្នុងសហគមន៍ និងដើម្បីសហគមន៍ទាំងមូល ។*



www.elibraryofcambodia.org

**ជាទីបញ្ចប់ ៖**

- រៀបចំ និងគូររូបភាពអំពីបរិស្ថានមួយល្អឥតខ្ចោះ នៅលើក្រដាសមួយសន្លឹកធំ ដោយការប្រើគំនិតទាំងអស់ ដែលយើងបានដឹងពីរឿងរ៉ាវជាច្រើន មាននៅក្នុងសៀវភៅនេះ ហើយនិងគំនិតនានា ដែលយើងធ្លាប់បានគិត ។
- រួចហើយដាក់តាំងរូបគំនូរនោះ នៅទីកន្លែងសាធារណៈ ដូចជាវត្ត ឬសាលារៀន ដើម្បីឱ្យអ្នកដទៃអាចរៀនសូត្របានពីគំនិតរបស់ព្រះតេជព្រះគុណ-លោកអ្នក ។
- សូមប្រាប់ឱ្យបានដឹងផង ប្រសិនបើព្រះតេជព្រះគុណ-លោកអ្នក អាចស្វែងរកបានរឿងពុទ្ធនិយមដទៃផ្សេងទៀត ដែលមានទាក់ទងនឹងបរិស្ថាន ហើយសូមស្នើដាក់បញ្ចូលរឿងទាំងនោះ ទៅក្នុងសៀវភៅនេះ ដោយមានភ្ជាប់រូបភាពផង ដើម្បីរំលេចលំអរឿងបន្ថែមរបស់ព្រះតេជគុណ-លោកអ្នក ឱ្យកាន់តែមានសម្រស់ថែមទៀត ។

គណៈកម្មការនិពន្ធ និងរៀបរៀងសៀវភៅនេះ តាងនាមឱ្យក្រុមអប់រំបរិស្ថានសំរាប់ព្រះសង្ឃខ្មែរ និងអង្គការឃ្មុំអិនឌីភី-អេតាប់ សូមថ្លែងអំណរព្រះគុណនិងអរគុណចំពោះការចូលរួមវិភាគទានដ៏ថ្លៃថ្លារបស់ព្រះតេជព្រះគុណ-លោកអ្នក ក្នុងការចូលរួមជាគំនិត និងសកម្មភាពថែរក្សាការពារបរិស្ថាន ទាំងក្នុងមូលដ្ឋាន ក៏ដូចក្នុងប្រទេសជាតិរបស់យើងដែរ ដើម្បីអនាគតល្អត្រចះត្រចង់នៃកុលបុត្រ-កុលធីតា របស់យើងទាំងអស់គ្នា ។

## ការពារបរិស្ថាន គឺការពារសុខភាពរបស់យើង



www.elibraryofcambodia.org

# ឯកសារពិគ្រោះ
# (Bibliography)


## ឯកសារជាភាសាខ្មែរ

ដេវីស, ជន និង ហ្គ័រដុន ក្លារីដ្យ, *ផលប្រយោជន៍នៃតំបន់ដីសើម ។ សក្ខានុពលសំរាប់តំបន់ដីសើម ដើម្បីទ្រទ្រង់និងថែទាំការអភិវឌ្ឍ* ។ ភ្នំពេញ : ការិយាល័យតំបន់ដីសើមអាស៊ី, ១៩៩៣ ។

ក្លារីដ្យ ហ្គ័រដុន, ប្រែសំរួលដោយ ម៉ម កុសល និង អ៊ុំ ពិសី, *គម្រោងការបង្ហាញសំរាប់ការអភិរក្សធនធានតំបន់ដីសើម និងការប្រើប្រាស់ធានានូវនិរន្តរភាពនៅតំបន់ដីកក់ទន្លេចាស់នៅកម្ពុជា* ។ ភ្នំពេញ : យូអិនឌីភី/អ៊ីកាប់, ១៩៩៧ ។

*សារពត៌មានបរិស្ថាន, ឯកសារសិក្ខាសាលា ២-១៤ ឧសភា ១៩៩៤* ។ ភ្នំពេញ : វិទ្យាស្ថានគមនាគមន៍កម្ពុជា ឧបត្ថម្ភដោយ យូនេស្កូ-ដានីដា, ១៩៩៤ ។

*បរិស្ថានយើង* ។ សំរាប់បឋមសិក្សា ។ ភ្នំពេញ : ក្រសួងបរិស្ថាន និង ក្រសួងអប់រំ យុវជន និងកីឡា ឧបត្ថម្ភដោយយូនេស្កូ និង យូអិនឌីភី /សៀត, ១៩៩៤ ។

*ការអប់រំបរិស្ថាន* ។ សៀវភៅសំរាប់គ្រូបឋមសិក្សា ។ ភ្នំពេញ : គណៈកម្មការអន្តរក្រសួងទទួលបន្ទុកការអប់រំបរិស្ថាន, ១៩៩៤ ។

*របាយការណ៍សង្ខេបស្តីពីស្ថានភាពបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា ១៩៩៤* ។ ភ្នំពេញ : ក្រសួងបរិស្ថាន ឧបត្ថម្ភដោយ យូអិនឌីភី និងស្ថាប័ននានា, ១៩៩៥ ។

*ឆ្ពោះទៅកាន់អភិសមាចារបរិស្ថានសំរាប់តំបន់អាស៊ីអាគ្នេយ៍* ។ ទម្រង់ការនៃសិក្ខាសាលាប្រចាំតំបន់ រៀបចំដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ៥-៧ វិច្ឆិកា ១៩៩៧ ។ ភ្នំពេញ : ពុទ្ធសាសនបណ្ឌិត្យ, ១៩៩៨ (បោះពុម្ពផ្សាយជាភាសាអង់គ្លេស ។

សម្តេច ជួន ណាត, *វចនានុក្រមខ្មែរ* ។ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ : ១៩៦៧ បោះពុម្ពឡើងវិញ វិច្ឆិកា ១៩៩៥ ។

ទិន ពន្លក, *វចនានុក្រមបច្ចេកសព្ទបរិស្ថាន* ។ បោះពុម្ពលើកទី ១, ភ្នំពេញ, ១៩៩៨ ។

## ឯកសារជាភាសាអង់គ្លេស

Burlingame, Eugene Watson (trans). *Buddhist Legends-translated from the original Pali text of the Dhammapada Commentary, Part 1, 2 & 3.* Cambridge: Harvard University Press/Pali Text Society, 1990.

Carino, Feliciano V. *The Greening of Faith.* National Council of Churches, Philippines, 1992.

Davies, Shann (ed). *Buddhist Perception of Nature.* Buddhist Perception of Nature Project, 1987.

Geertz, Clifford. *Local Knowledge-Further in interpretive Anthology.* Fontana Press, 1993.

Kabilsingh, Chatsumarn. *A Cry from the Forest - the Buddhist Perception of Nature.* Wildlife Fund, 1987.

Kotler, Arnold (ed). *Engaged Buddhist Reader. Berkeley:* Parallax Press, 1996.

Roscoe, Gerald. *The Triple Gem - An Introduction to Buddhism.* Chiang Mai: ilkworm Books, 1994.

Sandell, Klas. *Buddhist Perspectives on the Ecocrisis. Kandy:* Buddhist Publication Society, 1987.

*Seeds of Peace* (various articles). International Network of Engaged Buddhists, Bangkok, Thailand.

Zepp, Ray. *A Field Guide to Cambodian Pagodas.* Bert's Books, Phnom Penh, 1997.




www.elibraryofcambodia.org

- បុគ្គលណាមួយ ដែលចៀសវាងរួចអំពីការធ្វើឱ្យរបួសគ្រោះថ្នាក់ដល់ជីវិតគ្រាប់ពូជ និងជីវិតរុក្ខជាតិ..... លះបង់ចោលនូវសេចក្តីសៅហ្មង ដែលកើតអំពីបំណងអាក្រក់ ប្រកបដោយចិត្តរួចផុតពីបំណងអាក្រក់ បុគ្គលនោះនឹងរស់នៅដោយមានការគោរពចំពោះសុខុមាលភាព និងមានអារម្មណ៍ប្រកបដោយមេត្តាករុណា ចំពោះគ្រប់ភាវៈដែលមានជីវិតទាំងអស់ បុគ្គលនោះមានឈ្មោះថា បានសំអាតនូវចិត្តរបស់ខ្លួនដែលសៅហ្មងដោយបំណងអាក្រក់ ។
- ឈើដែលធ្លាប់ឱ្យម្លប់ដ៏ត្រជាក់ត្រឈៃដល់អ្នកសម្រាប់អង្គុយលេង ឬដេកលេងតាមតម្រូវការ អ្នកមិនត្រូវបែកកាប់មែកធាងវាចុះទេ អំពើព្រៃផ្សៃគ្មានត្រាប្រណីនឹងកើតឡើង **(ជាតកគាថាទី៥)** ។
- ដូចជាសត្វឃ្មុំមិនធ្វើឱ្យមានការខូចខាតដល់ផ្កា ពណ៌សម្បុរ និងក្លិនរបស់ផ្កាឡើយ ។ រួចវាហើរបាត់ទៅវាក្រេបយកតែទឹកដមផ្កាប៉ុណ្ណោះឯង យ៉ាងណាមិញបណ្ឌិតទាំងឡាយជាអ្នកប្រាជ្ញ គប្បីត្រាច់ចរទៅក្នុងភូមិស្រុកក៏ដូច្នោះដែរ ។
- កាលណាយើងស្រឡាញ់ ការពារបរិស្ថាន កាលនោះធម្មជាតិមុខតែល្អចំពោះយើងហើយ ។ ដើមឈើទាំងឡាយ ប្រៀបឧបមាដូចជាមាតាបិតារបស់យើងដូច្នេះដែរ ។ ដើមឈើចិញ្ចឹមបីបាច់ ថែរក្សាយើងឱ្យធំធាត់ ផ្គត់ផ្គង់ដល់យើងនូវវត្ថុគ្រប់បែបយ៉ាង មានដូចជា ផ្លែ ស្លឹក មែក ដើម ជាដើម ។ ឈើទាំងនោះ ផ្តល់ដល់យើងនូវម្ហូបអាហារ និងបំពេញបំណងប្រាថ្នារបស់យើងជាច្រើនទៀត ។ ប៉ុន្តែបើយើងកាប់រំលំដើមឈើចោល វានឹងមិនមានភ្លៀងតទៅទៀតទេ ។ ដើមឈើធ្វើឱ្យមានភ្លៀងធ្លាក់ ។ អាស្រ័យហេតុនេះហើយ នៅក្នុងការធ្វើធម្មយាត្រានេះ យើងនឹងផ្សព្វផ្សាយព្រះធម៌ អំពីការថែរក្សាការពារខ្លួនយើង និងការថែរក្សាការពារបរិស្ថានរបស់យើង ដែលនេះជាព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធជាអម្ចាស់នៃយើងទាំងអស់គ្នា **(សម្តេចព្រះមហាឃោសានន្ទ)** ។

UNDP/ETAP

គម្រោងការអប់រំបរិស្ថានសំរាប់ព្រះសង្ឃខ្មែរ

This non-formal education manual was prepared by the NGO Working Group of the Monk Environmental Education Project (MEEP) in the Kingdom of Cambodia with technical assistance from UNDP's Environmental Technical Advisory Programme (ETAP) in Cambodia. The writing, editing, and printing of the manual was supported by UNDP/ETAP in collaboration with UNESCO-Cambodia and with additional funds for printing provided by the Embassy of Great Britain and Northern Ireland in the Kingdom of Cambodia.

Pac $4.30
100065
www.elibraryofcambodia.org

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះរៀមច្បងវេជ្ជបណ្ឌិត ខ្ញៅ ឃុនសំរ៉ង ព្រមទាំងសហការីលោកដែលបានផ្តួចផ្តើមគំនិតធ្វើ បណ្ណាល័យអេឡិចត្រូនិច e-library ដែលមានគុណប្រយោជន៍ធំធេងនេះ។ខ្ញុំមានសំណាងណាស់ដោយបានចូលរួបរួមក្នុងគម្រោងនេះហើយបានទទួលឱកាសបង្ហាញនូវសៀវភៅដ៏កម្រដែលបោះពុម្ពផ្សាយក្នុងកម្លុងទសវត្ស៥០-៦០ដែលជាអំណោយនៃអតីតមន្រ្តីការបរទេសជប៉ុនគឺលោកវ៉ាតាណាបិ តូរី MrWatanabe Toru និងលោកស្រីចៃត្រ ចេក្ង(បុត្រីរបស់លោកចៃត្រ-ឆែម)និងមួយភាគបានពីACCU(Asian Cultural Centre of UNESCO in Tokyo,Ms Matsuo Naoko)មករូបខ្ញុំនិងបណ្តាំឱ្យផ្សព្វផ្សាយចែកចាយជាចំណោះដឹងដល់កុលបុត្រខ្មែរព្រមទាំងអ្នកសិក្សាភាសាខ្មែរ។ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកដែលមានការចាប់អារម្មណ៍នឹងសៀវភៅទាំងឡាយនេះនិងបួងសួងសុំឱ្យភាសាជាតិយើងមានភាពថ្កុំថ្កើងត្រចះត្រចង់ជានិច្ចនិរន្តតទៅ។ បណ្ឌិតប៉ែន សេដ្ឋារិន

www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ស្កេន ជា eBook ដោយ ឃើម បូរ៉េន

ឧសភា ឆ្នាំ ២០១៥

យើងខ្ញុំសូមថ្លែងអំណរអរគុណ យ៉ាងជ្រាលជ្រៅដល់

**បណ្ឌិតប៉ែន សេដ្ឋារិន**

ដែលបានផ្ញើសៀវភៅនេះមកយើងខ្ញុំ

សម្រាប់ក្នុងការថែរក្សាទុកនិង ផ្សព្វផ្សាយជាទូទៅ

ដើម្បីបម្រើប្រយោជន៍សាធារណៈ ដោយមិនគិតយកកម្រៃ

សូមអរគុណ

ខ្មៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org